៩- លោក ធឿន សុត្ថា មន្ត្រីផ្នែកបោះពុម្ពផ្សាយនិងបណ្ណាល័យ នៃរាជបណ្ឌិត្យសភាកម្ពុជា សមាជិក

១០- លោក ម៉ន វុត្ថា មន្ត្រីវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម សមាជិក

១១- លោកស្រី កែវ ខេមរា ប្រធានផ្នែកបោះពុម្ពផ្សាយនិងបណ្ណាល័យ នៃរាជបណ្ឌិត្យសភាកម្ពុជា សមាជិក

១២- លោកបណ្ឌិត ឈឹម ផាន់ណា មន្ត្រីវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា សមាជិក

១៣- លោកបណ្ឌិត ហុង វណ្ណៈ ប្រធានផ្នែកទំនាក់ទំនងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា សមាជិក

១៤- លោក យឹម រិទ្ធិកា អនុប្រធានលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ជំនួយការខាងភាសា

**១.១៣- គណៈកម្មការវិទ្យាសាស្ត្រអប់រំ មានសមាសភាពដូចខាងក្រោម ៖**

១- ឯកឧត្តមបណ្ឌិត នូ ចាន់សុភី ប្រធានវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ ប្រធាន

២- ឯកឧត្តមបណ្ឌិត កង ឌិម ទីប្រឹក្សាអមរាជបណ្ឌិត្យសភាកម្ពុជា អនុប្រធាន

| | | |
|---|---|---|
| ៣- លោក មាឃ សារី | ប្រធានផ្នែកវិទ្យាសាស្ត្រអប់រំនៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម | សមាជិក |
| ៤- លោក ហ៊ាន ស្រស់ | លេខាអចិន្ត្រៃយ៍នៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា | សមាជិក |
| ៥- លោកបណ្ឌិត សូ សុធីរ | មន្ត្រីវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម | សមាជិក |
| ៦- លោកស្រី តាំង មុយគា | មន្ត្រីចូលនិវត្តន៍ | សមាជិក |
| ៧- លោក សន ចាន់ថៃ | មន្ត្រីវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម | សមាជិក |
| ៨- កញ្ញា អ៊ិន សុភ័ក្រ្ត | មន្ត្រីវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម | សមាជិក |
| ៩- លោក លី គុង | មន្ត្រីឧទ្យានរាជបណ្ឌិត្យសភាកម្ពុជាតេជោសែន ឫស្សីត្រឹប | សមាជិក |
| ១០- លោក សេង មាន | មន្ត្រីឧទ្យានរាជបណ្ឌិត្យសភាកម្ពុជាតេជោសែន ឫស្សីត្រឹប | សមាជិក |
| ១១- លោក ស្រី សីហា | មន្ត្រីឧទ្យានរាជបណ្ឌិត្យសភាកម្ពុជាតេជោសែន ឫស្សីត្រឹប | សមាជិក |
| ១២- លោក កែវ លីណែត | មន្ត្រីវិទ្យាស្ថានភាសាជាតិ | ជំនួយការខាងភាសា |

**១.១៤- គណៈកម្មការសុខាភិបាល មានសមាសភាពដូចខាងក្រោម ៖**

| | | |
|---|---|---|
| ១- ឯកឧត្តមបណ្ឌិតសភាចារ្យ សំ សោភាន់ | ទីប្រឹក្សាអមរាជបណ្ឌិត្យសភាកម្ពុជា | ប្រធាន |
| ២- ឯកឧត្តមបណ្ឌិត នុត សម្បត្តិ | ប្រធានវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម | អនុប្រធាន |
| ៣- ឯកឧត្តម ប៉ែន បូនពីរ | ទីប្រឹក្សាឯកឧត្តម នៃ ប៉េណា អនុប្រធានទី១ព្រឹទ្ធសភា | សមាជិក |
| ៤- លោកជំទាវ ឡុង ថុល | ទីប្រឹក្សាអមរាជបណ្ឌិត្យសភាកម្ពុជា | សមាជិក |
| ៥- លោកបណ្ឌិត តាំង ស៊ិន | មន្ត្រីវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម | សមាជិក |
| ៦- លោក អាត ធារ៉ា | មន្ត្រីវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម | សមាជិក |
| ៧- លោកវេជ្ជបណ្ឌិត ស្វាយ កាម៉ុល | នាយកមន្ទីរពេទ្យនៃវិទ្យាស្ថានវិទ្យាសាស្ត្រ | |

សុខាភិបាលខេមរភូមិន្ទ សមាជិក

៨- លោក ជុំ គឹមវ៉ង មន្ត្រីវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម សមាជិក

៩- លោក ម៉ាន់ សុងញា មន្ត្រីវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម សមាជិក

១០- លោក ឃឹម វិច្ឆិកា អនុប្រធានលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ជំនួយការខាងភាសា

**១.១៥- គណៈកម្មការស្ថាបត្យកម្ម និងសំណង់ មានសមាសភាពដូចខាងក្រោម ៖**

១- លោក លឹម សុក្រាត មន្ត្រីវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ ប្រធាន

២- លោក ឈួក ឆៃហ៊ិង វិស្វករ អនុប្រធាន

៣- លោកបណ្ឌិត គឹម ពីនន់ ព្រឹទ្ធបុរសមហាវិទ្យាល័យសិល្បៈ នាដសាស្ត្រនៃសាកលវិទ្យាល័យ ភូមិន្ទវិចិត្រសិល្បៈ សមាជិក

៤- លោកបណ្ឌិត ចិន្ត ច័ន្ទវេតនា សមាជិកសមាគមប្រវត្តិវិទូខ្មែរ សមាជិក

៥- លោកបណ្ឌិត ងួនផាន ភក្តី ព្រឹទ្ធបុរសមហាវិទ្យាល័យវិស្វកម្ម នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ សមាជិក

៦- លោក វ៉ា ម៉ូរិន ទីប្រឹក្សាអមក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក

៧- លោក សឿន សម្បត្តិ សមាជិកបម្រុងនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សមាជិក

៨- លោក ព្រាប ចាន់ម៉ារ៉ា អ្នកស្រាវជ្រាវ និងបង្រៀន ឯកទេសវប្បធម៌ និងអរិយធម៌ខ្មែរ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សមាជិក

៩- លោក ជា សម្បត្តិ អនុប្រធានឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីស្រ៊ប សមាជិក

១០- លោក ហៀង លាងហុង ប្រធានផ្នែកវប្បធម៌វិទ្យា នៃវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ សមាជិក

១១- លោកបណ្ឌិត ម៉ុម មុនី អនុប្រធាននាយកដ្ឋានឧស្សាហកម្ម និងសំណង់នៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១២- លោក គួយ អភិរាជ វិស្វករ សមាជិក

១៣- លោកបណ្ឌិត ស៊ីន សុជាតិ ប្រធានផ្នែកទំនាក់ទំនងនិងសហប្រតិបត្តិការ

| | | |
|---|---|---|
| | នៃគណៈស្ថាបត្យករកម្ពុជា | សមាជិក |
| ១៤- លោក គុយ វិន | មន្ត្រីវិទ្យាស្ថានភាសាជាតិ | ជំនួយការខាងភាសា |

**១.១៦- គណៈកម្មការអក្ខរាវិរុទ្ធនិងអំណាន មានសមាសភាពដូចខាងក្រោម ៖**

| | | |
|---|---|---|
| ១- ឯកឧត្តម សូ មុយឃៀង | សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ប្រធាន |
| ២- ឯកឧត្តម ឈន អៀម | ទីប្រឹក្សាក្រសួងធម្មការនិងសាសនា | អនុប្រធាន |
| ៣- លោក គុយ វិន | មន្ត្រីវិទ្យាស្ថានភាសាជាតិ | អនុប្រធាន |
| ៤- ឯកឧត្តមបណ្ឌិត សន ពៅ | អនុប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ | សមាជិក |
| ៥- លោកបណ្ឌិត ថោ គឿន | មន្ត្រីក្រុមប្រឹក្សាជាតិភាសាខ្មែរ | សមាជិក |
| ៦- លោក ចាច់ សែម | សមាជិកគណៈកម្មការបណ្ឌិត្យសភា ទទួលបន្ទុកអនុម័តពាក្យច្បាប់ | សមាជិក |
| ៧- លោក លាង សុភាព | ប្រធានលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ | សមាជិក |
| ៨- លោក លឹម លឿម | គ្រូបង្រៀននៅពុទ្ធិកបឋមសិក្សា | សមាជិក |
| ៩- លោកស្រី ហង់ លក្ខិណា | អនុប្រធានលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ | សមាជិក |
| ១០- លោក ទូច គីមស្រ៊ាង | សមាជិកក្រុមជំនុំព្រះត្រៃបិដក នៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ | សមាជិក |
| ១១- លោក ជា ធារិទ្ធ | មន្ត្រីរាជបណ្ឌិត្យសភាកម្ពុជា | សមាជិក |
| ១២- លោក ខូយ សោភ័ណ | មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា | សមាជិក |

**១.១៧- គណៈកម្មការអក្សរសិល្ប៍ មានសមាសភាពដូចខាងក្រោម ៖**

| | | |
|---|---|---|
| ១- ឯកឧត្តមបណ្ឌិតសភាចារ្យ ស៊ុំ ឈុំប៊ុន | អនុប្រធានរាជបណ្ឌិត្យសភាកម្ពុជា | ទីប្រឹក្សា |
| ២- បណ្ឌិតសភាចារ្យ សោម សុមុនី | ទីប្រឹក្សាអមរាជបណ្ឌិត្យសភាកម្ពុជា ទទួលបន្ទុកជាប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម | ប្រធាន |
| ៣- លោកបណ្ឌិត ស៊ុំ ឈុំឡុង | អនុប្រធានវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម | អនុប្រធាន |
| ៤- ឯកឧត្តមបណ្ឌិត ពៅ សាមី | មន្ត្រីចូលនិវត្តន៍ | សមាជិក |
| ៥- លោកបណ្ឌិត ណុន សុខា | ប្រធានផ្នែកអក្សរសិល្ប៍និងអក្សរសាស្ត្រ នៃវិទ្យាស្ថានភាសាជាតិ | សមាជិក |
| ៦- ឯកឧត្តមបណ្ឌិត ជួន ជីវិន | ជំនួយការសម្ដេចអគ្គមហាសេនាបតី | |

| | | |
|---|---|---|
| | តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា | សមាជិក |
| ៧- លោកបណ្ឌិត តាន់ សុគន្ធា | ប្រធានផ្នែកបណ្តុះបណ្តាលនិងស្រាវជ្រាវនៃរាជបណ្ឌិត្យសភាកម្ពុជា | សមាជិក |
| ៨- លោកបណ្ឌិត ហាក់ វ៉ាន់ដារា | ប្រធានផ្នែកនរវិទ្យានិងជាតិពន្ធុវិទ្យា នៃវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម | សមាជិក |
| ៩- ឯកឧត្តម ម៉ុញ សារី | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១០- លោក សុខ កុសល | មន្ត្រីចូលនិវត្តន៍ | សមាជិក |
| ១១- លោកជំទាវ ប៉ក់ សម័យសុវិទ្យានី | ជំនួយការសម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា | សមាជិក |
| ១២- លោកស្រីបណ្ឌិត ភាជ ណាង | មន្ត្រីវិទ្យាស្ថានភាសាជាតិ | សមាជិក |
| ១៣-លោកស្រីបណ្ឌិត ជា វណ្ណី | មន្ត្រីវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម | សមាជិក |
| ១៤- ឯកឧត្តមឧត្តមសេនីយ៍ឯក ស៊ូ សុផាន | អនុប្រធានបណ្ឌិត្យសភានគរបាល | សមាជិក |
| ១៥- លោក ជួន សៅរិទ្ធី | មន្ត្រីក្រុមប្រឹក្សាជាតិភាសាខ្មែរ | សមាជិក |
| ១៦- លោក ឃិន យ៉ង់ | លេខាអចិន្ត្រៃយ៍វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម | សមាជិក |
| ១៧- លោក ហេង សុភី | មន្ត្រីវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម | សមាជិក |
| ១៨- លោក ជា សម្បត្តិ | អនុប្រធានឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រើប | សមាជិក |

**ប្រការ២.-**

គណៈកម្មការបច្ចេកទេសនីមួយៗ មានភារកិច្ចប្រមូលពាក្យនិងកំណត់ន័យនៃពាក្យបច្ចេកទេសរបស់ខ្លួនដែលមានប្រើប្រចមកហើយ និងបង្កើតពាក្យថ្មីក្នុងមុខវិជ្ជារបស់ខ្លួន ដើម្បីស្វែងរកការឯកភាពជាក់ជូនក្រុមប្រឹក្សាជាតិភាសាខ្មែរ ពិនិត្យនិងអនុម័ត។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

អគ្គលេខាធិការរាជរដ្ឋាភិបាល ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ច

**ប្រការ៣.-**

អគ្គលេខាធិការរាជរដ្ឋាភិបាល ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ច និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**និងជារដ្ឋមន្ត្រីស្ដីទីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**ប៊ិន ឈិន**

**កន្លែងទទួល ៖**

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី
លេខ ៤៥ សសរ

សេចក្ដីសម្រេច
ស្ដីពី
ការរៀបចំក្រុមមន្ត្រីជំនួយការលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ

ឧបនាយករដ្ឋមន្ត្រីប្រចាំការ

**និងជារដ្ឋមន្ត្រីស្ដីទីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្ដីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៧/៥៨៦ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលមាត្រា៦នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា និងមាត្រា៤ថ្មី មាត្រា១០ថ្មី មាត្រា១១ថ្មី មាត្រា១២ថ្មី និងមាត្រា២០ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា

ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៦៤១ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការផ្ទេរក្រុមប្រឹក្សាជាតិភាសាខ្មែរឱ្យស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់រាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រាជបណ្ឌិត្យសភាកម្ពុជា
- អនុក្រឹត្យលេខ១៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- យោងតាមសំណើរបស់ប្រធានរាជបណ្ឌិត្យសភាកម្ពុជា

## សម្រេច

**ប្រការ១.**

តែងតាំងមន្ត្រីជំនួយការលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ដូចខាងក្រោម ៖

| | |
|---|---|
| ១- លោកស្រីបណ្ឌិត ហ៊ន សុខុនា | មន្ត្រីវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម |
| ២- លោកបណ្ឌិត ហេង ហុកវេន | មន្ត្រីផ្នែកបណ្តុះបណ្តាលនិងស្រាវជ្រាវនៃរាជបណ្ឌិត្យសភាកម្ពុជា |
| ៣- លោកស្រី រ័ត្ន ធីតា | អនុប្រធានផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ នៃរាជបណ្ឌិត្យសភាកម្ពុជា |
| ៤- លោកស្រី តិប ស៊ីណា | មន្ត្រីវិទ្យាស្ថានភាសាជាតិ |
| ៥- លោកស្រី អ៊ឹង ម៉ាល័យ | មន្ត្រីវិទ្យាស្ថានភាសាជាតិ |
| ៦- លោក រ៉ាត សុផាន | មន្ត្រីវិទ្យាស្ថានភាសាជាតិ |
| ៧- លោក យិន ពោ | មន្ត្រីផ្នែកបណ្តុះបណ្តាលនិងស្រាវជ្រាវនៃរាជបណ្ឌិត្យសភាកម្ពុជា |
| ៨- លោកស្រី សំរិទ្ធ ទេពី | មន្ត្រីផ្នែករដ្ឋបាល និងហិរញ្ញវត្ថុនៃរាជបណ្ឌិត្យសភាកម្ពុជា |
| ៩- លោកស្រី សំរិទ្ធ ចរិយា | មន្ត្រីផ្នែកបោះពុម្ពផ្សាយនិងបណ្ណាល័យនៃរាជបណ្ឌិត្យសភាកម្ពុជា |
| ១០-លោក កែន ធារិទ្ធ | មន្ត្រីវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម |
| ១១- លោក សន ពិសី | បុគ្គលិកស្ម័គ្រចិត្តនៅក្រុមប្រឹក្សាជាតិភាសាខ្មែរ |
| ១២- កញ្ញា ទិត ស៊ីណាត | បុគ្គលិកស្ម័គ្រចិត្តនៅក្រុមប្រឹក្សាជាតិភាសាខ្មែរ |
| ១៣- លោក អ៊ិយ វិចិត្រ | មន្ត្រីជាប់កិច្ចសន្យាក្រុមប្រឹក្សាជាតិភាសាខ្មែរ |

**ប្រការ២.**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ច រៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

នៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ [illegible] ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ប៊ិន ឈិន**

**កន្លែងទទួល ៖**

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រាជបណ្ណិត្យសភាកម្ពុជា
- ដូចប្រការ៤
- ឯកសារ កាលប្បវត្តិ

# II- សមិទ្ធផល
# នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ

## II.១- បច្ចេកសព្ទស្មើដោយគណៈកម្មការប្រវត្តិវិទ្យា

| | |
|---|---|
| **១- ប្រជាជាតិសហសុខុមាល**<br>អ. Commonwealth of Nations<br>បារ. Pays du Commonwealth | អង្គការអន្តររដ្ឋាភិបាលនិងមិនមែនរដ្ឋាភិបាលដែលបង្កើតឡើងដោយបណ្ដារដ្ឋនិងដែនដីទាំង៥៣ ភាគច្រើនជាអតីតអាណានិគមអង់គ្លេស ចាប់ពីពាក់កណ្ដាលសតវត្សរ៍ទី២០ តាមរយៈសេចក្ដីថ្លែងការណ៍ទីក្រុងឡុងដ៍ឆ្នាំ១៩៤៩។<br>ពាក្យ «សហសុខុមាល» ចេញមកពីពាក្យ «សហ» (Common) និង «សុខុមាលភាព»(Well-being)។ និមិត្តរូបនៃអង្គការនេះ គឺមហាក្សត្រី អេលីហ្សាបែតទី២ ដែលជាប្រមុខនៃប្រជាជាតិសហសុខុមាល។ សមាជិកនីមួយៗមិនមានកាតព្វកិច្ចផ្លូវច្បាប់ទៅលើសមាជិកដទៃទេ និងមានគោលនយោបាយការបរទេសផ្ទាល់ខ្លួន ប៉ុន្តែរួបរួមគ្នា ដោយសារភាសា ប្រវត្តិសាស្ត្រ វប្បធម៌ ប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងនីតិរដ្ឋ។ ប្រជាជាតិសហសុខុមាលគ្របដណ្ដប់លើទឹកដីជាង ២៩ ៩៥៨ ០៥០ គីឡូម៉ែត្រក្រឡា គឺ២០ភាគរយនៃផ្ទៃដីពិភពលោកទាំងមូល។<br> |
| **២- រដ្ឋឯករាជ្យសហសុខុមាល**<br>អ. Commonwealth of Independent States<br>បារ. Communauté d'États Indépendants | អង្គការអន្តររដ្ឋាភិបាលបង្កើតឡើងនៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៩១ ដោយសាធារណរដ្ឋចំនួន១២នៃអតីតសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត គឺ អាមេនី(Arménie) អាស៊ែបៃហ្សង់(Azerbaïdjan) បេឡារុស (Biélorussie) ហ្សកហ្ស៊ី(Georgie) កាហ្សាក់ស្ថាន(Kazakhstan) កៀហ្ស៊ីគីស្ថាន (Kirghizistan) ម៉ុលដាវី(Moldavie) អ៊ូសបេគីស្ថាន (Ouzbékistan) រុស្ស៊ី (Russie) តាហ្ស៊ីគីស្ថាន(Tadjikistan) តួកម៉េនីស្ថាន(Turkménistan) និងអ៊ុយក្រែន(Ukraine) ក្រោយពេលដួលរលំនៃសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត នៅឆ្នាំ១៩៩១។<br>សាធារណរដ្ឋចំនួន៣ទៀតនៃអតីតសហភាពសាធារណរដ្ឋសង្គមនិយមសូវៀតនៅសមុទ្របាល់ទិកមិនបានចូលរួមទេ គឺអេស្តូនី(Estonie) ឡេតូនី (Lettonie) និងលីទុយអានី(Lituanie)។ ហ្សកហ្ស៊ីបានដកខ្លួនចេញនៅឆ្នាំ២០០៩ បន្ទាប់ពីសង្គ្រាមនៅអូសេទីខាងត្បូង(Géorgie se retire en 2009 à la suite de la Guerre d'Ossétie du Sud)។ អ៊ុយក្រែនបានដកខ្លួន |

| | |
|---|---|
| | ចេញនៅឆ្នាំ២០១៤ បន្ទាប់ពីឯករាជ្យនៃគ្រីមេ (l'Ukraine annonce sa sortie de la CEI en 2014 à la suite de l'indépendance de la Crimée)។ ម៉ុងហ្គោលីជារដ្ឋសង្កេតការណ៍។ អង្គការនេះមានទីស្នាក់ការនៅទីក្រុងមីន(Minsk, Biélorussie) មានគោលបំណងធ្វើឱ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការផ្នែកពាណិជ្ជកម្ម ហិរញ្ញវត្ថុ និងសន្តិសុខតំបន់។<br> |
| **៣- សមាគតរដ្ឋ**<br>អ. Associated state<br>បារ. Etat associé | រដ្ឋអធិបតេយ្យ ដែលបានចុះហត្ថលេខាលើអនុសញ្ញាភាពជាដៃគូជាមួយរដ្ឋមួយដែលធំជាងឬមានប្រជាជនច្រើនជាង ហើយខ្លួនក្លាយជាសមាជិកដែលជាទូទៅរដ្ឋធំប្រគល់ដល់រដ្ឋតូចនូវអធិបតេយ្យភាពក្នុងកិច្ចការការពារជាតិ និងកិច្ចការបរទេស។ នៅក្នុងកិច្ចព្រមព្រៀង គេមិនប្រើពាក្យ «អាណាព្យាបាល»ទេ។<br>ឧទាហរណ៍ នៅក្នុងក្របខណ្ឌនៃសហភាពបារាំង (Union française) ឥណ្ឌូចិនបារាំង(កម្ពុជា ឡាវ កូសាំងស៊ីន អណ្ណាម និងតុងកឹង) មានសមាគតរដ្ឋចំនួន៣រួមគ្នាជាមួយបារាំង (ដែលមានតំណែងរដ្ឋមន្ត្រីខាងទំនាក់ទំនងជាមួយបណ្ដាសមាគតរដ្ឋពីឆ្នាំ១៩៥០ទៅ១៩៥៥)។ ប៉ុន្តែ តាមព្រឹត្តន័យ (ភាពជាក់ស្ដែង) ព្រះរាជាណាចក្រកម្ពុជាបានក្លាយជាសមាគតរដ្ឋពិតប្រាកដនៅខែវិច្ឆិកា ឆ្នាំ១៩៥៣ និងបានដកខ្លួនចេញពីសហភាពបារាំងក្រោយកិច្ចព្រមព្រៀងក្រុងហ្សឺណែវ នៅខែកក្កដា ឆ្នាំ១៩៥៤។<br> |

| | |
|---|---|
| **៤- អាណាព្យាបាល**<br>អ. Protectorate<br>បារ. Protectorat | របបកើតពីកិច្ចព្រមព្រៀង ដែលរដ្ឋពីរធ្វើការបែងចែកសមត្ថកិច្ចមិនស្មើគ្នា។ រដ្ឋអាណាព្យាបាល(Etat protecteur) ទទួលខុសត្រូវទាំងស្រុងក្នុងកិច្ចការអន្តរជាតិ។ រដ្ឋក្រោមអាណាព្យាបាល(Etat protégé) បន្តគ្រប់គ្រងរដ្ឋនៅក្រោមការត្រួតពិនិត្យពីរដ្ឋអាណាព្យាបាលនៅក្នុងរដ្ឋបាលមួយបែប ហៅថា «រដ្ឋបាលមិនផ្ទាល់» (Administration indirecte)។<br>ឧទាហរណ៍ នៅសម័យបារាំង(១៨៦៣-១៩៥៣) ប្រទេសបារាំងជារដ្ឋអាណាព្យាបាល ឯប្រទេសកម្ពុជាជារដ្ឋក្រោមអាណាព្យាបាល។ |
| **៥- រដ្ឋអាណាព្យាបាល**<br>អ. Protecting State<br>បារ. Etat Protecteur / Puissance protectrice | រដ្ឋដែលទទួលខុសត្រូវទាំងស្រុងក្នុងកិច្ចការអន្តរជាតិក្នុងឋានៈជាអ្នកតំណាងនៃរដ្ឋក្រោមអាណាព្យាបាល និងត្រួតពិនិត្យលើរដ្ឋបាលផ្ទៃក្នុងនៃរដ្ឋក្រោមអាណាព្យាបាល។<br>ឧទាហរណ៍ នៅសម័យអាណាព្យាបាលបារាំង ប្រទេសបារាំង ក្នុងឋានៈជារដ្ឋអាណាព្យាបាល ជាអ្នកតំណាងរដ្ឋាភិបាលកម្ពុជាក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនានាជាមួយរដ្ឋាភិបាលសៀមនៅឆ្នាំ១៩០៤ ដែលតម្រូវឱ្យសៀមប្រគល់មកឱ្យកម្ពុជានូវខេត្តម្លូព្រៃនិងទន្លេរពៅ ដែលមានប្រាសាទព្រះ-វិហារនៅក្នុងនោះ និងនៅឆ្នាំ១៩០៧ ដែលតម្រូវឱ្យសៀមប្រគល់មកឱ្យកម្ពុជានូវខេត្តសៀមរាប បាត់ដំបង និងសិរីសោភ័ណ។ នៅពេលដែលបារាំងប្រគល់ឯករាជ្យមកឱ្យកម្ពុជានៅឆ្នាំ១៩៥៣ ប្រទេសកម្ពុជាទទួលសិទ្ធិបន្តពីបារាំងដោយសារកិច្ចព្រមព្រៀងទាំងនោះនៅមានសុពលភាព (នៅជាធរមាន)ទាំងអស់ ដែលថៃ(មុនឆ្នាំ១៩៣៩ ហៅថា សៀម)ត្រូវតែទទួលស្គាល់ជាបន្ត។ |
| **៦- រដ្ឋក្រោមអាណាព្យាបាល**<br>អ. Protected State<br>បារ. Etat Protégé | រដ្ឋដែលបន្តការគ្រប់គ្រងរដ្ឋរបស់ខ្លួនតទៅទៀត តែស្ថិតនៅក្រោមការត្រួតពិនិត្យពីរដ្ឋអាណាព្យាបាលនៅក្នុងរដ្ឋបាលមួយបែប ហៅថា «រដ្ឋបាលមិនផ្ទាល់» (Administration indirecte)។<br>ឧទាហរណ៍ នៅសម័យអាណាព្យាបាលបារាំង នៅថ្នាក់ជាតិ ប្រទេសកម្ពុជាដែលជារដ្ឋក្រោមអាណាព្យាបាលត្រូវបានគ្រប់គ្រងដោយគណៈរដ្ឋមន្ត្រីមួយហៅថា កុងស៊ីយ៍សេនាបតី(Conseil des Ministres) ដែលមានមន្ត្រីជាន់ខ្ពស់៥រូប គឺអគ្គមហាសេនា យមរាជ ក្រឡាហោម ចក្រី និងវាំង។ នៅថ្នាក់ក្រោមជាតិ មានរដ្ឋបាលខ្មែរថ្នាក់ខេត្ត ស្រុក ឃុំ ដែលគ្រប់គ្រងដោយមន្ត្រីខ្មែរក្រោមការត្រួតពិនិត្យពីអាជ្ញាធរបារាំង។ ព្រះរាជប្រកាសចេញពីព្រះរាជាខ្មែរអាចចូលជាធរមានបញ្ញត្តិ(មានសុពលភាព)ទាល់តែមានការចុះហត្ថលេខាអមពីលោករេស៊ីដង់ជាន់ខ្ពស់បារាំង។ |

| | |
|---|---|
| |  |
| **៧- អាណានិគម**<br>អ. colony<br>បារ. colonie | ១- ទឹកដីដែលកាន់កាប់និងគ្រប់គ្រងផ្ទាល់ដោយមហាអំណាចបរទេសណាមួយ។<br>ឧទាហរណ៍ កូសាំងស៊ីន (នៅឥណ្ឌូចិន) ជាអាណានិគមរបស់បារាំង (នៅអឺរ៉ុប) ចាប់ពីឆ្នាំ១៨៥៩ដល់ឆ្នាំ១៩៤៩។<br>២- ទឹកដីកាន់កាប់និងគ្រប់គ្រងផ្ទាល់ដោយប្រជាជាតិមួយ ដែលនៅក្រៅពីព្រំដែនរបស់ខ្លួន និងនៅតែផ្សារភ្ជាប់ជាមួយមាតុជានី ដោយរក្សាទំនាក់ទំនងជិតស្និទ្ធខាងនយោបាយនិងសេដ្ឋកិច្ច។<br>ឧទាហរណ៍ អាណានិគមទាំង១៣នៅអាម៉េរិកខាងជើង។ |
| **៨- អាណានិគមទាំង១៣**<br>អ. The Thirteen colonies<br>បារ. Les Treize colonies | អាណានិគមចំនួន១៣ដែលបានផ្តាច់ខ្លួនចេញពីចក្រភពអង់គ្លេស ហើយដែលបានផ្តល់កំណើតដល់សហរដ្ឋអាម៉េរិក។<br>អាណានិគមទាំងនោះស្ថិតនៅឆ្នេរខាងកើតនៃទ្វីបអាម៉េរិកខាងជើង ដែលបានរួបរួមគ្នានៅឆ្នាំ១៧៧៥ និងបានចុះហត្ថលេខាលើសេចក្តីប្រកាសឯករាជ្យនៅឆ្នាំ១៧៧៦ ដើម្បីផ្តាច់ខ្លួនចេញពីចក្រភពអង់គ្លេស។ អាណានិគមទាំង១៣នោះ គឺវីហ្ស៊ីនី (Virginie) ម៉ាសាឈូសិត (Massachusetts) ញូវហេមស្ស៊ៀ (New Hampshire) ម៉េរីឡេន (Maryland) កូណិកទីកត់ (Connecticut) រ៉ូដអៃឡេន (Rhode Island) ដេលីវែរ (Delaware) ការ៉ូលីនខាងជើង |

| | |
|---|---|
| | (Caroline du Nord) ការ៉ូលីនខាងត្បូង(Caroline du Sud) ញូវហ្សើស៊ី (New Jersey) ញូវយ៉ក(New York) ផេនស៊ីលវ៉ានី(Pennsylvanie) និងហ្សកហ្ស៊ី (Géorgie)។   |
| **៩- មាតុជានី**<br>អ. Metropolis<br>បារ. Métropole | ដែនដីមួយជាស្នូលនៃបណ្តាដែនដីរបស់ខ្លួនដែលស្ថិតនៅខាងក្រៅឬនៅឯនាយសមុទ្រ។<br>ឧទាហរណ៍ ៖<br>- ប្រទេសបារាំងជាមាតុជានីនៃដែនដីឯនាយសមុទ្ររបស់ខ្លួន ដូចជា នូវែលកាឡេ ដូនី(Nouvelle-Calédonie) ប៉ូលីនេស៊ីបារាំង (la Polynésie française)។<br>- ចក្រភពអង់គ្លេសជាមាតុជានីនៃអាណានិគមទាំង១៣នៅអាម៉េរិកខាងជើងមុនឯករាជ្យនៃសហរដ្ឋអាម៉េរិកនៅឆ្នាំ១៧៧៦។<br>- បណ្ណសារឯនាយសមុទ្រ(Archives d'outre-mer) នៃឥណ្ឌូចិនបារាំងមានតម្កល់ទុកនៅឯទីក្រុងអិចហ្សង់ ប្រូវ៉ង់(Aix-en-Provence) នៅភាគខាងត្បូងប្រទេសបារាំងដែលស្ថិតក្នុងមាតុជានី។ |
| **១០- ពាក់កណ្តាលអាណានិគម**<br>អ. semi-colony<br>បារ. semi-colonie | ប្រទេសដែលមានឯករាជ្យខាងនយោបាយ(ខុសពីអាណានិគម) ប៉ុន្តែស្ថិតនៅក្រោមការគ្រប់គ្រងខាងសេដ្ឋកិច្ចពីប្រទេសចក្រពត្តិនិយមមួយឬច្រើន។<br>ឧទាហរណ៍ ប្រទេសចិន ជារដ្ឋពាក់កណ្តាលអាណានិគមនៅចុងសតវត្សរ៍ទី១៩ ដោយបណ្តាប្រទេសចក្រពត្តិនិយមដូចជា ចក្រភពអង់គ្លេស អាល្លឺម៉ង់ រុស្ស៊ី បារាំង និងជប៉ុន បានមកបែងចែកប្រទេសចិនជាតំបន់ឥទ្ធិពលរបស់គេ នៅសម័យនោះ។ |

<table>
<tr><td></td><td>



រូបកំប្លុកកំប្លែងខាងនយោបាយរបស់បារាំង ដែលបង្ហាញអំពីការបែងចែកប្រទេសចិន ដោយបណ្ដាមហាអំណាចបរទេស នៅចុងសតវត្សរ៍ទី១៩

</td></tr>
<tr><td>

**១១- ពាក់កណ្ដាលអាណានិគមនិយម**

អ. semi-colonialism

បារ. semi-colonialisme

</td><td>

ស្ថានភាពនៃបណ្ដារដ្ឋនៅចុងសតវត្សរ៍ទី១៩និងដើមសតវត្សរ៍ទី២០ ដែលត្រូវបានប្រទេសចក្រពត្តិនិយមដាក់(សម្ពាធ)បញ្ចូលប្រាក់មូលធនពាណិជ្ជកម្ម និងឥទ្ធិពលនយោបាយ ប៉ុន្តែនៅរក្សាឯករាជ្យរបស់ខ្លួនខាងគតិយុត្ត(តាមផ្លូវច្បាប់)។

ឧទាហរណ៍ ចិន ពែក្ស(អ៊ីរ៉ង់) សៀម អាហ្វហ្កានីស្ថាន យេម៉ែន និង អេត្យូពី ជាប្រទេសដែលស្ថិតក្នុងស្ថានភាពពាក់កណ្ដាលអាណានិគមនិយម នាចុងសតវត្សរ៍ទី១៩និងដើមសតវត្សរ៍ទី២០។

(ជាពាក្យដែលប្រើដោយ លោក ឡេនីន និងម៉ៅសេទុង)

</td></tr>
<tr><td>

**១២- អាណានិគមកម្ម**

អ. Colonization

បារ. colonisation

</td><td>

ការធ្វើអាជីវកម្មខាងផលប្រយោជន៍ដោយទាញយកនូវរូបធាតុដើម កម្លាំងពលកម្ម ទីតាំងយុទ្ធសាស្ត្រ កន្លែងរស់នៅ។ល។ ពីដែនដីមួយសម្រាប់ជាផលប្រយោជន៍ចំពោះមាតុភូមិរបស់ខ្លួនតាមរយៈរដ្ឋអំណាច ដែលយកពន្ធដារជួនកាលពីនិគមជន ជួនកាលពីក្រុមហ៊ុននានា ដែលធ្វើអាជីវកម្មលើធនធានរ៉ែឬធនធានផ្សេងទៀត។





ផែនទីបង្ហាញអំពីអាណានិគមកម្មនៅអាស៊ី ឆ្នាំ១៩១៤

</td></tr>
</table>

| | |
|---|---|
| **១៣- និរាណានិគមកម្ម**<br>អ. Decolonisation<br>បារ. Décolonisation | ដំណើរការដែលប្រទេសឬតំបន់ណាមួយជាទឹកដីអាណានិគមទទួលបានមកវិញនូវឯករាជ្យជាតិ។<br>និរាណានិគមកម្មបានចាប់ផ្តើមពីឆ្នាំ១៩៤៥។ ការចុះទន់ខ្សោយនៃបណ្តាមាតុជានីនៅទ្វីបអឺរ៉ុបបានអនុគ្រោះដល់បណ្តាចលនាជាតិនិយមក្នុងការទាមទារឯករាជ្យរបស់ខ្លួន។ ការប្រឆាំងរបស់សហរដ្ឋអាម៉េរិក និងរបស់សហភាពសាធារណរដ្ឋសង្គមនិយមសូវៀតចំពោះអាណានិគមកម្មនិងការបង្កើតអង្គការសហប្រជាជាតិ សុទ្ធតែជាសមាសធាតុអនុគ្រោះដល់ការរំដោះខ្លួននៃប្រជាជនដែលត្រូវគេត្រួតត្រា។ មិនដល់១ភាគ៤នៃសតវត្សរ៍ផង បណ្តាមាតុជានីនៅទ្វីបអឺរ៉ុប បានបាត់បង់អាណានិគមសឹងតែទាំងអស់។<br><br>ផែនទីឆ្នាំ១៩៤៥ មុននិរនិគមកម្ម |
| **១៤- សហភាពឥណ្ឌូចិន**<br>អ. Indochinese Union<br>បារ. Union indochinoise | សហភាពមួយដែលមានរដ្ឋចំនួន៥គឺ កម្ពុជា កូសាំងស៊ីន តុងកឹង ឡាវ និងអណ្ណាម នៅជ្រោយឥណ្ឌូចិន ដែលគ្រប់គ្រងដោយបារាំង។ ឈ្មោះជាផ្លូវការនៃសហភាពឥណ្ឌូចិននេះត្រូវបានបង្កើតឡើងនៅឆ្នាំ១៨៨៧ និងត្រូវជំនួសដោយឈ្មោះមួយថ្មីហៅថា«សហព័ន្ធឥណ្ឌូចិន» ចាប់ពីឆ្នាំ១៩៤៦ រហូតដល់ខែកក្កដា ឆ្នាំ១៩៥៤(កិច្ចព្រមព្រៀងក្រុងហ្សឺណែវស្តីពីការបញ្ចប់ ជម្លោះនៅឥណ្ឌូចិន Accords de Genève sur la cessation des hostilités en Indochine, juillet 1954)។ ឈ្មោះក្រៅផ្លូវការគឺឥណ្ឌូចិនបារាំង(Indochine Française)។ សហភាពឥណ្ឌូចិន មានអាណានិគមមួយឈ្មោះកូសាំងស៊ីន និង អាណាព្យាបាលចំនួនបួន គឺកម្ពុជា អាណ្ណាម(វៀតណាមកណ្តាល) តុងកឹង (វៀតណាមខាងជើង) និងឡាវ។ |




**១៥- ឥណ្ឌូចិនបារាំង**

អ. French Indochina

បារ. Indochine française

ទឹក ... ជាជន ច្រើនដ ... ឈ្មោះ ក្រៅផ្លូវការនៃទឹកដីអតីតចក្រភពអាណានិគមបារាំង ត្រូវបានគេហៅត្រឹមតែ «ឥណ្ឌូចិន» ដូចជា «សង្គ្រាមឥណ្ឌូចិន» លើកទី១(១៩៤៦-១៩៥៤) ជាដើម។ ឈ្មោះផ្លូវការគឺ សហភាពឥណ្ឌូចិន(១៨៨៧-១៩៤៦) និងសហព័ន្ធឥណ្ឌូចិន (១៩៤៦-១៩៥៤)។ បន្ថែមលើរដ្ឋទាំងប្រាំ(កូសាំងស៊ីន កម្ពុជា អណ្ណាម តុងកឹង និងឡាវ) ឥណ្ឌូចិនបារាំងគ្រប់គ្រងទឹកដីមួយផ្នែករបស់ចិន នៅក្នុងខេត្តក្វាងទុងសព្វថ្ងៃ គឺក្វាងចូវាន់(ឆកសមុទ្រក្វាងចូវ) ដែលបារាំងបានជួលពីចិន ពីឆ្នាំ១៨៩៨ ដល់១៩៤៥។




**១៦- សហភាពបារាំង**

អ. French Union

បារ. Union française

អង្គការនយោបាយនៃប្រទេសបារាំងនិងចក្រភពអាណានិគមរបស់ខ្លួនដែលត្រូវបានបង្កើតឡើងដោយរដ្ឋធម្មនុញ្ញសាធារណរដ្ឋទី៤ និងនៅក្នុងនោះមានមាតុជានី ទឹកដីឯនាយសមុទ្រ(អតីតអាណានិគម ចាប់ពីឆ្នាំ១៩៤៦) និង

<table>
<tr><td></td><td>សមាគតរដ្ឋ(អតីតអាណាព្យាបាល ចាប់ពីឆ្នាំ១៩៤៩)។ សាធារណរដ្ឋទី៤ជារបបសាធារណរដ្ឋបារាំង ពីឆ្នាំ១៩៤៦ដល់១៩៥៨ បន្ទាប់ពីពេលរំដោះប្រទេសបារាំងពីការកាន់កាប់របស់អាល្លឺម៉ង់សម័យណាស៊ីពីឆ្នាំ១៩៤១ដល់១៩៤៥។




រូបសញ្ញាសហភាពបារាំងឆ្នាំ១៩៤៦ និងប្រាក់១ប្យាសសហព័ន្ធឥណ្ឌូចិន</td></tr>
<tr><td>១៧- ឥណ្ឌូចិន<br>អ. Indochina<br>បារ. Indochine</td><td>ឧបទ្វីបមួយនៃទ្វីបអាស៊ី ស្ថិតនៅខាងត្បូងប្រទេសចិន និងខាងកើតប្រទេសឥណ្ឌា ដែលនៅក្នុងនោះមានប្រទេសកម្ពុជា វៀតណាម ឡាវ ថៃ ភូមា និងជ្រោយមលក្កា។<br>ពាក្យឥណ្ឌូចិន ត្រូវគេសម្គាល់ជារឿយៗថាជាទឹកដីអតីតចក្រភពអាណានិគមបារាំង ដែលមានរដ្ឋចំនួន៥(កូសាំងស៊ីន កម្ពុជា អណ្ណាម តុងកឹង និងឡាវ)។ ជួនកាល គេប្រើពាក្យ«ឥណ្ឌូចិនអង់គ្លេស» (Indochine britannique) ដើម្បីសម្គាល់ប្រទេសភូមាសម័យអាណានិគម។


</td></tr>
<tr><td>១៨- បដិវត្តន៍ខែសីហា<br>អ. August Revolution<br>បារ. Révolution d’Août</td><td>បណ្ដាព្រឹត្តិការណ៍ដែលបានកើតឡើងនៅភាគខាងជើងវៀតណាម បន្ទាប់ពីពលប្រហាររបស់ជប៉ុននៅឥណ្ឌូចិន នាថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៤៥ រហូតដល់ការប្រកាសឯករាជ្យនៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៤៥ នៅទីក្រុងហាណូយ និង</td></tr>
</table>

<table>
<tr>
<td></td>
<td>ការប្រកាសបង្កើតសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម។<br>ព្រឹត្តិការណ៍ទាំងនេះបានប្រព្រឹត្តទៅជាពិសេស នៅភាគខាងជើងវៀតណាម ពីតំបន់ព្រំដែនចិនវៀតណាម(កាវបាងនិងឡាងសឺន)ទៅដល់ក្រុងហាណូយ និងហាយហ្វុង។ បដិវត្តន៍នេះបាននាំឱ្យវៀតមិញឡើងកាន់អំណាច និងជាចំណុចផ្តើមមួយនៃសង្គ្រាមឥណ្ឌូចិនលើកទី១។<br>
</td>
</tr>
<tr>
<td>១៩- សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម<br>អ. Democratic Republic of Vietnam<br>បារ. République Démocratique du Vietnam</td>
<td>រដ្ឋមួយនៅឧបទ្វីបឥណ្ឌូចិន ដែលគេហៅជាទូទៅថា«វៀតណាមខាងជើង» និងមានអត្ថិភាពពីឆ្នាំ១៩៤៥ដល់ឆ្នាំ១៩៧៦ ជាឆ្នាំដែលត្រូវបានប្តូរឈ្មោះមកជាសាធារណរដ្ឋសង្គមនិយមវៀតណាម បន្ទាប់ពីវៀតណាមខាងជើងច្បាំងឈ្នះវៀតណាមខាងត្បូងនៅឆ្នាំ១៩៧៥។ លោក ហូ ជីមិញ ដែលជាមេដឹកនាំបដិវត្តន៍វៀតណាមបានប្រកាសឯករាជ្យ នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៤៥ នៅទីក្រុងហាណូយ និងបានប្រកាសបង្កើតសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម។<br>ប្រទេសបារាំងដែលបានបង្កើត«រដ្ឋវៀតណាម» (កូសាំងស៊ីន អណ្ណាម និងតុងកឹង)នៅឆ្នាំ១៩៤៩នោះ មិនបានទទួលស្គាល់ឯករាជ្យនេះទេ។ សង្គ្រាមឥណ្ឌូចិនលើកទី១(បារាំងច្បាំងនឹងវៀតមិញ) ដែលបានផ្ទុះឡើងនៅឆ្នាំ១៩៤៦ នោះ ត្រូវបានបញ្ចប់ដោយកិច្ចព្រមព្រៀងក្រុងហ្សឺណែវឆ្នាំ១៩៥៤ ដែលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមជាភាគីមួយនៅក្នុងនោះ។</td>
</tr>
<tr>
<td>២០- រដ្ឋវៀតណាម<br>អ. State of Vietnam<br>បារ. L’Etat du Vietnam</td>
<td>រដ្ឋមួយនៅឧបទ្វីបឥណ្ឌូចិន ដែលបង្កើតដោយបារាំងនៅឆ្នាំ១៩៤៩ដោយមានការបញ្ចូលគ្នារវាងកូសាំងស៊ីន(ក្រុងព្រៃនគរ) អណ្ណាម(ក្រុងវ៉េ)និងតុងកឹង(ក្រុងហាណូយ) និងជាសមាគតរដ្ឋនៃសហភាពបារាំង(១៩៤៩-១៩៥៤)។</td>
</tr>
</table>

| | |
|---|---|
| | ប៉ុន្តែ ក្នុងបរិការណ៍នៃសង្គ្រាមត្រជាក់ លោក ហូ ជីមិញ បានប្រកាសឯករាជ្យភាគខាងជើងវៀតណាម នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៤៥ នៅទីក្រុងហាណូយ និងបានប្រកាសបង្កើតសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម។<br>នៅក្នុងសន្និសីទក្រុងហ្សឺណែវឆ្នាំ១៩៥៤ វៀតណាមមានពីរភាគីទៅចូលរួមគឺ រដ្ឋវៀតណាម(គាំទ្រដោយបារាំង) និងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម(គាំទ្រដោយចិននិងសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត)។ |
| **២១- សង្គ្រាមកូរ៉េ**<br>អ. Korean War<br>បារ. Guerre de Corée | សង្គ្រាមពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៥០ដល់ថ្ងៃទី២៧ ខែកក្កដាឆ្នាំ១៩៥៣ រវាងសាធារណរដ្ឋកូរ៉េ(កូរ៉េខាងត្បូង) និងសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ(កូរ៉េខាងជើង)។ នៅក្នុងសង្គ្រាមនេះ កូរ៉េខាងត្បូងមានការគាំទ្រពីអ.ស.ប.ដែលមានស.រ.អា.ជាកម្លាំងធំជាងគេ និងនៅពេលដែលសាធារណរដ្ឋប្រជាមានិតចិនមិនទាន់ចូលជាសមាជិកនៅឡើយ។ កូរ៉េខាងជើងមានការគាំទ្រពីសាធារណរដ្ឋប្រជាមានិតចិននិងសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត។ ប្រទេសជប៉ុនបានគ្រប់គ្រងឧបទ្វីបកូរ៉េពីឆ្នាំ១៩១០រហូតដល់សង្គ្រាមលោកលើកទី២។ បន្ទាប់ពីបរាជ័យនៃសង្គ្រាមប្រទេសជប៉ុននៅខែកញ្ញា ឆ្នាំ១៩៤៥ នោះ សហរដ្ឋអាម៉េរិកនិងសហភាពសាធារណរដ្ឋសង្គមនិយមសូវៀតបានចែកគ្នាកាន់កាប់ឧបទ្វីបកូរ៉េនៅសងខាងខ្សែស្របទី៣៨នៃអឌ្ឍគោលខាងជើងដោយកងកម្លាំងអាម៉េរិកកាន់កាប់ខាងត្បូងនិងកងកម្លាំងសូវៀតកាន់កាប់ខាងជើង។<br> |
| **២២- សន្និសីទក្រុងហ្សឺណែវ ឆ្នាំ១៩៥៤**<br>អ. Geneva Conference | សន្និសីទដែលបានប្រព្រឹត្តទៅចន្លោះពីថ្ងៃទី២៦ ខែមេសាដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៥៤ នៅក្រុងហ្សឺណែវ ប្រទេសស្វីស ដើម្បីដោះស្រាយបញ្ហាសង្គ្រាមកូរ៉េ និងស្ដាបនាសន្តិភាពនៅឥណ្ឌូចិនឡើងវិញ(ដើម្បីបញ្ចប់សង្គ្រាម |

of 1954
បារ. Conférence de Genève de 1954

ឥណ្ឌូចិនលើកទី១)។ អ្នកតំណាងនៃ៥ប្រទេស ដែលបានចូលរួមពីដើមដល់ចប់នោះមកពីសហរដ្ឋអាម៉េរិក សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត ចក្រភពអង់គ្លេស សាធារណរដ្ឋប្រជាមានិតចិន និងបារាំង។

ចំណែកអ្នកតំណាងនៃប្រទេសដទៃទៀតបានមកចូលរួមតែក្នុងកិច្ចពិភាក្សាលើបញ្ហាដែលពាក់ព័ន្ធប៉ុណ្ណោះ។ សម្រាប់បញ្ហាកូរ៉េ មានអ្នកតំណាងកូរ៉េខាងត្បូងនិងកូរ៉េខាងជើងបានចូលរួម។ សម្រាប់បញ្ហាឥណ្ឌូចិន មានអ្នកតំណាងប្រទេសកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម រដ្ឋវៀតណាម និងឡាវបានចូលរួម។ ការពិភាក្សាលើជម្លោះឥណ្ឌូចិនបានចាប់ផ្តើមនៅថ្ងៃទី៨ ខែឧសភា គឺមួយថ្ងៃបន្ទាប់ពីបារាំងច្បាំងចាញ់វៀតមិញនៅដៀនបៀនភូ។ សន្និសីទនេះបានបញ្ចប់ទៅដោយគ្មានកិច្ចព្រមព្រៀង(បរាជ័យ)ស្តីពីបញ្ហាកូរ៉េ តែបានឈានដល់កិច្ចព្រមព្រៀងស្តីពីឥណ្ឌូចិនដែលហៅថាកិច្ចព្រមព្រៀងក្រុងហ្សឺណែវ។




**២៣- សន្និសីទក្រុងហ្សឺណែវស្តីពីកូរ៉េ**
អ. Geneva Conference on Korea
បារ. Conférence de Genève sur la Corée

សន្និសីទដែលបានប្រព្រឹត្តទៅចន្លោះពីថ្ងៃទី២៦ ខែមេសាដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៥៤ នៅទីក្រុងហ្សឺណែវ ប្រទេសស្វ៊ីស ដើម្បីដោះស្រាយបញ្ហាសង្គ្រាមកូរ៉េ។ សន្និសីទនេះបានបញ្ចប់ទៅដោយគ្មានកិច្ចព្រមព្រៀងអ្វីឡើយ។ ក្នុងចំណោមបុព្វហេតុនៃបរាជ័យនោះមាន៖ អ្នកតំណាងកូរ៉េខាងត្បូងបានស្នើថា រដ្ឋាភិបាលកូរ៉េខាងត្បូង ជារដ្ឋាភិបាលពេញច្បាប់តែមួយគត់នៅកូរ៉េថា ការបោះឆ្នោតក្រោមការត្រួតពិនិត្យពីអ.ស.ប.នឹងត្រូវធ្វើនៅកូរ៉េខាងជើងថាកងទ័ពចិនត្រូវដកចេញនិងថាកងកម្លាំងអ.ស.ប. (ជាភាគីប្រយុទ្ធក្នុងសង្គ្រាមនោះ) នឹងត្រូវស្ថិតនៅជាកម្លាំងនគរបាល។ អ្នកតំណាងកូរ៉េខាងជើងបានស្នើថា ការបោះឆ្នោតនឹងត្រូវធ្វើទូទាំងប្រទេសកូរ៉េ កងកម្លាំងបរទេសទាំងអស់ត្រូវដកចេញនៅពេលឆាប់ៗ ថាការបោះឆ្នោតត្រូវរៀបចំដោយគណៈកម្មការកូរ៉េទាំងស្រុងដែលមានចំនួនស្មើគ្នាពីកូរ៉េខាងជើងនិងខាងត្បូង ដើម្បីបង្កើនទំនាក់ទំនងខាងសេដ្ឋកិច្ច និងវប្បធម៌ រវាងកូរ៉េទាំងពីរ។ នេះជាបុព្វហេតុមួយចំនួន ដែលនាំឱ្យ

| | |
|---|---|
| | សន្ធិសីទខាងលើបរាជ័យ។ |
| **២៤- កិច្ចព្រមព្រៀងក្រុងហ្សឺណែវស្ដីពីឥណ្ឌូចិន**<br>អ. Geneva Accords on Indochina<br>បារ. Accords de Genève sur l'Indochine | កិច្ចព្រមព្រៀងចំនួន៣ស្ដីពីការបញ្ចប់ប្រទូសរ៉ាយភាពនៅកម្ពុជា នៅឡាវ និងនៅវៀតណាម ដែលត្រូវបានចុះហត្ថលេខានៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៥៤ នៅក្រុងហ្សឺណែវ ប្រទេសស្វ៊ីស ដើម្បីស្ដាបនាសន្តិភាពនៅឥណ្ឌូចិនឡើងវិញ និងដើម្បីបញ្ចប់សង្គ្រាមឥណ្ឌូចិនលើកទី១(ឆ្នាំ១៩៤៦-១៩៥៤)។ |
| **២៥- កិច្ចព្រមព្រៀងក្រុងហ្សឺណែវស្ដីពីការបញ្ចប់ប្រទូសរ៉ាយភាពនៅកម្ពុជា**<br>អ. Geneva Accord on the Cessation of Hostilities in Cambodia,<br>បារ. Accord de Genève sur la cessation des hostilités au Cambodge | កិច្ចព្រមព្រៀងក្រុងហ្សឺណែវ (មាន៥ជំពូកនិង៣៣មាត្រា) ដែលមានភាគីកម្ពុជានិងភាគីពាក់ព័ន្ធដទៃទៀតចូលរួមចុះហត្ថលេខានៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៥៤ និងចូលជាធរមាននៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៥៤។<br>កិច្ចព្រមព្រៀងនេះ មានចែងជាអាទិ៍អំពី៖<br>- គោលការណ៍និងលក្ខខណ្ឌអនុវត្តការឈប់បាញ់គ្នា<br>- នីតិវិធីនៃការដកកងកម្លាំងប្រដាប់អាវុធបរទេសចេញពីទឹកដីកម្ពុជា<br>- កងកម្លាំងប្រដាប់អាវុធខ្មែរដែលមានដើមកំណើតនៅកម្ពុជា និងបម្រាមមិនឱ្យបញ្ចូលកងទ័ពថ្មី បុគ្គលិកយោធា សព្វាវុធនិងគ្រាប់រំសេវ និងមូលដ្ឋានយោធា<br>- គណៈកម្មការចម្រុះត្រួតពិនិត្យអន្តរជាតិ<br>- ការអនុវត្តកិច្ចព្រមព្រៀង។ |
| **២៦- បទឈប់បាញ់គ្នានៅកម្ពុជាតាមកិច្ចព្រមព្រៀងក្រុងហ្សឺណែវ**<br>អ. Cease-fire in Cambodia by virtue of Geneva Accord<br>បារ. Cessez-le-feu au Cambodge en vertu de l'Accord de Genève | បទបញ្ញត្តិដែលមានចែងនៅក្នុងជំពូក១នៃកិច្ចព្រមព្រៀងក្រុងហ្សឺណែវស្ដីពីការបញ្ចប់ប្រទូសរ៉ាយភាពនៅកម្ពុជា ដែលក្នុងនោះ ភាគីក្នុងជម្លោះនៅកម្ពុជាព្រមព្រៀងគ្នាថា ការឈប់បាញ់គ្នាទូទាំងកម្ពុជាទាំងស្រុង និងជំណាលគ្នានឹងត្រូវអនុវត្តនៅម៉ោង៨ព្រឹក(ម៉ោងក្នុងស្រុក) នៅថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៥៤។<br>មានការឯកភាពគ្នាថា ម៉ោងក្នុងស្រុក យកតាមម៉ោងនៅប៉េកាំង ដែលមានចែងនៅក្នុងជំពូក១ស្ដីពីគោលការណ៍និងលក្ខខណ្ឌអនុវត្តការឈប់បាញ់គ្នា។ |
| **២៧ - ការដកកងកម្លាំងប្រដាប់អាវុធបរទេសចេញពីទឹកដីកម្ពុជាតាមកិច្ចព្រមព្រៀងក្រុងហ្សឺណែវ**<br>អ. Withdrawal of Foreign | បទបញ្ញត្តិដែលមានចែងក្នុងមាត្រា៤ ជំពូក២នៃកិច្ចព្រមព្រៀងក្រុងហ្សឺណែវស្ដីពីការបញ្ចប់ប្រទូសរ៉ាយភាពនៅកម្ពុជា ដែលចែងជាអាទិ៍ថា ការដកចេញពីទឹកដីកម្ពុជានឹងត្រូវអនុវត្តចំពោះ៖<br>១- កងកម្លាំងប្រដាប់អាវុធនិងបុគ្គលិកយោធាប្រយុទ្ធនៃសហភាពបារាំង។<br>២- អង្គភាពប្រយុទ្ធគ្រប់ប្រភេទដែលបានចូលមកក្នុងទឹកដីកម្ពុជាពីបណ្ដាប្រទេសដទៃឬពីបណ្ដាតំបន់នៃឧបទ្វីប។ |

| | |
|---|---|
| Armed Forces from the territory of Cambodia by virtue of Geneva Accord<br>បារ. Retrait des forces armées étrangères du territoire du Cambodge en vertu de l'Accord de Genève | ៣- យុទ្ធជនបរទេសទាំងអស់(ឬជនជាតិខ្មែរ ដែលមិនកើតនៅកម្ពុជា) នៅក្នុងអង្គភាពយោធាណាក៏ដោយឬមានមុខងារគ្រប់គ្រងនៅក្នុងរាល់អង្គការនយោបាយឬយោធា រដ្ឋបាល សេដ្ឋកិច្ច ហិរញ្ញវត្ថុ ឬសង្គមកិច្ច ដែលបានធ្វើការដោយមានទំនាក់ទំនងជាមួយនឹងអង្គភាពយោធាវៀតណាម។ |
| **២៨- កងកម្លាំងប្រដាប់អាវុធខ្មែរតាមកិច្ចព្រមព្រៀងក្រុងហ្សឺណែវ**<br>អ. Khmer Armed Forces by virtue of Geneva Accord<br>បារ. Forces Armées Khmères en vertu de l'Accord de Genève | បទបញ្ញត្តិដែលមានចែងក្នុងមាត្រា៥ ជំពូក៣នៃកិច្ចព្រមព្រៀងក្រុងហ្សឺណែវស្តីពីការបញ្ចប់ប្រទូសរ៉ាយភាពនៅកម្ពុជា ដែលចែងថា ភាគីទាំងពីរសន្យាថា ក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីបទបញ្ជានៃបទឈប់បាញ់គ្នាត្រូវបានប្រកាសនោះ កងកម្លាំងតស៊ូខ្មែរ(ខ្មែរឥស្សរៈ)ត្រូវរំសាយនៅនឹងកន្លែង ហើយក្នុងពេលជំណាលគ្នានោះ ទាហាននៃកងយោធពលខេមរភូមិន្ទនឹងមិនធ្វើសកម្មភាពប្រទូសរ៉ាយនឹងកងកម្លាំងតស៊ូខ្មែរឡើយ។<br>តាមសេចក្តីប្រកាសរបស់គណៈប្រតិភូកម្ពុជា នៅឯសន្និសីទក្រុងហ្សឺណែវ រាជរដ្ឋាភិបាលកម្ពុជាដែលមានបំណងធានានូវសុខដុមភាពក្នុងចំណោមប្រជាជននៃព្រះរាជាណាចក្រនោះ ប្តេជ្ញាថានឹងចាត់វិធានការចាំបាច់ដើម្បីធ្វើសមាហរណកម្មប្រជាពលរដ្ឋទាំងអស់ ទៅក្នុងសហគមន៍ជាតិដោយគ្មានការរើសអើង ជានាផ្តល់នូវសិទ្ធិនិងសេរីភាពដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និងអះអាងថា ប្រជាពលរដ្ឋទាំងអស់អាចចូលរួមដោយសេរី ជាអ្នកបោះឆ្នោតឬជាបេក្ខជនក្នុងការបោះឆ្នោតសកលដោយសម្ងាត់(មាត្រា៦)។ |
| **២៩- អព្យាក្រឹតភាពកម្ពុជាតាមកិច្ចព្រមព្រៀងក្រុងហ្សឺណែវ**<br>អ. Cambodian neutrality by virtue of Geneva Accord<br>បារ. Neutralité du Cambodge en vertu de l'Accord de Genève | អព្យាក្រឹតភាពដែលជាបទបញ្ញត្តិមានចែងក្នុងមាត្រា៧ ជំពូក៣នៃកិច្ចព្រមព្រៀងក្រុងហ្សឺណែវស្តីពីការបញ្ចប់ប្រទូសរ៉ាយភាពនៅកម្ពុជា ដែលមានខ្លឹមសារថា ដោយអនុលោមតាមសេចក្តីប្រកាសរបស់គណៈប្រតិភូកម្ពុជា នៅម៉ោង ២៤:០០ នាថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៥៤ នៅឯសន្និសីទក្រុងហ្សឺណែវនៃថ្នាក់រដ្ឋមន្ត្រីការបរទេសនោះ *«រាជរដ្ឋាភិបាលកម្ពុជានឹងមិនចូលរួមក្នុងកិច្ចព្រមព្រៀងណាមួយជាមួយប្រទេសដទៃឡើយ ប្រសិនបើ កិច្ចព្រមព្រៀងនេះតម្រូវឱ្យកម្ពុជាចូលទៅក្នុងសម្ព័ន្ធភាពយោធាមួយ ដែលមិនស្របនឹងគោលការណ៍នៃធម្មនុញ្ញសហប្រជាជាតិឬគោលការណ៍នៃកិច្ចព្រមព្រៀងស្តីពីការបញ្ចប់ប្រទូសរ៉ាយភាព ឬដរាបណាសន្តិសុខរបស់ខ្លួនមិនត្រូវបានគំរាមកំហែងនោះ ឬក៏តម្រូវ ឱ្យបង្កើតមូលដ្ឋាននៅលើទឹកដីកម្ពុជាសម្រាប់កងកម្លាំងយោធាមហាអំណាចបរទេស។ល។»* |

| | |
|---|---|
| | - កិច្ចព្រមព្រៀងនេះ មានចែងក្នុងជំពូក៣ស្តីពីបម្រាមមិនឱ្យបញ្ចូលកងទ័ពថ្មី បុគ្គលិកយោធា សព្វាវុធនិងគ្រាប់រំសេវ និងមូលដ្ឋានយោធា។<br>- ដោយផ្អែកលើកិច្ចព្រមព្រៀងនេះ អញ្ញាក្រឹតភាពកម្ពុជាត្រូវបានបង្កើតឡើងដោយច្បាប់ធម្មនុញ្ញថ្ងៃទី១២ ខែមករា ឆ្នាំ១៩៥៧។ |
| **៣០- គណៈកម្មការត្រួតពិនិត្យអន្តរជាតិនៅកម្ពុជា តាមកិច្ចព្រមព្រៀងក្រុងហ្សឺណែវ**<br>អ. International Control Commission in Cambodia by virtue of Geneva Accord<br>បារ. Commission Internationale de Contrôle au Cambodge en vertu de l'Accord de Genève | គណៈកម្មការអន្តរជាតិដែលត្រូវបានបង្កើតឡើងតាមបទបញ្ញត្តិមានចែងក្នុងមាត្រា១១ មាត្រា១២ និងមាត្រា១៣ ក្នុងជំពូក៤នៃកិច្ចព្រមព្រៀងក្រុងហ្សឺណែវស្តីពីការបញ្ចប់ប្រទូសរ៉ាយភាពនៅកម្ពុជា ដើម្បីទទួលបន្ទុកក្នុងការឃ្លាំមើលនិងត្រួតពិនិត្យការអនុវត្តបទបញ្ញត្តិនៃកិច្ចព្រមព្រៀងស្តីពីការបញ្ចប់ប្រទូសរ៉ាយភាពនៅក្នុងប្រទេសកម្ពុជា។<br>សមាសភាពនៃគណៈកម្មការនេះ មានអ្នកតំណាងនៃរដ្ឋដូចតទៅៈ កាណាដា ឥណ្ឌា និងប៉ូឡូញ។ គណៈកម្មការនេះនឹងដឹកនាំដោយអ្នកតំណាងប្រទេសឥណ្ឌានិងមានទីស្នាក់ការកណ្តាលនៅភ្នំពេញ(មាត្រា១១)។<br>គណៈកម្មការអន្តរជាតិនេះនឹងបង្កើតក្រុមអធិការកិច្ចអចល័ត និងចល័តដែលមានសមាសភាពចំនួនស្មើគ្នានៃមន្ត្រីដែលចាត់តាំងដោយរដ្ឋនីមួយៗដូចមានចែងខាងលើ។ ក្រុមអចល័តនឹងមានទីស្នាក់ការនៅចំណុចដូចតទៅៈ ភ្នំពេញ កំពង់ចាម ក្រចេះ ស្វាយរៀង កំពត។ ចំណុចនៃទីតាំងទាំងនេះអាចផ្លាស់ប្តូរនៅថ្ងៃក្រោយដោយកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជា និងគណៈកម្មការអន្តរជាតិ(មាត្រា១២)។<br>មុខងារនៃគណៈកម្មការនេះផ្តោតជាពិសេសលើៈ ការត្រួតពិនិត្យលើការដកកងកម្លាំងបរទេសស្របតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀងស្តីពីការបញ្ចប់ប្រទូសរ៉ាយភាពនិងមើលឱ្យច្បាស់ថាព្រំដែនត្រូវបានគេគោរព ព្រមទាំងត្រួតពិនិត្យការដោះលែងឈ្លើយសឹកនិងជនស៊ីវិលដែលជាប់ពន្ធនាគារ។ល។ |
| **៣១- ការអនុវត្តកិច្ចព្រមព្រៀងក្រុងហ្សឺណែវនៅកម្ពុជា**<br>អ. Implementation of Geneva Accord in Cambodia<br>**បារ.** Exécution de l'Accord de Genève au Cambodge | ការអនុវត្តដែលមានចែងជាបទបញ្ញត្តិក្នុងមាត្រា៣១ ជំពូក៥នៃកិច្ចព្រមព្រៀងក្រុងហ្សឺណែវស្តីពីការបញ្ចប់ប្រទូសរ៉ាយភាពនៅកម្ពុជា ដែលតម្រូវឱ្យបណ្តាហត្ថលេខីនៃកិច្ចព្រមព្រៀងនេះនិងអ្នកបន្តក្នុងមុខងាររបស់ខ្លួន ទទួលខុសត្រូវចំពោះការគោរពនិងការដាក់ជាធរមាននូវខទាំងឡាយនិងបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ហើយមេបញ្ជាការកងទ័ពនៃភាគីទាំងពីរនឹងធ្វើការសម្របសម្រួលជាចាំបាច់ដើម្បីធានាការអនុវត្តពេញលេញនូវបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះដោយបុគ្គលិកយោធាទាំងអស់ដែលនៅក្រោមបញ្ជារបស់ពួកគេ។ |
| **៣២- កិច្ចព្រមព្រៀងក្រុងហ្សឺណែវស្តីពីការបញ្ចប់ប្រទូសរ៉ាយភាព** | កិច្ចព្រមព្រៀងក្រុងហ្សឺណែវ(មាន៧ជំពូកនិង៤១មាត្រា)ដែលមានភាគីឡាវនិងភាគីពាក់ព័ន្ធដទៃទៀតចូលរួមចុះហត្ថលេខានៅថ្ងៃទី២០ខែកក្កដា ឆ្នាំ១៩៥៤ និងចូលជាធរមាននៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៥៤ (ម៉ោង២៤ ម៉ោងនៅ |

<table>
<tr>
<td>
នៅឡាវ<br>
អ. Geneva Accord on the Cessation of Hostilities in Laos,<br>
បារ. Accord de Genève sur la cessation des hostilités au Laos
</td>
<td>
ក្រុងហ្សឺណែវ)។<br>
កិច្ចព្រមព្រៀងនេះ មានចែងជាអាទិ៍ថា ទម្រាំដល់ពេលមានដំណោះស្រាយនយោបាយ បណ្ដាអង្គភាពប្រយុទ្ធនៃ«ប៉ាថេតឡាវ»(Pathet Lao)ដែលបានស្នាក់នៅតាមបណ្ដាតំបន់ប្រមូលផ្ដុំបណ្ដោះអាសន្ននោះ នឹងត្រូវទៅនៅក្នុងខេត្តផុងសាលី និងសាមនឿ លើកលែងតែបុគ្គលិកយោធាណាដែលចង់រំសាយនៅនឹងកន្លែង(មាត្រា១៤)។<br>
បញ្ហាប្រទេសឡាវត្រូវបានយកទៅដោះស្រាយម្ដងទៀតនៅឯសន្និសីទក្រុងហ្សឺណែវពីខែឧសភា ឆ្នាំ១៩៦១ដល់ខែកក្កដា ឆ្នាំ១៩៦២ ដែលមានសម្ដេចព្រះប្រមុខរដ្ឋ នរោត្តម សីហនុ ជាប្រធានសន្និសីទ។<br>
«ប៉ាថេតឡាវ» ជាអង្គការ និងចលនានយោបាយកុម្មុយនីស្តនៅប្រទេសឡាវដែលត្រូវបានបង្កើតឡើងនៅពាក់កណ្ដាលសតវត្សរ៍ទី២០ ហើយបានឡើងកាន់អំណាចនៅឆ្នាំ១៩៧៥ បន្ទាប់ពីសង្គ្រាមស៊ីវិលនៅប្រទេសឡាវ។<br>


</td>
</tr>
<tr>
<td>
៣៣- កិច្ចព្រមព្រៀងក្រុងហ្សឺណែវស្ដីពីការបញ្ចប់ប្រទូសរ៉ាយភាពនៅវៀតណាម<br>
អ. Geneva Accord on the Cessation of Hostilities in Vietnam,<br>
បារ. Accord de Genève sur la cessation des hostilités au Vietnam
</td>
<td>
កិច្ចព្រមព្រៀងក្រុងហ្សឺណែវ(មាន៦ជំពូកនិង៤៧មាត្រា) ដែលមានភាគីវៀតណាម និងភាគីពាក់ព័ន្ធដទៃទៀតចូលរួមចុះហត្ថលេខានៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៥៤ និងចូលជាធរមាននៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៥៤ (ម៉ោង២៤ ម៉ោងនៅក្រុងហ្សឺណែវ)។<br>
កិច្ចព្រមព្រៀងនេះ មានចែងជាអាទិ៍ថា ខ្សែព្រំដែនយោធាបណ្ដោះអាសន្នមួយនឹងកំណត់ឱ្យកងកម្លាំងនៃភាគីទាំងពីរត្រូវប្រមូលផ្ដុំនៅសងខាងនៃខ្សែនេះ បន្ទាប់ពីការដកថយរបស់ខ្លួន ដោយកងកម្លាំងនៃយោធាប្រជាជនវៀតណាមនៅខាងជើងខ្សែព្រំដែន ឯកងកម្លាំងនៃសហភាពបារាំងនៅខាងត្បូង(មាត្រា១)។<br>
តាមរយៈកិច្ចព្រមព្រៀងនេះ ប្រទេសវៀតណាមត្រូវបានបែងចែកជាពីរតាមខ្សែស្របទី១៧(វៀតណាមខាងជើងកុម្មុយនីស្ត ឯវៀតណាមខាងត្បូងសេរី)។
</td>
</tr>
</table>

<table>
<tr><td></td><td>
</td></tr>
<tr><td>៣៤- អវសានកិច្ចនៃសន្និសីទក្រុងហ្សឺណែវ ស្តីពីឥណ្ឌូចិន<br>អ. Final Act of the Geneva Conference on Indochina<br>បារ. Acte final de la Conférence de Genève sur l'Indochine</td><td>ឯកសារចុងក្រោយនៃសន្និសីទក្រុងហ្សឺណែវ ដែលបានប្រព្រឹត្តទៅពីថ្ងៃទី២៦មេសាដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៥៤ នៅទីក្រុងហ្សឺណែវនៃប្រទេសស្វ៊ីស ដើម្បីស្តាបនាសន្តិភាពនៅឥណ្ឌូចិនឡើងវិញ(ដើម្បីបញ្ចប់សង្គ្រាមឥណ្ឌូចិនលើកទី១) ដែលមានអ្នកតំណាងនៃប្រទេសចំនួន៩បានចូលរួម គឺសហរដ្ឋអាម៉េរិក សហភាពសូវៀត ចក្រភពអង់គ្លេស សាធារណរដ្ឋប្រជាមានិតចិន បារាំង កម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម រដ្ឋវៀតណាម និងឡាវ។<br>នៅក្នុងឯកសារចុងក្រោយនេះ មានសេចក្តីប្រកាសចុងក្រោយ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៥៤ ស្តីពីការស្តាបនាសន្តិភាពនៅឥណ្ឌូចិនឡើងវិញដែលនៅក្នុងនោះមានសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជាចំនួនពីរសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលឡាវចំនួនពីរ និងសេចក្តីប្រកាសរបស់រដ្ឋាភិបាលបារាំងចំនួនពីរ។</td></tr>
<tr><td>៣៥- សេចក្តីប្រកាសរបស់រដ្ឋាភិបាលកម្ពុជាក្នុងអវសានកិច្ចនៃសន្និសីទក្រុងហ្សឺណែវ ស្តីពីឥណ្ឌូចិន<br>អ. Declaration of Cambodian Government in the Final Act of the Geneva Conference on Indochina</td><td>សេចក្តីប្រកាសចំនួនពីរ ដែលនៅក្នុងសេចក្តីប្រកាសទី១មានខ្លឹមសារថា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដោយមានឆន្ទៈចង់ធានាឱ្យមានសុខដុមភាពនិងឯកភាពសម្រាប់ប្រជាជននៃព្រះរាជាណាចក្រនោះ ប្រកាសប្តេជ្ញាចិត្តរបស់ខ្លួនចាត់វិធានការសមស្របដើម្បីធ្វើសមាហរណកម្មប្រជាពលរដ្ឋទាំងអស់ដោយគ្មានការរើសអើង ឱ្យចូលក្នុងសហគមន៍ជាតិ និងធានានូវសិទ្ធិនិងសេរីភាព ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ពលរដ្ឋទាំងអស់អាចចូលរួមដោយសេរី ជាអ្នកបោះឆ្នោត និងជាបេក្ខជនក្នុងការបោះឆ្នោតទូទៅ និងដោយសម្ងាត់។<br>សេចក្តីប្រកាសទី២មានខ្លឹមសារជាអាទិ៍ថា រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាមិនចូលរួមក្នុងនយោបាយឈ្លានពានណាមួយនិងមិនអនុញ្ញាតឱ្យយកទឹកដីកម្ពុជា</td></tr>
</table>

| | |
|---|---|
| បារ. Déclaration du Gouvernement du Cambodge dans l'Acte final de la Conférence de Genève sur l'Indochine | ប្រើប្រាស់ ដើម្បីបម្រើគោលនយោបាយបែបនោះឡើយ។ |
| **៣៦- សេចក្ដីប្រកាសរបស់រដ្ឋាភិបាលបារាំងក្នុងអវសានកិច្ចនៃសន្និសីទក្រុងហ្សឺណែវស្ដីពីឥណ្ឌូចិន**<br>អ. Declaration of French Government in the Final Act of the Geneva Conference on Indochina<br>បារ. Déclaration du Gouvernement français dans l'Acte final de la Conférence de Genève sur l'Indochine | សេចក្ដីប្រកាសចំនួនពីរ ដែលនៅក្នុងសេចក្ដីប្រកាសទី១មានខ្លឹមសារថា រដ្ឋាភិបាលនៃសាធារណរដ្ឋបារាំងប្រកាសថា ខ្លួនសុខចិត្តដកកងទ័ពចេញពីទឹកដីកម្ពុជា ឡាវ និងវៀតណាម តាមការស្នើសុំរបស់រដ្ឋាភិបាលពាក់ព័ន្ធនិងក្នុងពេលដែលត្រូវកំណត់ដោយកិច្ចព្រមព្រៀងជាមួយនឹងរដ្ឋាភិបាលទាំងនេះ លើកលែងតែក្នុងករណីដែលតាមកិច្ចព្រមព្រៀងរបស់ភាគីទាំងពីរ កងទ័ពបារាំងមួយចំនួននឹងអាចត្រូវបានរក្សាទុកឱ្យនៅក្នុងបណ្ដាចំណុចកំណត់និងរយៈពេលកំណត់មួយ។<br>សេចក្ដីប្រកាសទី២មានខ្លឹមសារថា នៅក្នុងដំណោះស្រាយរាល់បញ្ហាដែលទាក់ទងនឹងការស្ដាបនាឡើងវិញ និងការពង្រឹងសន្តិភាពនៅក្នុងប្រទេសកម្ពុជា ឡាវ និងវៀតណាម រដ្ឋាភិបាលនៃសាធារណរដ្ឋបារាំងនឹងត្រូវផ្អែកលើការគោរពឯករាជ្យនិងអធិបតេយ្យ ឯកភាពនិងបូរណភាពទឹកដីនៃប្រទេសកម្ពុជា ឡាវ និងវៀតណាម។ |
| **៣៧- សេចក្ដីប្រកាសរបស់រដ្ឋាភិបាលឡាវក្នុងអវសានកិច្ចនៃសន្និសីទក្រុងហ្សឺណែវស្ដីពីឥណ្ឌូចិន**<br>អ. Declaration of Laos Government in the Final Act of the Geneva Conference on Indochina<br>បារ. Déclaration du Gouvernement du Laos dans l'Acte final de la Conférence de Genève sur l'Indochine | សេចក្ដីប្រកាសចំនួនពីរ ដែលនៅក្នុងសេចក្ដីប្រកាសទី១មានខ្លឹមសារថា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រឡាវ ដោយមានឆន្ទៈចង់ធានាឱ្យមានសុខដុមភាព និងឯកភាពសម្រាប់ប្រជាជននៃព្រះរាជាណាចក្រនោះ ប្រកាសប្ដេជ្ញាចិត្តរបស់ខ្លួនចាត់វិធានការសមស្រប ដើម្បីធ្វើសមាហរណកម្មប្រជាពលរដ្ឋទាំងអស់ដោយគ្មានការរើសអើង ឱ្យចូលក្នុងសហគមន៍ជាតិ និងធានានូវសិទ្ធិនិងសេរីភាព ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ។ ពលរដ្ឋទាំងអស់អាចចូលរួមដោយសេរី ជាអ្នកបោះឆ្នោតនិងជាបេក្ខជនក្នុងការបោះឆ្នោតទូទៅ និងដោយសម្ងាត់។<br>សេចក្ដីប្រកាសទី២មានខ្លឹមសារជាអាទិ៍ថា រាជរដ្ឋាភិបាលឡាវប្ដេជ្ញាមិនចូលរួមក្នុងនយោបាយឈ្លានពានណាមួយ និងមិនអនុញ្ញាតឱ្យយកទឹកដីឡាវប្រើប្រាស់ដើម្បីបម្រើគោលនយោបាយបែបនោះឡើយ។ |
| **៣៨- អព្យាក្រឹតភាព**<br>អ. Neutrality<br>បារ.Neutralité | គោលនយោបាយប្រកាន់យកដោយរដ្ឋមួយ ដែលមិនចូលរួមក្នុងសង្គ្រាមណាមួយ ដែលមានការពាក់ព័ន្ធនឹងរដ្ឋពីរឬច្រើន។ រដ្ឋអព្យាក្រឹតត្រូវបានហាមឃាត់មិនឱ្យចូលរួមក្នុងសម្ព័ន្ធភាពយោធាណាមួយឬប្រគល់ទឹកដីរបស់ខ្លួនឱ្យ |

| | |
|---|---|
| | មហាអំណាចណាមួយដែលជាគូប្រយុទ្ធនោះប្រើប្រាស់។ ប៉ុន្តែ រដ្ឋអព្យាក្រឹតមានសិទ្ធិក្នុងការការពារខ្លួន ដោយមធ្យោបាយយោធាប្រឆាំងនឹងការរំលោភបំពានលើអព្យាក្រឹតភាពរបស់ខ្លួន។ |
| **៣៩- អព្យាក្រឹតភាពអចិន្ត្រៃយ៍**<br>អ. perpetual (permanent) Neutrality<br>បារ. Neutralité perpétuelle (permanente) | គោលជំហរនៃប្រទេសដែលមិនត្រឹមតែស្ថិតនៅជាអព្យាក្រឹតក្នុងពេលសង្គ្រាមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមិនចូលរួមក្នុងសម្ព័ន្ធភាពយោធាក្នុងពេលសន្តិភាពផងដែរ។ ប្រទេសដែលប្រកាន់ជំហរដ៏ច្បាស់លាស់នេះ គឺប្រទេសស្វ៊ីសតាំងពីឆ្នាំ១៨១៥។<br><br>Switzerland |
| **៤០- អព្យាក្រឹតភាពអចិន្ត្រៃយ៍នៃប្រទេសស្វ៊ីស**<br>អ. Perpetual Neutrality of Switzerland<br>បារ. Neutralité perpétuelle de la Suisse | អព្យាក្រឹតភាពដែលត្រូវបានកំណត់នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៨១៥ នៅក្នុងសមាជក្រុងវីយ៉ែន (Vienna Congress/Congrès de Vienne) នៃប្រទេសអូទ្រីស ដោយបណ្តាមហាអំណាចជាហត្ថលេខីនៃសន្ធិសញ្ញាក្រុងប៉ារីស។ ជាលទ្ធផល ប្រទេសស្វ៊ីសជារដ្ឋអធិបតេយ្យ ដែលបានទទួលនូវលក្ខន្តិកៈជារដ្ឋអព្យាក្រឹតចាប់ពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៨១៥ ដែលធានានូវបូរណភាពទឹកដី និងភាពមិនអាចរំលោភបាននៃទឹកដីរបស់ខ្លួន។<br>សមាជក្រុងវីយ៉ែន ជាសន្និសីទអ្នកតំណាងការទូតនៃបណ្តាមហាអំណាចអឺរ៉ុប ដែលបានប្រព្រឹត្តទៅនៅក្រុងវីយ៉ែន ពីខែកញ្ញា ឆ្នាំ១៨១៤ ដល់ខែមិថុនា ឆ្នាំ១៨១៥។ បណ្តាប្រទេសដែលមានជ័យជម្នះលើអធិរាជណាប៉ូឡេអុងទី១ (បារាំង) បានរួមប្រជុំដើម្បីដាក់លក្ខខណ្ឌសន្តិភាពនិងកំណត់ព្រំដែនប្រទេសនានានៅទ្វីបអឺរ៉ុប។<br>សន្ធិសញ្ញាក្រុងប៉ារីសថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៨១៤ ធ្វើការកំណត់ព្រំដែននៃប្រទេសបារាំង បន្ទាប់ពីការដាក់រាជ្យនៃអធិរាជណាប៉ូឡេអុងទី១។ |



| | |
|---|---|
| | |
| **៤១- អព្យាក្រឹតភាព តាមឱកាស**<br>អ. Occasional Neutrality<br>បារ. Neutralité occasionnelle | គោលជំហរនៃរដ្ឋដែលមិនចូលរួមក្នុងប្រទូសរ៉ាយភាពណាមួយ ពោលគឺក្នុងឱកាសដែលជម្លោះនោះកំពុងប្រព្រឹត្តទៅ។<br>ឧទាហរណ៍ អព្យាក្រឹតភាពតាមឱកាសនៃប្រទេសកម្ពុជា នៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទី២(ឆ្នាំ១៩៥៤-១៩៧៥)។ អព្យាក្រឹតភាពកម្ពុជា ដែលត្រូវបានបង្កើតឡើងដោយច្បាប់ធម្មនុញ្ញថ្ងៃទី១២ ខែមករា ឆ្នាំ១៩៥៧នោះ លែងត្រូវបានប្រកាន់យកនៅឆ្នាំ១៩៦៥ នៅពេលដែលរាជរដ្ឋាភិបាលកម្ពុជាបានផ្តាច់ទំនាក់ទំនងការទូតជាមួយសហរដ្ឋអាមេរិក និងងាកទៅរកសាធារណរដ្ឋប្រជាមានិតចិន និងសហភាពសូវៀតជាពិសេស។ |
| **៤២- ឯករាជ្យកម្ពុជាក្នុង សហភាពបារាំង**<br>អ. The Independence of Cambodia in the French Union<br>បារ. L'indépendance du Cambodge au sein de l'Union française | ឯករាជ្យកម្ពុជាដែលត្រូវបានប្រកាសនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៤៨ នៅក្រុងភ្នំពេញ ដោយឧត្តមសេនីយ៍ ប្លេសូ(Général Blaizot) ដែលបំពេញមុខងារជាស្នងការជាន់ខ្ពស់បារាំងនៅឥណ្ឌូចិន។ តាមសេចក្តីប្រកាសនេះ កម្ពុជាក្លាយជារដ្ឋឯករាជ្យ ប៉ុន្តែជាសមាជិកនៃសហភាពបារាំង។<br>ចាប់ពីចុងខែតុលា ឆ្នាំ១៩៤៥ គឺបន្ទាប់ពីសង្គ្រាមលោកលើកទី២ តំណែង ជាអគ្គទេសាភិបាលឥណ្ឌូចិន ត្រូវជំនួសដោយតំណែងជាស្នងការជាន់ខ្ពស់បារាំងនៅឥណ្ឌូចិនវិញ។ |
| **៤៣- សន្ធិសញ្ញាបារាំង-កម្ពុជា ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៤៩**<br>អ. Franco-Cambodian Treaty of 8 November 1949<br>បារ. Traité franco-cambodgien du 8 novembre 1949 | សន្ធិសញ្ញាដែលត្រូវបានចុះហត្ថលេខារវាងបារាំងនិងកម្ពុជា នាក្រុងប៉ារីស នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៤៩ ដែលមាន២០មាត្រា។ មាត្រា១ចែងថា «សាធារណរដ្ឋបារាំងទទួលស្គាល់ព្រះរាជាណាចក្រកម្ពុជាថាជារដ្ឋឯករាជ្យ។ ព្រះរាជាណាចក្រកម្ពុជាអះអាងជាថ្មីនូវការចូលជាសមាជិករបស់ខ្លួនក្នុងសហភាពបារាំងក្នុងឋានៈជាសមាគតរដ្ឋ»។<br>ឯកសារខ្លះប្រើពាក្យ «កិច្ចព្រមព្រៀងបារាំង-កម្ពុជា ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៤៩»(Accord franco-cambodgien du 8 Novembre 1949)។<br>តាមសន្ធិសញ្ញានេះ សហភាពរូបិយវត្ថុនិងគយ (Union monétaire et douanière) បានភ្ជាប់កម្ពុជាជាមួយសមាគតរដ្ឋផ្សេងទៀតនៅឥណ្ឌូចិន គឺវៀតណាម(ខាងត្បូង)និងឡាវ។ ផលប្រយោជន៍ដែលប្រទេសកម្ពុជាបាន |

| | |
|---|---|
| | ទទួល នោះមានដូចជា ៖<br>១- អ្នកអង្គម្ចាស់ ពីងពាង យុគន្ធរ ដែលជាម្ដាយមីងរបស់សម្ដេចព្រះនរោត្តម សីហនុ បានក្លាយជាអនុប្រធានសភានៃសហភាពបារាំង។<br>២- ប្រទេសកម្ពុជាមានសិទ្ធិចុះកិច្ចព្រមព្រៀងអន្តរជាតិទាក់ទងនឹងផលប្រយោជន៍ផ្ទាល់ខ្លួន។<br>៣- ព្រះមហាក្សត្រខ្មែរមានការទទួលស្គាល់តាមអង្គច្បាប់ពីរដ្ឋចំនួន៣៥ ដែលមានសហរដ្ឋអាម៉េរិកនិងចក្រភពអង់គ្លេសនៅក្នុងនោះព្រះអង្គបានដាក់ស្ថានទូតនៅក្នុងប្រទេសមួយចំនួនហើយប្រទេសកម្ពុជាបានចូលរួមដោយពេញសិទ្ធិនៅក្នុងសន្និសីទក្រុងសានហ្វ្រានស៊ីស្កូ នាថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៩៥១ ដោយបានចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិភាពជាមួយប្រទេសជប៉ុន។<br>ទោះជាយ៉ាងនេះក្ដី ក៏បារាំងនៅរក្សាសមត្ថកិច្ចមួយចំនួន ដោយផ្ដាច់មុខដូចជា បញ្ញាការខាងកងកម្លាំងប្រដាប់អាវុធ ខាងសន្តិសុខ ជាដើម។ |
| **៤៤- ឯករាជ្យវៀតណាមក្នុងសហភាពបារាំង**<br>អ. The Independence of Vietnam in the French Union<br>បារ. L'indépendance du Vietnam au sein de l'Union française | ឯករាជ្យវៀតណាមដែលបានមកពីកិច្ចព្រមព្រៀងបារាំង-វៀតណាម នាថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៤៩ ហើយដែលតាមកិច្ចព្រមព្រៀងនេះ វៀតណាមក្លាយជារដ្ឋឯករាជ្យ ប៉ុន្តែជាសមាជិកនៃសហភាពបារាំង។<br>ព្រះចៅបៅដាយ(Bao Dai)ដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះជាមួយប្រធានាធិបតីបារាំងលោក វ៉ាំងសង់ អូរីយ៉ូល (Vincent Auriol) ត្រូវបានលើកបន្ទុបជានាយករដ្ឋមន្ត្រីនៃរដ្ឋវៀតណាម។ |
| **៤៥- ឯករាជ្យឡាវក្នុងសហភាពបារាំង**<br>អ. The Independence of Laos in the French Union<br>បារ. L'indépendance du Laos au sein de l'Union française | ឯករាជ្យឡាវដែលបានមកពីកិច្ចព្រមព្រៀងបារាំង-ឡាវ នាថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៤៩ ហើយដែលតាមកិច្ចព្រមព្រៀងនេះ ឡាវក្លាយជារដ្ឋឯករាជ្យ ប៉ុន្តែជាសមាជិកនៃសហភាពបារាំង។<br>ព្រះរាជាណាចក្រឡាវសន្យាថានឹងដាក់រួមនូវមធ្យោបាយទាំងអស់របស់ខ្លួនជាមួយសមាជិកដទៃទៀតនៃសហភាពបារាំង ដើម្បីធានានូវកិច្ចការពារសហភាពទាំងមូល។ ចំណែករដ្ឋាភិបាលនៃសាធារណរដ្ឋបារាំងទទួលបន្ទុកសម្របសម្រួលមធ្យោបាយទាំងនេះ និងដឹកនាំនយោបាយសម្រាប់ធានានូវកិច្ចការពារនេះ។ |
| **៤៦- សន្និសីទអន្តររដ្ឋក្រុងប៉ូ ឆ្នាំ១៩៥០**<br>អ. Interstate Conference | សន្និសីទដែលបានប្រព្រឹត្តទៅនៅក្រុងប៉ូ(Pau) ប្រទេសបារាំង ពីថ្ងៃទី២៩ ខែមិថុនាដល់ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៥០ ដោយមានការចូលរួមពីអ្នកតំណាងរដ្ឋាភិបាលបារាំង កម្ពុជា ឡាវ និងវៀតណាម ស្ដីពីរបៀបផ្ទេរអធិបតេយ្យមក |

<table>
<tr>
<td>in Pau 1950<br>បារ. Conférence inter-<br>Etats à Pau en 1950</td>
<td>ប្រទេសទាំងបីនៅឥណ្ឌូចិន ដោយមានអត្ថបទនៃកិច្ចព្រមព្រៀងចតុភាគីចំនួន ១០៖<br>
១- ប្រៃសណីយ៍និងទូរគមនាគមន៍<br>
២- ការត្រួតពិនិត្យអន្តោប្រវេសន៍<br>
៣- ផែនការបរិក្ខារ<br>
៤- របបនាវាចរណ៍សមុទ្រនិងទន្លេនៅលើទន្លេមេគង្គនិងនាវាចរណ៍ទន្លេចូលទៅកាន់កំពង់ផែក្រុងព្រៃនគរ<br>
៥- ពិធីសារទាក់ទងនឹងការប្រើប្រាស់និងអាជីវកម្មកំពង់ផែក្រុងព្រៃនគរ<br>
៦- សហភាពគយ<br>
៧- ពាណិជ្ជកម្មក្រៅប្រទេស<br>
៨- បណ្ណារ<br>
៩- វិទ្យាស្ថានបោះពុម្ពធនបត្រ<br>
១០- រតនាគារ។<br>

</td>
</tr>
<tr>
<td>៤៧- អនុសញ្ញាអន្តររដ្ឋ ខែធ្នូ ឆ្នាំ១៩៥០<br>អ. Interstate Conventions in December 1950<br>បារ. Conventions inter-états en décembre 1950</td>
<td>អនុសញ្ញានិងពិធីសារសរុបចំនួន១០ដែលត្រូវបានចុះហត្ថលេខានៅ៖<br>
- ក្រុងព្រៃនគរ ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងវៀតណាម (ខាងត្បូង) ដើម្បីអនុវត្តកិច្ចព្រមព្រៀងបារាំង-វៀតណាម ថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៤៩(ជារដ្ឋឯករាជ្យក្នុងសហភាពបារាំង)។<br>
- ក្រុងភ្នំពេញ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងកម្ពុជា ដើម្បីអនុវត្តកិច្ចព្រមព្រៀងបារាំង-កម្ពុជា ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៤៩(ជារដ្ឋឯករាជ្យក្នុងសហភាពបារាំង)។<br>
- ក្រុងវៀងចន្ទន៍ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងឡាវ ដើម្បីអនុវត្តកិច្ចព្រមព្រៀងបារាំង-ឡាវ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៤៩(ជារដ្ឋឯករាជ្យក្នុងសហភាពបារាំង)។<br>
អនុសញ្ញាទាំង១០នេះមានខ្លឹមសារដូចៗគ្នាសម្រាប់កម្ពុជា ឡាវ និង</td>
</tr>
</table>

| | |
|---|---|
| | វៀតណាមស្តីពីៈ<br>១- ប្រៃសណីយ៍និងទូរគមនាគមន៍<br>២- ការត្រួតពិនិត្យអន្តោប្រវេសន៍<br>៣- ផែនការបរិក្ខារ<br>៤- របបនាវាចរណ៍សមុទ្រនិងទន្លេនៅលើទន្លេមេគង្គនិងនាវាចរណ៍ទន្លេចូលទៅកាន់កំពង់ផែក្រុងព្រៃនគរ<br>៥- ពិធីសារទាក់ទងនឹងការប្រើប្រាស់និងអាជីវកម្មកំពង់ផែក្រុងព្រៃនគរ<br>៦- សហភាពគយ<br>៧- ពាណិជ្ជកម្មក្រៅប្រទេស<br>៨- បណ្ណួរ<br>៩- វិទ្យាស្ថានបោះពុម្ពធនបត្រ<br>១០- រតនាគារ។<br> |
| **៤៨- អនុសញ្ញាស្តីពីប្រៃសណីយ៍និងទូរគមនាគមន៍នៅឥណ្ឌូចិន ឆ្នាំ១៩៥០**<br>អ. Convention on Transmissions in Indochina in 1950<br>បារ. Convention sur les transmissions en Indochine en 1950 | អនុសញ្ញាទី១ក្នុងចំណោមអនុសញ្ញានិងពិធីសារសរុបទាំង១០ដែលត្រូវបានចុះហត្ថលេខានៅៈ<br>- ក្រុងព្រៃនគរនាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងវៀតណាម(ខាងត្បូង)<br>- ក្រុងភ្នំពេញនាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងកម្ពុជា<br>- ក្រុងវៀងចន្ទន៍នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងឡាវ ហើយដែលមានខ្លឹមសារជាអាទិ៍ថា ការរៀបចំនិងការធ្វើអាជីវកម្មប្រៃសណីយ៍ និងទូរគមនាគមន៍នៅក្នុងប្រទេសកម្ពុជា ឡាវ និងវៀតណាម គឺជាសមត្ថកិច្ចរបស់រដ្ឋាភិបាលនៃរដ្ឋនីមួយៗដែលមានស្ថាប័នជាតិផ្ទាល់ខ្លួន(មាត្រា១)។ |
| **៤៩- អនុសញ្ញាស្តីពីការត្រួតពិនិត្យអន្តោប្រវេសន៍នៅឥណ្ឌូចិន ឆ្នាំ១៩៥០** | អនុសញ្ញាទី២ក្នុងចំណោមអនុសញ្ញានិងពិធីសារសរុបទាំង១០ ដែលត្រូវបានចុះហត្ថលេខានៅៈ<br>- ក្រុងព្រៃនគរនាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងវៀតណាម |

| | |
|---|---|
| អ. Convention on the Control of Immigration in Indochina in 1950<br>បារ. Convention sur le contrôle de l'immigration en Indochine en 1950 | (ខាងត្បូង)<br>- ក្រុងភ្នំពេញនាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងកម្ពុជា<br>- ក្រុងវៀងចន្ទន៍នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងឡាវ ហើយដែលមានខ្លឹមសារជាអាទិ៍ថា តាមបទបញ្ញាជាធរមាននៅឥណ្ឌូចិន ក្នុងផ្នែកអន្តោប្រវេសន៍ អនុសញ្ញានេះពាក់ព័ន្ធនឹងបណ្ដាជន ដែលត្រូវបញ្ចូលទៅក្នុងប្រភេទជនអន្តោប្រវេសន៍អាស៊ីដែលមានឯកសិទ្ធិនិងទៅក្នុងប្រភេទជនអន្តោប្រវេសន៍អាស៊ីបរទេស(មាត្រា១)។ ផ្នែកអន្តោប្រវេសន៍នេះស្ថិតនៅក្នុងសមត្ថកិច្ចរបស់រដ្ឋាភិបាលកម្ពុជា ឡាវ និងវៀតណាម ដែលមានស្ថាប័នជាតិផ្ទាល់ខ្លួន(មាត្រា២)។<br>ប្រសិនបើមានការចាំបាច់ ត្រូវមានការរៀបចំសន្និសីទ ដើម្បីកំណត់បទបញ្ញាសម្រាប់ការចេញចូលនៃជនអន្តោប្រវេសន៍នៅតាមព្រំដែននៃប្រទេសកម្ពុជា ឡាវ និងវៀតណាម(មាត្រា៣)។<br>ស្នងការរដ្ឋានជាន់ខ្ពស់បារាំងនឹងអាចស្នើរដ្ឋាភិបាលជាតិទាំង៣ឱ្យមានការបណ្ដេញជនអន្តោប្រវេសន៍ចេញ ប្រសិនបើគេយល់ថា មានការចាំបាច់ចំពោះសន្តិសុខនៃកងទ័ពសហភាពបារាំង(ឧបសម្ព័ន្ធ)។ |
| **៥០- អនុសញ្ញាស្ដីពីផែនការបរិក្ខារនៅឥណ្ឌូចិន ឆ្នាំ១៩៥០**<br>អ. Convention on Equipment Plan in Indochina in 1950<br>បារ. Convention sur le plan d'équipement en Indochine en 1950 | អនុសញ្ញាទី៣ក្នុងចំណោមអនុសញ្ញានិងពិធីសារសរុបទាំង១០ ដែលត្រូវបានចុះហត្ថលេខានៅៈ<br>- ក្រុងព្រៃនគរនាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងវៀតណាម(ខាងត្បូង)<br>- ក្រុងភ្នំពេញនាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងកម្ពុជា<br>- ក្រុងវៀងចន្ទន៍នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងឡាវ ហើយដែលមានខ្លឹមសារជាអាទិ៍ថា ការសិក្សា ការអនុម័ត និងការអនុវត្តផែនការកសាងឡើងវិញទំនើបភាវូបនីយកម្ម និងបរិក្ខារនៃប្រទេសកម្ពុជា ឡាវ និងវៀតណាម គឺជាសមត្ថកិច្ចនៃរដ្ឋទាំងនេះ។ រដ្ឋាភិបាលនីមួយៗអាចបង្កើតស្ថាប័នជាតិខាងផែនការផ្ទាល់ខ្លួន(មាត្រា១)។ ស្ថាប័នផែនការ ដែលកំពុងដំណើរការនៅក្រុងព្រៃនគរត្រូវលុបចោល(មាត្រា២)។ គណៈកម្មការផែនការបរិក្ខារមួយត្រូវបង្កើតឡើងដោយមានចំនួនសមាជិកស្មើគ្នា ដែលចាត់តាំងដោយប្រទេសកម្ពុជា បារាំង ឡាវ និងវៀតណាម(មាត្រា៣)។<br>សមត្ថកិច្ចនៃគណៈកម្មការនេះមានជាអាទិ៍ ការផ្ដល់រាល់ព័ត៌មានបច្ចេក-ទេសដែលមានប្រយោជន៍ចំពោះការសិក្សា និងការរៀបចំបណ្ដាផែនការជាតិទៅ ដល់រដ្ឋាភិបាលនៃប្រទេសកម្ពុជា បារាំង ឡាវ និងវៀតណាម(មាត្រា៤)។ |



| | |
|---|---|
| | |
| **៥១- អនុសញ្ញាស្ដីពីរបបនាវាចរណ៍នៅឥណ្ឌូចិនឆ្នាំ១៩៥០**<br>អ. Convention on the Regime of Navigation in Indochina in 1950<br>បារ. Convention sur le régime de la navigation en Indochine en 1950 | អនុសញ្ញាទី៤ (ស្ដីពីរបបនាវាចរណ៍សមុទ្រនិងទន្លេលើទន្លេមេគង្គ និងនាវាចរណ៍ទន្លេទៅកាន់កំពង់ផែក្រុងព្រៃនគរ) ក្នុងចំណោមអនុសញ្ញា និងពិធីសារសរុបទាំង១០ ដែលត្រូវបានចុះហត្ថលេខានៅ៖<br>- ក្រុងព្រៃនគរ នាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងវៀតណាម (ខាងត្បូង)<br>- ក្រុងភ្នំពេញ នាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងកម្ពុជា<br>- ក្រុងវៀងចន្ទន៍ នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងឡាវ<br>ហើយដែលមានខ្លឹមសារជាអាទិ៍ថា ដងទន្លេមេគង្គទាំងមូល ដៃរបស់វាដែលធ្វើនាវាចរណ៍បាន ខ្នែងនិងមាត់ពាមរបស់វាដែលស្ថិតនៅលើទឹកដីកម្ពុជា ឡាវ និងវៀតណាម បណ្ដាកំពង់ផែដែលនៅតាមផ្លូវទឹកទាំងនេះ ជាពិសេស កំពង់ផែក្រុងភ្នំពេញ បណ្ដាផ្លូវទឹកចូលទៅកាន់កំពង់ផែក្រុងព្រៃនគរ ទៅកាន់សមុទ្រ ... ត្រូវបើកចំហដោយសេរីនិងគ្រប់ពេល ដោយប្រទេសកម្ពុជា ឡាវ និងវៀតណាម ចំពោះរាល់ភាគីនៃអនុសញ្ញានេះ និងចំពោះប្រទេសដទៃទៀតនៃសហភាពបារាំង ដែលអាចប្រើប្រាស់វាដោយស្មើភាព(មាត្រា១)។ |
| **៥២- ពិធីសារទាក់ទងនឹងការប្រើប្រាស់និងអាជីវកម្មកំពង់ផែក្រុងព្រៃនគរនៅឆ្នាំ១៩៥០**<br>អ. Protocol concerning the use and operation of the port of Saigon in | ពិធីសារទោល ក្នុងចំណោមអនុសញ្ញានិងពិធីសារសរុបទាំង១០ ដែលត្រូវបានចុះហត្ថលេខានៅ៖<br>- ក្រុងព្រៃនគរនាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងវៀតណាម(ខាងត្បូង)<br>- ក្រុងភ្នំពេញនាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងកម្ពុជា<br>- ក្រុងវៀងចន្ទន៍នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងឡាវ<br>ហើយដែលមានខ្លឹមសារជាអាទិ៍ថា ការប្រើប្រាស់និងអាជីវកម្មកំពង់ផែពាណិជ្ជកម្មក្រុងព្រៃនគរ នឹងក្លាយជាកម្មវត្ថុនៃអនុសញ្ញាទ្វេភាគី ដែលត្រូវធ្វើនៅពេល |

| | |
|---|---|
| 1950<br>បារ. Protocole relatif à l'utilisation et l'exploitation du port de Saigon en 1950 | ក្រោយនិងពេលជំណាលគ្នា ដោយវៀតណាមជាមួយកម្ពុជា បារាំង និងឡាវ។<br>អនុសញ្ញាទាំងនេះដែលនឹងយកបទបញ្ញត្តិនៃពិធីសារបច្ចុប្បន្នដោយមានការយល់ព្រម ចាប់ពីពេលនេះទៅធ្វើជាមូលដ្ឋាននោះ នឹងមានខ្លឹមសារដូចៗគ្នា។ ទោះជាយ៉ាងនេះក្តី ក៏បណ្តាមូលហេតុឃោជានឹងមានតែនៅក្នុងកិច្ចព្រមព្រៀងរវាងវៀតណាម និងបារាំងតែប៉ុណ្ណោះ។ |
| **៥៣- អនុសញ្ញាស្តីពីសហភាពគយនៅឥណ្ឌូចិន ឆ្នាំ១៩៥០**<br>អ. Convention on Customs Union in Indochina in 1950<br>បារ. Convention sur l'union douanière en Indochine en 1950 | អនុសញ្ញាទី៥ ក្នុងចំណោមអនុសញ្ញានិងពិធីសារសរុបទាំង១០ ដែលត្រូវបានចុះហត្ថលេខានៅ៖<br>- ក្រុងព្រៃនគរនាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងវៀតណាម(ខាងត្បូង)<br>- ក្រុងភ្នំពេញនាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងកម្ពុជា<br>- ក្រុងវៀងចន្ទន៍នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងឡាវ<br>ហើយដែលមានខ្លឹមសារជាអាទិ៍ថា ស្ថាប័នសហព័ន្ធគយនៅឥណ្ឌូចិនត្រូវលុបចោល(មាត្រា១)។ ការបង្កើតនីតិកម្មនិងបទបញ្ជា ការរៀបចំនិងរដ្ឋបាលនៃស្ថាប័នគយ ការប្រមូលពន្ធដារ សម្រាប់បណ្តារដ្ឋជាសមាជិកនៃសហភាពគយ គឺជាសមត្ថកិច្ចរៀងខ្លួន នៃរដ្ឋកម្ពុជា រដ្ឋឡាវ និងរដ្ឋវៀតណាម(មាត្រា២)។ រដ្ឋកម្ពុជា រដ្ឋឡាវ និងរដ្ឋវៀតណាម បង្កើតសហភាពគយរបស់ខ្លួន(មាត្រា៣) ហើយមិនត្រូវមានរបាំងគយនៅតាមព្រំដែនរួមនៃប្រទេសនៅក្នុងសហភាពគយនោះទេ(មាត្រា៤)។ |
| **៥៤- អនុសញ្ញាស្តីពីពាណិជ្ជកម្មក្រៅប្រទេស នៅឥណ្ឌូចិន ឆ្នាំ១៩៥០**<br>អ. Convention on Foreign Trade in Indochina in 1950<br>បារ. Convention sur le commerce extérieur en Indochine en 1950 | អនុសញ្ញាទី៦ ក្នុងចំណោមអនុសញ្ញានិងពិធីសារសរុបទាំង១០ ដែលត្រូវបានចុះហត្ថលេខានៅ៖<br>- ក្រុងព្រៃនគរនាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងវៀតណាម(ខាងត្បូង)<br>- ក្រុងភ្នំពេញនាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងកម្ពុជា<br>- ក្រុងវៀងចន្ទន៍នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងឡាវ<br>ហើយដែលមានខ្លឹមសារជាអាទិ៍ថា អង្គការនិងស្ថាប័នដែលមានលក្ខណៈសហព័ន្ធ ដូចខាងក្រោមនេះត្រូវលុបចោល៖<br>• គណៈកម្មការកណ្តាលខាងផ្គត់ផ្គង់និងបណ្តូរពាណិជ្ជកម្ម<br>• គណៈកម្មការអចិន្ត្រៃយ៍ខាងបណ្តូរសម្រាប់ក្នុងនិងក្រៅប្រទេស<br>• ទីចាត់ការពាណិជ្ជកម្មក្រៅប្រទេស<br>• ការិយាល័យកែលម្អកម្មវិធីនាំចេញ<br>• គណៈកម្មការកណ្តាលខាងតម្លៃ។ល។<br>មុខការនិងសមត្ថកិច្ចនៃអង្គការនិងស្ថាប័នទាំងនេះស្ថិតនៅក្រោមឱវាទនៃរដ្ឋាភិបាល កម្ពុជា ឡាវ និងវៀតណាម(មាត្រា១)។ រដ្ឋាភិបាលកម្ពុជា បារាំង ឡាវ និងវៀតណាមព្រមព្រៀងគ្នាធ្វើសុខដុមនីយកម្មក្នុងគោលនយោបាយ |

| | |
|---|---|
| | ពាណិជ្ជកម្មក្រៅប្រទេសរបស់ខ្លួនឱ្យស្របទៅតាមបណ្តាកិច្ចព្រមព្រៀងរវាងប្រទេសបារាំង និងប្រទេសទាំងបីនៅឥណ្ឌូចិន ស្តីពីសេរីភាពពាណិជ្ជកម្ម ជាដើម (មាត្រា២និងមាត្រា៣)។ |
| **៥៥- អនុសញ្ញាស្តីពីបណ្តូរ នៅឥណ្ឌូចិន ឆ្នាំ១៩៥០**<br>អ. Convention on Exchange in Indochina in 1950<br>បារ. Convention sur les changes en Indochine en 1950 | អនុសញ្ញាទី៧ ក្នុងចំណោមអនុសញ្ញានិងពិធីសារសរុបទាំង១០ ដែលត្រូវបានចុះហត្ថលេខានៅ៖<br>- ក្រុងព្រៃនគរនាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងវៀតណាម(ខាងត្បូង)<br>- ក្រុងភ្នំពេញនាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងកម្ពុជា<br>- ក្រុងវៀងចន្ទន៍នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងឡាវ ហើយដែលមានខ្លឹមសារជាអាទិ៍ថា មន្ទីរឥណ្ឌូចិនខាងបណ្តូរតាមរចនាសម្ព័ន្ធពេលនោះ ព្រមទាំងគ្រប់អង្គការ និងស្ថាប័នឧបសម្ព័ន្ធ ជាពិសេស ការិយាល័យអនុញ្ញាតលើការទិញ ត្រូវលុបចោលតាមលក្ខខណ្ឌដូចមានចែងនៅក្នុងអនុសញ្ញានេះ(មាត្រា១)។ នាយកដ្ឋានខាងបណ្តូរត្រូវបង្កើតឡើងនៅក្នុងវិទ្យាស្ថានបោះពុម្ពធនបត្រ នៃរដ្ឋកម្ពុជា រដ្ឋឡាវ និងរដ្ឋវៀតណាម(មាត្រា៣)។ |
| **៥៦- អនុសញ្ញាស្តីពីវិជ្ជាស្ថានបោះប្រាក់នៅឥណ្ឌូចិន ឆ្នាំ១៩៥០**<br>(សម័យបច្ចុប្បន្ន គេប្រើ វិទ្យាស្ថានវិញ)<br>អ. Convention on the Emission Institute in Indochina in 1950<br>បារ. Convention sur l'Institut d'Emission en Indochine en 1950 | អនុសញ្ញាទី៨ក្នុងចំណោមអនុសញ្ញានិងពិធីសារសរុបទាំង១០ដែលត្រូវបានចុះហត្ថលេខានៅ៖<br>- ក្រុងព្រៃនគរនាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងវៀតណាម (ខាងត្បូង)<br>- ក្រុងភ្នំពេញនាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងកម្ពុជា<br>- ក្រុងវៀងចន្ទន៍នាថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំង និងឡាវ ហើយដែលមានខ្លឹមសារជាអាទិ៍ថា គ្រឹះស្ថានមួយដែលមានឈ្មោះថា វិទ្យាស្ថានបោះប្រាក់ត្រូវបង្កើតឡើងនៅក្នុងរដ្ឋកម្ពុជា រដ្ឋឡាវ និងរដ្ឋវៀតណាម(មាត្រា១)។ វិទ្យាស្ថានបោះប្រាក់មានភ្នាក់ងារនៅក្រុងប៉ារីស ក្រុងហាណូយ ក្រុងវ៉េ និងនៅក្នុងក្រុងដទៃទៀតដែលក្រុមប្រឹក្សាភិបាលយល់ថាចាំបាច់(មាត្រា២)។ ក្រដាសប្រាក់ដែលបោះពុម្ពដោយវិទ្យាស្ថាននេះមានឈ្មោះថា រៀល(Piastres) (មាត្រា៣)។<br><br> |
| **៥៧- អនុសញ្ញាស្តីពីរតនាគារនៅឥណ្ឌូចិន ឆ្នាំ១៩៥០** | អនុសញ្ញាទី៩ ក្នុងចំណោមអនុសញ្ញានិងពិធីសារសរុបទាំង១០ដែលត្រូវ បានចុះហត្ថលេខានៅ៖<br>- ក្រុងព្រៃនគរនាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងវៀតណាម |

| | |
|---|---|
| អ. Convention on the treasure in Indochina in 1950<br>បារ. Convention sur le trésor en Indochine en 1950 | (ខាងត្បូង)<br>- ក្រុងភ្នំពេញនាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងកម្ពុជា<br>- ក្រុងវៀងចន្ទន៍នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៥០ រវាងបារាំងនិងឡាវ ហើយដែលមានខ្លឹមសារជាអាទិ៍ថា អង្គការនិងស្ថាប័នហិរញ្ញវត្ថុដែលមានលក្ខណៈសហព័ន្ធត្រូវលុបចោល ជាពិសេស រតនាគារឥណ្ឌូចិន និងទីចាត់ការរតនាគារ (មាត្រា១)។ រដ្ឋកម្ពុជា រដ្ឋឡាវ និងរដ្ឋវៀតណាម តាមរយៈស្ថាប័នជាតិខាងរតនាគារ ជានានូវការអនុវត្តថវិកាជាតិរៀងៗខ្លួន។ សមត្ថកិច្ចនៃស្ថាប័នជាតិខាងរតនាគារ លាតសន្ធឹងនៅលើទឹកដីរៀងៗខ្លួននៃរដ្ឋកម្ពុជា រដ្ឋឡាវ និងរដ្ឋវៀត-ណាម(មាត្រា២)។ |
| **៥៨- អនុសញ្ញាស្តីពីការបោះប្រាក់នៅឥណ្ឌូចិន ឆ្នាំ១៩៥១**<br>អ. Convention on the Emission in Indochina in 1951<br>បារ. Convention sur l'Emission en Indochine en 1951 | អនុសញ្ញាដែលត្រូវបានចុះហត្ថលេខានៅក្រុងប៉ារីស នាថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៥១ ហើយដែលមានខ្លឹមសារជាអាទិ៍ថា ជាការអនុវត្តតាមមាត្រា៣នៃអនុ-សញ្ញាអន្តររដ្ឋ ស្តីពីវិទ្យាស្ថានបោះប្រាក់នៅឥណ្ឌូចិនឆ្នាំ១៩៥០នោះ ប្រទេសកម្ពុជា ឡាវ និងវៀតណាមប្រគល់សិទ្ធិបោះធនបត្រ ទៅឱ្យវិទ្យាស្ថានបោះប្រាក់នៃរដ្ឋកម្ពុជា រដ្ឋឡាវ និងរដ្ឋវៀតណាម ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៥២តទៅ។ រដ្ឋាភិបាលបារាំងនឹងចាត់វិធានការដកយកឯកសិទ្ធិបោះប្រាក់ពីធនាគារឥណ្ឌូចិន នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៥១(មាត្រា១)។ ទីស្នាក់ការនៃវិទ្យាស្ថាននេះស្ថិតនៅក្រុងភ្នំពេញ ចំណែកឯបណ្តាសាខាថ្នាក់ជាតិត្រូវបង្កើតនៅក្នុងរាជ/រដ្ឋធានីនៃប្រទេសកម្ពុជា ឡាវ និងវៀតណាម(មាត្រា២)។<br><br>ប្រាក់កាក់១០សេន ២០សេន ៥០សេន ឆ្នាំ១៩៥៣ |
| **៥៩- សន្និសីទចតុភាគីក្រុងប៉ារីសទាក់ទងនឹងឥណ្ឌូចិនឆ្នាំ១៩៥៤** | សន្និសីទដែលបានប្រព្រឹត្តទៅនៅក្រុងប៉ារីស ចាប់ពីថ្ងៃទី២៦ ខែសីហា ដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៥៤ ដោយមានការចូលរួមពីអ្នកតំណាងនៃរដ្ឋាភិបាលបារាំង កម្ពុជា ឡាវ និងវៀតណាម ហើយបានឈានទៅដល់កិច្ចព្រមព្រៀង និងអនុ- |

| | |
|---|---|
| អ. Quadripartite Conference of Paris concerning Indochina in 1954<br>បារ. Conférence quadripartite de Paris concernant l'Indochine en 1954 | សញ្ញានានា ដើម្បីប្រគល់ឯករាជ្យទាំងស្រុងមកឱ្យរដ្ឋកម្ពុជា រដ្ឋឡាវ និងរដ្ឋវៀតណាម។ កិច្ចព្រមព្រៀងនិងអនុសញ្ញាទាំងនោះ មានជាអាទិ៍៖<br>- កិច្ចព្រមព្រៀងទាក់ទងនឹងការផ្ទេរស្ថាប័នរូបិយវត្ថុ<br>- កិច្ចព្រមព្រៀងទាក់ទងនឹងបណ្តូរ<br>- កិច្ចព្រមព្រៀងទាក់ទងនឹងពាណិជ្ជកម្មក្រៅប្រទេស<br>- កិច្ចព្រមព្រៀងទាក់ទងនឹងនិរាករណ៍អនុសញ្ញាស្តីពីសហភាពគយ<br>- កិច្ចព្រមព្រៀងទាក់ទងនឹងរបបនាវាចរណ៍លើទន្លេមេគង្គនិងផ្លូវចូលកំពង់ផែព្រៃនគរ<br>- កិច្ចព្រមព្រៀងទាក់ទងនឹងការប្រើប្រាស់និងអាជីវកម្មកំពង់ផែព្រៃនគរ<br>- កិច្ចព្រមព្រៀងរវាងវៀតណាមនិងកម្ពុជា ស្តីពីការប្រើប្រាស់កំពង់ផែពាណិជ្ជកម្មព្រៃនគរ<br>- កិច្ចព្រមព្រៀងទាក់ទងនឹងផែនការបរិក្ខារ<br>- កិច្ចព្រមព្រៀងទាក់ទងនឹងការត្រួតពិនិត្យអន្តោប្រវេសន៍<br>- កិច្ចព្រមព្រៀងទាក់ទងនឹងប្រៃសណីយ៍និងទូរគមនាគមន៍<br>- កិច្ចព្រមព្រៀងទាក់ទងនឹងក្រុមភូមិសាស្ត្រឥណ្ឌូចិន<br>- កិច្ចព្រមព្រៀងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិសាធារណៈនៃឥណ្ឌូចិន។ |
| **៦០- កិច្ចព្រមព្រៀងទាក់ទងនឹងការផ្ទេរស្ថាប័នរូបិយវត្ថុនៅឥណ្ឌូចិនឆ្នាំ១៩៥៤**<br>អ. Agreement concerning the transfer of monetary institutions in Indochina in 1954<br>បារ. Accord relatif au transfert des institutions monétaires en Indochine en 1954 | កិច្ចព្រមព្រៀងមួយ ដែលត្រូវបានចុះហត្ថលេខានៅពេលបញ្ចប់សន្និសីទចតុភាគីក្រុងប៉ារីស(ពីថ្ងៃទី២៦ ខែសីហាដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៥៤) ហើយដែលមានខ្លឹមសារជាអាទិ៍ថា របបរូបិយវត្ថុ ដែលត្រូវបានបង្កើតឡើងដោយអនុសញ្ញាអន្តររដ្ឋ នាខែវិច្ឆិកានិងខែធ្នូ ឆ្នាំ១៩៥០ និងខែធ្នូ ឆ្នាំ១៩៥១ នៅក្នុងទឹកដីនៃរដ្ឋកម្ពុជា រដ្ឋឡាវ និងរដ្ឋវៀតណាមនោះ នឹងត្រូវបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៥៤។ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៥៥ ឯកសិទ្ធិបោះប្រាក់ ដែលជាមុខការរបស់វិទ្យាស្ថានបោះប្រាក់បង្កើតឡើងដោយមាត្រា១នៃអនុសញ្ញាអន្តររដ្ឋ នាខែវិច្ឆិកានិងខែធ្នូ ឆ្នាំ១៩៥០នោះនឹងត្រូវដកចេញពីស្ថាប័ននេះ(មាត្រា១)។ រដ្ឋនីមួយៗក្នុងចំណោមរដ្ឋទាំង៣មានអធិបតេយ្យពេញលេញក្នុងការកំណត់របបរូបិយវត្ថុនៅលើទឹកដីរបស់ខ្លួន ជាពិសេស ក្នុងការចាត់តាំងឱ្យគ្រឹះស្ថានមួយទទួលឯកសិទ្ធិបោះប្រាក់ ដើម្បីអនុវត្តតាមមាត្រា១ខាងលើនេះ មុនថ្ងៃទី១ ខែមករា ឆ្នាំ១៩៥៥ (មាត្រា២)។ |
| **៦១- កិច្ចព្រមព្រៀងទាក់ទងនឹងបណ្តូរនៅឥណ្ឌូចិនឆ្នាំ១៩៥៤** | កិច្ចព្រមព្រៀងមួយ ដែលត្រូវបានចុះហត្ថលេខានៅពេលបញ្ចប់សន្និសីទចតុភាគីក្រុងប៉ារីស(ពីថ្ងៃទី២៦ ខែសីហាដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៥៤) ហើយដែលមានខ្លឹមសារជាអាទិ៍ថា អនុសញ្ញាស្តីពីបណ្តូរដែលត្រូវបានចុះហត្ថ- |

| | |
|---|---|
| អ. Agreement concerning the Exchange in Indochina in 1954<br>បារ. Accord relatif aux changes en Indochine en 1954 | លេខានៅខែធ្នូ ឆ្នាំ១៩៥០ រវាងព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋបារាំង ព្រះរាជាណាចក្រឡាវ និងរដ្ឋវៀតណាមនោះត្រូវចាត់ទុកជានិរាករណ៍(មាត្រា១)។ មន្ទីរឥណ្ឌូចិនខាងបណ្តូរត្រូវលុបចោលចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៥៥។ សមត្ថកិច្ចខាងបណ្តូរនឹងត្រូវផ្ទេរទៅឱ្យរដ្ឋាភិបាលកម្ពុជា ឡាវ និងវៀតណាម ចាប់ពីកាលបរិច្ឆេទដូចគ្នានេះ(មាត្រា២)។ |
| **៦២- កិច្ចព្រមព្រៀងទាក់ទងនឹងពាណិជ្ជកម្មក្រៅប្រទេសនៅឥណ្ឌូចិន ឆ្នាំ១៩៥៤**<br>អ. Agreement concerning the External trade in Indochina in 1954<br>បារ. Accord relatif au commerce extérieur en Indochine en 1954 | កិច្ចព្រមព្រៀងមួយ ដែលត្រូវបានចុះហត្ថលេខានៅពេលបញ្ចប់សន្និសីទចតុភាគីក្រុងប៉ារីស(ពីថ្ងៃទី២៦ ខែសីហាដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៥៤) ហើយដែលមានខ្លឹមសារជាអាទិ៍ថា អនុសញ្ញាស្តីពីពាណិជ្ជកម្មក្រៅប្រទេស ដែលត្រូវបានចុះហត្ថលេខានៅខែធ្នូ ឆ្នាំ១៩៥០ រវាងព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋបារាំង ព្រះរាជាណាចក្រឡាវ និងរដ្ឋវៀតណាមនោះត្រូវទុកជានិរាករណ៍(មាត្រា១)។ រាល់អង្គការនិងស្ថាប័នដូចខាងក្រោម ដែលត្រូវបានបង្កើតឡើងដោយអនុសញ្ញានេះត្រូវលុបចោល៖<br>- គណៈកម្មការវិជ្ជាជីវៈ<br>- កិច្ចប្រជុំនាយកពាណិជ្ជកម្មក្រៅប្រទេស<br>- គណៈកម្មការសិក្សាខាងពាណិជ្ជកម្មក្រៅប្រទេស<br>- សន្និសីទអន្តររដ្ឋាភិបាល<br>- សន្និសីទសហភាពបារាំង(មាត្រា២)។<br>ដើម្បីជានានិរន្តរភាពក្នុងការផ្គត់ផ្គង់ដល់រដ្ឋកម្ពុជា រដ្ឋឡាវ និងរដ្ឋវៀតណាមនោះ ត្រូវមានការបញ្ជាក់ថា៖<br>ក- ឥណទានសម្រាប់វិស័យនាំចូលនៃតំបន់ប្រាក់ដុល្លារ នឹងត្រូវរក្សាទុករហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៥៥។<br>ខ- ឥណទានសម្រាប់វិស័យនាំចូលនៃតំបន់ប្រាក់ស្វែលីង(Sterling) នឹងត្រូវបញ្ចប់ក្នុងកាលបរិច្ឆេទដូចគ្នានេះ(មាត្រា៤)។ |
| **៦៣- កិច្ចព្រមព្រៀងទាក់ទងនឹងនិរាករណ៍អនុសញ្ញាស្តីពីសហភាពគយនៅឥណ្ឌូចិន ឆ្នាំ១៩៥៤**<br>អ. Agreement concerning the abolition of the Customs Union Convention in Indochina in 1954 | កិច្ចព្រមព្រៀងមួយ ដែលត្រូវបានចុះហត្ថលេខានៅពេលបញ្ចប់សន្និសីទចតុភាគីក្រុងប៉ារីស(ពីថ្ងៃទី២៦ ខែសីហាដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៥៤) ហើយដែលមានខ្លឹមសារជាអាទិ៍ថា អនុសញ្ញាអន្តររដ្ឋស្តីពីសហភាពគយ ដែលត្រូវបានចុះហត្ថលេខា នៅខែធ្នូ ឆ្នាំ១៩៥០ រវាងព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋបារាំង ព្រះរាជាណាចក្រឡាវ និងរដ្ឋវៀតណាមនោះ ត្រូវទុកជានិរាករណ៍(មាត្រា១)។ រាល់អង្គការនិងស្ថាប័នដូចខាងក្រោមនេះ ក៏ត្រូវលុបចោលដែរ៖<br>- គណៈកម្មការសិក្សាខាងគយ<br>- សន្និសីទអន្តររដ្ឋាភិបាល |

| | |
|---|---|
| បារ. Accord relatif à l'abrogation de la convention sur l'union douanière en Indochine en 1954 | - កិច្ចប្រជុំនាយកថ្នាក់ជាតិខាងគយ<br>- គណៈសង្កេតការណ៍នៃសហភាពគយ<br>- គណៈកម្មការសុខដុមនីយកម្មខាងរដ្ឋាករ(មាត្រា២)។<br>ដើម្បីរក្សាសហប្រតិបត្តិការជិតស្និទ្ធរវាងប្រទេសកម្ពុជា ឡាវ និងវៀតណាមនោះ អនុសញ្ញាទ្វេភាគីនានានឹងកំណត់នូវទំនាក់ទំនងអនាគតរបស់ប្រទេសទាំងបីក្នុងវិស័យគយ(មាត្រា៤)។ |
| **៦៤- កិច្ចព្រមព្រៀងទាក់ទងនឹងរបបនាវាចរណ៍នៅឥណ្ឌូចិន ឆ្នាំ១៩៥៤**<br>អ. Agreement concerning the Regime of Navigation in Indochina in 1954<br>បារ. Accord relatif au régime de la navigation en Indochine en 1954 | កិច្ចព្រមព្រៀងមួយ ដែលត្រូវបានចុះហត្ថលេខានៅពេលបញ្ចប់សន្និសីទចតុភាគីក្រុងប៉ារីស(ពីថ្ងៃទី២៦ ខែសីហាដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៥៤) ហើយដែលមានខ្លឹមសារជាអាទិ៍ថា អនុសញ្ញាស្ដីពីរបបនាវាចរណ៍សមុទ្រ និងទន្លេនៅលើទន្លេមេគង្គ និងនាវាចរណ៍ទន្លេចូលទៅកំពង់ផែ ក្រុងព្រៃនគរ ដែលត្រូវបានចុះហត្ថលេខានៅខែធ្នូ ឆ្នាំ១៩៥០ រវាងព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋបារាំង ព្រះរាជាណាចក្រឡាវ និងរដ្ឋវៀតណាមនោះ ត្រូវទុកជានិរាករណ៍(មាត្រា១)។ រដ្ឋទាំងបីគឺកម្ពុជា ឡាវ និងវៀតណាម ជាអ្នកសម្រេចក្នុងការចុះហត្ថលេខាលើអនុសញ្ញាសម្រាប់នាវាចរណ៍នៅលើទន្លេមេគង្គ និងនៅលើបណ្ដាផ្លូវចូលទៅកំពង់ផែក្រុងព្រៃនគរ ទៅតាមស្ថានភាពដោយឡែក និងក្នុងផលប្រយោជន៍រួមរបស់ខ្លួន(មាត្រា២)។ |
| **៦៥- កិច្ចព្រមព្រៀងទាក់ទងនឹងការប្រើប្រាស់និងអាជីវកម្មកំពង់ផែព្រៃនគរ ឆ្នាំ១៩៥៤**<br>អ. Agreement concerning the use and operation of the port of Saigon in 1954<br>បារ. Accord relatif à l'utilisation et à l'exploitation du port de Saigon en 1954 | កិច្ចព្រមព្រៀងមួយ ដែលត្រូវបានចុះហត្ថលេខានៅពេលបញ្ចប់សន្និសីទចតុភាគីក្រុងប៉ារីស(ពីថ្ងៃទី២៦ ខែសីហាដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៥៤) ហើយដែលមានខ្លឹមសារជាអាទិ៍ថា ពិធីសារទាក់ទងនឹងការប្រើប្រាស់និងអាជីវកម្មកំពង់ផែព្រៃនគរ ដែលត្រូវបានចុះហត្ថលេខានៅខែធ្នូ ឆ្នាំ១៩៥០រវាងប្រទេសកម្ពុជា បារាំង ឡាវ និងវៀតណាមនោះត្រូវទុកជានិរាករណ៍(មាត្រា១)។<br>តាមស្ថានភាពដោយឡែកនិងក្នុងផលប្រយោជន៍រួមរបស់ខ្លួន រដ្ឋទាំងបី គឺកម្ពុជា ឡាវ និងវៀតណាម ជាអ្នកសម្រេចក្នុងការចុះហត្ថលេខាលើអនុសញ្ញាមួយរវាងវៀតណាមនិងកម្ពុជា និងលើអនុសញ្ញាមួយទៀតរវាងវៀតណាម និងឡាវ ដើម្បីកំណត់អំពីរបៀប ប្រើប្រាស់កំពង់ផែព្រៃនគរ(មាត្រា២)។ |
| **៦៦- អនុសញ្ញារវាងវៀតណាមនិងកម្ពុជាស្ដីពីការប្រើប្រាស់កំពង់ផែពាណិជ្ជ** | អនុសញ្ញាមួយដែលត្រូវបានចុះហត្ថលេខានៅពេលបញ្ចប់សន្និសីទចតុភាគីក្រុងប៉ារីស(ពីថ្ងៃទី២៦ ខែសីហាដល់ថ្ងៃទី២៩ ធ្នូ ឆ្នាំ១៩៥៤) ហើយដែលមានខ្លឹមសារជាអាទិ៍ថា កំពង់ផែពាណិជ្ជកម្មព្រៃនគរ រួមទាំងសាខានិងផ្លូវចូលដែល |

| | |
|---|---|
| **កម្មព្រៃនគរ ឆ្នាំ១៩៥៤**<br>អ. Convention between Vietnam and Cambodia on the use of the commercial port of Saigon in 1954<br>បារ. Convention entre le Vietnam et le Cambodge sur l'utilisation du port de commerce de Saigon en 1954 | បង្កើតបានជាកំពង់ផែពាណិជ្ជកម្មស្វយ័តព្រៃនគរ រាប់ទាំងផ្នែកសមុទ្រឆ្ពោះទៅសមុទ្រអន្តរជាតិនោះ នឹងត្រូវបើកចំហគ្រប់ពេលវេលាដោយសេរី ដោយវៀតណាម ចំពោះពាណិជ្ជកម្មកម្ពុជា ដោយគោរពតាមបទបញ្ញត្តិនិងបទបញ្ជាជាធរមាន ជាពិសេស ខាងនគរបាល គយ នាវាចរណ៍ និងសន្តិសុខ(មាត្រា១)។ ដើម្បីផ្តល់ភាពងាយស្រួលដល់ពាណិជ្ជកម្មកម្ពុជា ជាពិសេសការប្រមូលផ្តុំទំនិញ វៀតណាមនឹងផ្តល់ទីកន្លែងដោយឡែកមួយនៅក្នុងបរិវេណនៃកំពង់ផែព្រៃនគរសម្រាប់ពាណិជ្ជកម្មនេះ(មាត្រា៤)។ |
| **៦៧- កិច្ចព្រមព្រៀងទាក់ទងនឹងផែនការបរិក្ខារនៅឥណ្ឌូចិន ឆ្នាំ១៩៥៤**<br>អ. Agreement concerning the equipment plan in Indochina In 1954<br>បារ. Accord relatif au plan d'équipement en Indochine en 1954 | កិច្ចព្រមព្រៀងមួយ ដែលត្រូវបានចុះហត្ថលេខានៅពេលបញ្ចប់សន្និសីទចតុភាគីក្រុងប៉ារីស(ពីថ្ងៃទី២៦ ខែសីហាដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៥៤) ហើយដែលមានខ្លឹមសារជាអាទិ៍ថា អនុសញ្ញាស្តីពីផែនការបរិក្ខារដែលត្រូវបានចុះហត្ថលេខានៅខែធ្នូ ឆ្នាំ១៩៥០ រវាងព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋបារាំង ព្រះរាជាណាចក្រឡាវ និងរដ្ឋវៀតណាមនោះ ត្រូវទុកជានិរាករណ៍(មាត្រា១)។គណៈកម្មការផែនការបរិក្ខារត្រូវលុបចោល(មាត្រា២)។ ការបិទបញ្ជីរបស់គណៈកម្មការផែនការបរិក្ខារនឹងត្រូវធ្វើតាមបែបបទ ដែលកំណត់ដោយពិធីសារភ្ជាប់ជាមួយកិច្ចព្រមព្រៀងនេះ ហើយនឹងត្រូវបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៥៤។ បែបបទនៃការបិទបញ្ជី ដែលទាក់ទងនឹងបុគ្គលិកចែងជាអាទិ៍ថា បុគ្គលិកបារាំងនឹងត្រូវប្រគល់ឱ្យអគ្គស្នងការបារាំងនៅឥណ្ឌូចិន ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៥៥ ចំណែកឯបុគ្គលិកវៀតណាមនឹងត្រូវប្រគល់ឱ្យរដ្ឋាភិបាលវៀតណាមចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៥៥ដែរ។ |
| **៦៨- កិច្ចព្រមព្រៀងទាក់ទងនឹងការត្រួតពិនិត្យអន្តោប្រវេសន៍នៅឥណ្ឌូចិន ឆ្នាំ១៩៥៤**<br>អ. Agreement concerning the Immigration control in Indochina in 1954<br>បារ. Accord relatif au contrôle de l'immigration en Indochine en 1954 | កិច្ចព្រមព្រៀងមួយ ដែលត្រូវបានចុះហត្ថលេខានៅពេលបញ្ចប់សន្និសីទចតុភាគីក្រុងប៉ារីស(ពីថ្ងៃទី២៦ ខែសីហាដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៥៤) ហើយដែលមានខ្លឹមសារជាអាទិ៍ថា អនុសញ្ញាស្តីពីការត្រួតពិនិត្យអន្តោប្រវេសន៍ដែលត្រូវបានចុះហត្ថលេខានៅខែធ្នូ ឆ្នាំ១៩៥០ រវាងព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋបារាំង ព្រះរាជាណាចក្រឡាវ និងរដ្ឋវៀតណាមនោះ ត្រូវទុកជានិរាករណ៍(មាត្រា១)។ ស្នងការជាន់ខ្ពស់បារាំងនៅឥណ្ឌូចិនបានបង្កើតស្ថាប័នកណ្តាលខាងអន្តោប្រវេសន៍ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៤៩ និងបានប្រគល់ឱ្យរដ្ឋាភិបាលវៀតណាមគ្រប់គ្រង នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៥០។ រដ្ឋាភិបាលកម្ពុជា ឡាវ និងវៀតណាម នឹងអាចយកមកកាន់កាប់ឡើងវិញនូវសំណុំឯកសារចម្លងនៃជនអន្តោប្រវេសន៍ ដែលបានមកនៅលើទឹកដីរបស់ខ្លួន ប្រសិនបើគេចង់បាន(មាត្រា២)។ |

| | |
|---|---|
| **៦៩- កិច្ចព្រមព្រៀងទាក់ទងនឹងប្រៃសណីយ៍និងទូរគមនាគមន៍នៅឥណ្ឌូចិនឆ្នាំ១៩៥៤**<br>អ. Agreement concerning the transmissions in Indochina in 1954<br>បារ. Accord relatif aux transmissions en Indochine en 1954 | កិច្ចព្រមព្រៀងមួយ ដែលត្រូវបានចុះហត្ថលេខានៅពេលបញ្ចប់សន្និសីទចតុភាគីក្រុងប៉ារីស(ពីថ្ងៃទី២៦ ខែសីហាដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៥៤) ហើយដែលមានខ្លឹមសារជាអាទិ៍ថា អនុសញ្ញាស្តីពីប្រៃសណីយ៍និងទូរគមនា-គមន៍ ដែលត្រូវបានចុះហត្ថលេខានៅខែធ្នូឆ្នាំ១៩៥០ រវាងប្រទេសកម្ពុជា បារាំង ឡាវ និងវៀតណាមនោះត្រូវទុកជានិរាករណ៍(មាត្រា១)។ |
| **៧០- កិច្ចព្រមព្រៀងទាក់ទងនឹងក្រុមភូមិសាស្ត្រឥណ្ឌូចិន ឆ្នាំ១៩៥៤**<br>អ. Agreement concerning the Geographical Service of Indochina in 1954<br>បារ. Accord relatif au service géographique de l'Indochine en 1954 | កិច្ចព្រមព្រៀងមួយដែលត្រូវបានចុះហត្ថលេខានៅពេលបញ្ចប់សន្និសីទចតុភាគីក្រុងប៉ារីស(ពីថ្ងៃទី២៦ ខែសីហាដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៥៤)<br>ហើយដែលមានខ្លឹមសារជាអាទិ៍ថា អនុសញ្ញាស្តីពីវិទ្យាស្ថានភូមិសាស្ត្រឥណ្ឌូចិន ដែលត្រូវបានចុះហត្ថលេខានៅខែមេសា ឆ្នាំ១៩៥២នោះ ត្រូវទុកជានិរាករណ៍(មាត្រា១)។ ក្រុមភូមិសាស្ត្រឥណ្ឌូចិននឹងត្រូវរំសាយ ហើយត្រូវធ្វើការបែងចែកទ្រព្យសម្បត្តិរួមរវាងរដ្ឋកម្ពុជា រដ្ឋឡាវ និងរដ្ឋវៀតណាម។ កាលបរិច្ឆេទនៃការរំសាយនិងការបញ្ចប់នៃការបិទបញ្ជីត្រូវកំណត់ត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៥៥។ រដ្ឋាភិបាលបារាំងនឹងធានាខាងហិរញ្ញកិច្ច និងដំណើរការនៃក្រុមភូមិសាស្ត្រឥណ្ឌូចិន រហូតទៅដល់កាលបរិច្ឆេទនោះ (មាត្រា២)។ |
| **៧១- កិច្ចព្រមព្រៀងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិរួមនៃឥណ្ឌូចិនឆ្នាំ១៩៥៤**<br>អ. Agreement concerning the sharing of property in the common domain of Indochina in 1954<br>បារ. Accord relatif au partage des biens du domaine commun de l'Indochine en 1954 | កិច្ចព្រមព្រៀងមួយដែលត្រូវបានចុះហត្ថលេខានៅពេលបញ្ចប់សន្និសីទចតុភាគីក្រុងប៉ារីស(ពីថ្ងៃទី២៦ ខែសីហាដល់ថ្ងៃទី២៩ខែធ្នូឆ្នាំ១៩៥៤) ហើយដែលមានខ្លឹមសារជាអាទិ៍ថា គេត្រូវធ្វើការបែងចែករាល់ចលនទ្រព្យ និងអចលនទ្រព្យដែលជាប់បន្ទុក ឬ ត្រូវបានសាងសង់ក្នុងនាមអតីតវិស័យរួមនៃឥណ្ឌូចិន ដោយប្រើឥណទាននៃអតីតថវិកាទូទៅសហព័ន្ធ ឬរួម។<br>គេត្រូវធ្វើការបែងចែកផងដែរ រាល់ចលនទ្រព្យនិងអចលនទ្រព្យដែលបានមកដោយឥតគិតថ្លៃ ក្នុងនាមវិស័យដូចគ្នានេះ។ រាល់ទ្រព្យសម្បត្តិនៃវិស័យសាធារណៈត្រូវដាក់នៅក្រៅការបែងចែក(មាត្រា១)។ ដើម្បីសម្រួលដល់ការបែងចែកចលនទ្រព្យសម្រាប់ការប្រើប្រាស់ធម្មតា(ដូចជាសង្ហារិម វត្ថុ) នឹងត្រូវដកចេញពីការបែងចែក ហើយនឹងក្លាយជាកម្មសិទ្ធិរបស់រដ្ឋដែលកាន់កាប់វត្ថុទាំងនោះនៅក្នុងពេលបែងចែកនេះ(មាត្រា២)។<br>ការបែងចែកនឹងធ្វើតាមភាគរយ ដូចខាងក្រោមនេះ៖<br>- សម្រាប់ប្រទេសកម្ពុជាគឺ ១៩,៧៥%<br>- សម្រាប់ប្រទេសឡាវគឺ ៦% |

| | |
|---|---|
| | - សម្រាប់ប្រទេសវៀតណាមគឺ ៧៤,២៥% (មាត្រា៤)។ |
| **៧២- សេអាតូ :**<br>**អង្គការសន្ធិសញ្ញា**<br>**អាស៊ីអាគ្នេយ៍**<br>អ. SEATO: Southeast Asia Treaty Organisation<br>បារ. Organisation du Traité de l'Asie du Sud-Est | អង្គការអន្តរជាតិមួយសម្រាប់កិច្ចការពាររួមនៅអាស៊ីអាគ្នេយ៍បង្កើតឡើងដោយសន្ធិសញ្ញាការពាររួមអាស៊ីអាគ្នេយ៍ឬកតិកាសញ្ញា ក្រុងម៉ានីល(ប្រទេសហ្វីលីពីន) ដែលត្រូវបានចុះហត្ថលេខានៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៩៥៤។ ស្ថាប័នផ្លូវការរបស់សេអាតូត្រូវបានបង្កើតឡើងនៅក្នុងកិច្ចប្រជុំនៃដៃគូសន្ធិសញ្ញានៅទីក្រុងបាងកក នាថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៥៥។ គោលបំណងចម្បងនៃអង្គការនេះ គឺដើម្បីទប់ស្កាត់ការពង្រីកលទ្ធិកុម្មុយនីស្តនៅអាស៊ីអាគ្នេយ៍បន្តទៀត។<br>ទីស្នាក់ការរបស់អង្គការនេះស្ថិតនៅទីក្រុងបាងកកប្រទេសថៃ។ សមាជិករបស់អង្គការនេះមាន អូស្ត្រាលី បារាំង នូវែលសេឡង់ ប៉ាគីស្ថាន ហ្វីលីពីន ថៃ អង់គ្លេសនិងសហរដ្ឋអាមេរិក។ សេអាតូត្រូវបានរំសាយនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៧៧។<br><br>ទង់របស់អង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍។ |
| **៧៣- សន្និសីទក្រុងបានឌុង**<br>**ឆ្នាំ១៩៥៥**<br>អ. Bandung Conference of 1955<br>បារ. Conférence de Bandung de 1955 | សន្និសីទអាស៊ី-អាហ្វ្រិកខ្នាតធំជាលើកដំបូងដែលបានប្រព្រឹត្តទៅពីថ្ងៃទី១៨ ដល់ថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៥៥ នៅក្រុងបានឌុង ប្រទេសឥណ្ឌូណេស៊ី ដោយមានការចូលរួមពីបណ្ដារដ្ឋអាស៊ី-អាហ្វ្រិក ដែលភាគច្រើនទើបទទួលបានឯករាជ្យ។ ប្រទេសចំនួន២៩ ដែលបានចូលរួមក្នុងសន្និសីទក្រុងបានឌុង តំណាងជិត១ភាគ៤នៃផ្ទៃភពផែនដី និងមានប្រជាជនសរុបចំនួន១ ៥០០លាននាក់។ សន្និសីទនេះត្រូវបានរៀបចំដោយប្រទេសឥណ្ឌូណេស៊ី ភូមា ប៉ាគីស្ថាន ស្រី-លង្កា និងឥណ្ឌា ដោយមានគោលបំណងបង្កើនសហប្រតិបត្តិការខាងសេដ្ឋ-កិច្ច និងវប្បធម៌អាស៊ី-អាហ្វ្រិក ប្រឆាំងនឹងលទ្ធិអាណានិគមនិយមបែបថ្មី ព្រមទាំងពិភាក្សាអំពីសន្តិភាព និរាណានិគមកម្ម និងតួនាទីរបស់តតិយលោកនៅក្នុងសង្គ្រាមត្រជាក់។ សន្និសីទនេះ គឺជាជំហានដ៏សំខាន់មួយឆ្ពោះទៅកាន់ចលនាមិនចូលបក្សសម្ព័ន្ធ។ ដើម្បីប្រារព្ធខួបលើកទី៥០នៃសន្និសីទនេះ ប្រមុខរដ្ឋនិងរដ្ឋាភិបាលនៃបណ្ដាប្រទេសអាស៊ី-អាហ្វ្រិកបានចូលរួមក្នុងកិច្ចប្រជុំកំពូលអាស៊ី-អាហ្វ្រិកថ្មីមួយពីថ្ងៃទី២០ដល់ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៥ នៅទីក្រុងហ្សាកាតា និងបានឌុង។ សន្និសីទនេះបានបញ្ចប់ដោយការបង្កើតភាពជាដៃគូយុទ្ធសាស្ត្រអាស៊ី-អាហ្វ្រិកថ្មី(NAASP: New Asian–African Strategic Partnership)។ |

| | |
|---|---|
| | <br>ទង់ជាតិកម្ពុជាដែលត្រូវបានប្រើនៅក្នុងសន្និសីទក្រុងបាន់ឌុងឆ្នាំ១៩៥៥ នៅរក្សាទុកមកដល់សព្វថ្ងៃ នៅក្នុងសារមន្ទីរនៃសន្និសីទអាស៊ី-អាហ្វ្រិក។ |
| **៧៤- សន្ធិសញ្ញាសាំងសែ ម៉ាំងអង់ឡេ ឆ្នាំ១៩១៩**<br>អ. Treaty of Saint-Germain-en-laye 1919<br>បារ. Traité de Saint-Germain-en-laye 1919 | កិច្ចព្រមព្រៀងសន្តិភាពដែលបានចុះហត្ថលេខានៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ ១៩១៩ រវាងក្រុមប្រទេសសម្ព័ន្ធមិត្តដែលឈ្នះក្នុងសង្គ្រាមលោកលើកទី១ និងប្រទេសអូទ្រីស ដែលតម្រូវឱ្យរំលាយចក្រភពអូទ្រីស-ហុងគ្រីដោយទទួលស្គាល់រដ្ឋឯករាជ្យមួយចំនួន ដូចជា ហុងគ្រី ឆេកូស្លូវ៉ាគី ប៉ូឡូញ យូហ្គោស្លាវី ក្រូអាស៊ី សែប៊ី។ សន្ធិសញ្ញានេះ ចូលជាធរមាននៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩២០។ |
| **៧៥- សន្ធិសញ្ញា ណឺយីសៀសែន**<br>អ. Treaty of Neuilly-sur-Seine<br>បារ. Traité de Neuilly-sur-Seine | កិច្ចព្រមព្រៀងសន្តិភាពដែលបានចុះហត្ថលេខានៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ ១៩១៩ រវាងក្រុមប្រទេសសម្ព័ន្ធមិត្តដែលឈ្នះក្នុងសង្គ្រាមលោកលើកទី១និងប្រទេសប៊ុលហ្គារី ដែលតម្រូវឱ្យប្រទេសប៊ុលហ្គារីប្រគល់ទឹកដីដែលខ្លួនបានដណ្តើមយកក្នុងសង្គ្រាមលោកលើកទី១ទៅឱ្យរាជាណាចក្របី គឺសែប៊ី ក្រូអាស៊ី និងស្លូវេនី(ដែលក្រោយមកក្លាយជាយូហ្គោស្លាវី) និងប្រទេសក្រិកវិញ និងមានលក្ខខណ្ឌតម្រូវមួយចំនួនទៀត។ |
| **៧៦- ចលនាមិនចូល បក្សសម្ព័ន្ធ**<br>អ. Non-Aligned Movement (NAM)<br>បារ. Mouvement des non-alignés | ចលនានៃបណ្តារដ្ឋដែលមិនចូលរួមជាផ្លូវការឬមិនប្រឆាំងនឹងប្លុកលោកសេរី ឬប្លុកសង្គមនិយម។ អង្គការនេះត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៦១ នៅក្រុង Belgrade ប្រទេសយូហ្គោស្លាវី។ បិតាស្ថាបនិកនៃចលនាមិនចូលបក្សសម្ព័ន្ធគឺ លោក ណេរូ (Nehru) នៃប្រទេសឥណ្ឌា លោក ស៊ូកាណូ (Sukarno) នៃឥណ្ឌូណេស៊ី លោក ទីតូ(Tito)នៃយូហ្គោស្លាវី លោក ណាសែ (Nasser) នៃអេហ្ស៊ីប និងលោក អិនគ្រូម៉ា(Nkrumah)នៃប្រទេសហ្គាណា។ ចលនានេះបានប្រកាន់យកផ្លូវកណ្តាលសម្រាប់ប្រទេសកំពុងអភិវឌ្ឍ នៅចន្លោះប្លុកលោកខាងលិចនិងលោកខាងកើតក្នុងសម័យសង្គ្រាមត្រជាក់។<br>ចលនាមិនចូលបក្សសម្ព័ន្ធបានប្រកាន់យកគោលការណ៍៥យ៉ាងគឺ៖<br>១- ការគោរពបូរណភាពទឹកដីនិងអធិបតេយ្យទៅវិញទៅមក |

| | |
|---|---|
| | ២- ការមិនឈ្លានពានគ្នាទៅវិញទៅមក<br>៣- ការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងទៅវិញទៅមក<br>៤- សមភាពនិងផលប្រយោជន៍ទៅវិញទៅមក<br>៥- សន្តិសហវិជ្ជមាន។<br>នៅឆ្នាំ២០១២ ចលនាមិនចូលបក្សសម្ព័ន្ធមានសមាជិក១២០ប្រទេស។<br> |
| **៧៧- សន្តិសហវិជ្ជមាន**<br>អ. Peaceful coexistence<br>បារ. Coexistence pacifique | ទ្រឹស្តីដែលត្រូវបានតាក់តែងឡើង និងអនុវត្តដោយសហភាពសូវៀតនៅចំណុចដៅនានា ក្នុងកំលុងពេលសង្គ្រាមត្រជាក់និងត្រូវបានប្រកាន់យកដោយបណ្តារដ្ឋសង្គមនិយមក្រោមឥទ្ធិពលសូវៀត ដែលថាពួកគេអាចរស់នៅដោយសុខសាន្តជាមួយប្លុកមូលធននិយម។ គោលការណ៍នេះផ្ទុយទៅនឹងគោល-ការណ៍ ដែលថាលទ្ធិកុម្មុយនីស្ត និងមូលធននិយមមិនអាចរស់នៅជាមួយគ្នាក្នុងសន្តិភាពបាន។ សហភាពសូវៀតបានអនុវត្តគោលការណ៍នេះក្នុងទំនាក់ទំនងជាមួយលោកខាងលិច ជាពិសេស រវាងបណ្តាប្រទេសនៃអង្គការសន្ធិ-សញ្ញាអាត្លង់ទិកខាងជើងដែលហៅកាត់ថា អូតង់(OTAN: Organisation du traité de l'Atlantique nord)និងបណ្តាប្រទេសនៃកតិកាសញ្ញាវ៉ាសូវី(Pacte de Varsovie)។ |
| **៧៨- បញ្ចសីលានៃសន្តិសហវិជ្ជមាន**<br>អ. Five Principles of Peaceful Coexistence<br>បារ. Cinq principles de la coexistence pacifique | គោលការណ៍ចំនួន៥ដែលត្រូវបានបង្កើតឡើងជាមូលដ្ឋានគ្រឹះក្នុងទំនាក់ទំនងរវាងប្រទេសឥណ្ឌានិងសាធារណរដ្ឋប្រជាមានិតចិន នៅឆ្នាំ១៩៥៤ដែលចែងពី៖<br>១- ការគោរពបូរណភាពទឹកដីនិងអធិបតេយ្យទៅវិញទៅមក<br>២- ការមិនឈ្លានពានគ្នាទៅវិញទៅមក<br>៣- ការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងទៅវិញទៅមក<br>៤- សមភាពនិងសហប្រតិបត្តិការដើម្បីផលប្រយោជន៍ទៅវិញទៅមក<br>៥- សន្តិសហវិជ្ជមាន។ |
| **៧៩- អង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង** | សម្ព័ន្ធភាពយោធាអន្តររដ្ឋាភិបាលរវាងរដ្ឋជាច្រើននៅអាម៉េរិកខាងជើងនិងអឺរ៉ុបផ្អែកលើសន្ធិសញ្ញាអាត្លង់ទិកខាងជើង ដែលត្រូវបានចុះហត្ថលេខា នាថ្ងៃទី៤ |

<table>
<tr>
<td>

**(អង្គការអូតង់)**

អ. North Atlantic Treaty Organization

បារ. Organisation du traité de l'Atlantique nord

</td>
<td>

ខែមេសា ឆ្នាំ១៩៤៩ ក្នុងសម័យសង្គ្រាមត្រជាក់(ឆ្នាំ១៩៤៥-១៩៩១)។

អង្គការនេះបានបង្កើតប្រព័ន្ធការពាររួមមួយដែលរដ្ឋជាសមាជិកព្រមព្រៀងគ្នាចំពោះកិច្ចការពារទៅវិញទៅមកក្នុងការឆ្លើយតបទៅនឹងការវាយប្រហារណាមួយពីខាងក្រៅ។ សមាជិកចំនួនបី(សហរដ្ឋអាម៉េរិក ប្រទេសបារាំង និងអង់គ្លេស) ជាសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិដែលមានសិទ្ធិជំទាស់/សិទ្ធិវេតូ និងជារដ្ឋដែលមានអាវុធនុយក្លេអ៊ែរជាផ្លូវការ។ ទីស្នាក់ការកណ្តាលនៃអង្គការនេះស្ថិតនៅក្រុងព្រុចសែល ប្រទេសបែលហ្ស៊ិក។

បច្ចុប្បន្ននេះ អង្គការអូតង់មានប្រទេសជាសមាជិកចំនួន២៨។ នៅពេលបង្កើតក្នុងឆ្នាំ១៩៤៩ មានសមាជិកស្ថាបនិកចំនួន១២គឺ បែលហ្ស៊ិក កាណាដា ដាណឺម៉ាក សហរដ្ឋអាម៉េរិក បារាំង អ៊ីស្លង់ អ៊ីតាលី លុចសំបួ ន័រវែស ហូឡង់ ព័រទុយហ្គាល់ និងចក្រភពអង់គ្លេស។ ក្រោយមកមានបណ្តាប្រទេសមួយចំនួនទៀតបានចូលរួមជាសមាជិកគឺ ក្រិកនិងតួកគី(១៩៥២) អាល្លឺម៉ង់(១៩៥៥) អេស្ប៉ាញ(១៩៨២) សាធារណរដ្ឋឆែក ហុងគ្រី និងប៉ូឡូញ(១៩៩៩) ប៊ុលហ្គារី អេស្តូនី ឡេតូនី លីទុយអានី(Estonie, Lettonie, Lituanie) រូម៉ានី ស្លូវ៉ាគី ស្លូវេនី(២០០៤) អាល់បានី និងក្រូអាស៊ី(២០០៩)។




</td>
</tr>
<tr>
<td>

**៨០- កតិកាសញ្ញាវ៉ាសូវី**

អ. Warsaw Pact

បារ. Pacte de Varsovie

</td>
<td>

អង្គការយោធានៃបណ្តាប្រទេសសង្គមនិយមនៅអឺរ៉ុបកណ្តាលនិងខាងកើតដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៥៥ ដើម្បីឆ្លើយតបនឹងអង្គការអូតង់(បង្កើតនៅឆ្នាំ១៩៤៩ ក្នុងសម័យសង្គ្រាមត្រជាក់)។ នៅក្នុងអង្គការនេះមានសហភាពសូវៀត និងរដ្ឋរណបសូវៀតចំនួន៧ទៀត គឺអាល់បានី ប៊ុលហ្គារី ហុងគ្រី ប៉ូឡូញ អាល្លឺម៉ង់ខាងកើត រូម៉ានី និងឆេកូស្លូវ៉ាគី។ ទីស្នាក់ការកណ្តាលនៃអង្គការនេះស្ថិតនៅក្រុងវ៉ាសូវី ប្រទេសប៉ូឡូញ។

កតិកាសញ្ញាការពាររួមនេះ ជាផ្នែកបំពេញបន្ថែមខាងយោធានៃក្រុមប្រឹក្សាជំនួយសេដ្ឋកិច្ចទៅវិញទៅមក(Comecon: Conseil d'assistance économique mutuelle) ដែលជាអង្គការសេដ្ឋកិច្ចតំបន់នៃរដ្ឋសង្គមនិយមនៅអឺរ៉ុបកណ្តាល

</td>
</tr>
</table>

| | |
|---|---|
| | និងខាងកើត(បង្កើតឡើងនៅក្រុងមូស្គូ ក្នុងឆ្នាំ១៩៤៩)។ ការបង្កើតកតិកាសញ្ញាវ៉ាសូវី ក៏ត្រូវបានចាត់ទុកថាស្ថិតនៅក្រោមការជំរុញពីសហភាពសូវៀត ដើម្បីរក្សាការត្រួតពិនិត្យលើកងកម្លាំងយោធានៅអឺរ៉ុបកណ្តាលនិងខាងកើត។<br><br> |
| **៨១- ក្រុមប្រឹក្សាជំនួយសេដ្ឋកិច្ចទៅវិញទៅមក(កូមេកុង)**<br>អ. Council for Mutual Economic Assistance (Comecon)<br>បារ. Conseil d'assistance économique mutuelle | អង្គការសេដ្ឋកិច្ចដែលមានអត្ថិភាពពីឆ្នាំ១៩៤៩ដល់ឆ្នាំ១៩៩១ ក្រោមការដឹកនាំរបស់សហភាពសូវៀតដែលមានបណ្តាប្រទេសនៃប្លុកខាងកើតរួមជាមួយរដ្ឋសង្គមនិយមមួយចំនួននៅកន្លែងផ្សេងទៀតក្នុងពិភពលោក។ អង្គការនេះត្រូវបានបង្កើតឡើងដោយសហភាពសូវៀតជាការឆ្លើយតបនឹង៖<br>- ផែនការម៉ាសាល់(Marshall Plan) ដែលត្រូវបានបង្កើតឡើងនៅអឺរ៉ុបខាងលិច នៅឆ្នាំ១៩៤៧។<br>- អង្គការអឺរ៉ុបសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច(Organisation européenne de coopération économique) ដែលត្រូវបានបង្កើតឡើងនៅអឺរ៉ុបខាងលិច នៅឆ្នាំ១៩៤៨(ដែលជាការផ្តើមទៅកាន់សហគមន៍សេដ្ឋកិច្ចអឺរ៉ុប នៅឆ្នាំ១៩៥៧)។ |
| **៨២- ផែនការម៉ាសាល់**<br>អ. Marshall Plan<br>បារ. Plan Marshall | ផែនការដែលមានឈ្មោះជាផ្លូវការថា កម្មវិធីស្តារអឺរ៉ុបឡើងវិញត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៤៧ ក្រោមការផ្តួចផ្តើមគំនិតពីសហរដ្ឋអាម៉េរិក និងយកតាមឈ្មោះរបស់លោករដ្ឋមន្ត្រីការបរទេស ហ្សក ម៉ាសាល់(George Marshall) ដើម្បីជួយអឺរ៉ុបខាងលិចឱ្យកសាងសេដ្ឋកិច្ចឡើងវិញបន្ទាប់ពីការបញ្ចប់សង្គ្រាមលោកលើកទី២។<br>ផែនការនេះត្រូវអនុវត្តសម្រាប់រយៈពេលបួនឆ្នាំ ដែលចាប់ផ្តើមនៅថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៤៨។ នៅពេលចាប់ផ្តើម ប្រទេសចំនួន១៦បានទទួលជំនួយពីផែនការនេះ។ គោលដៅនៃសហរដ្ឋអាម៉េរិកក្នុងផែនការនេះ មានជាអាទិ៍ ការកសាងតំបន់ដែលត្រូវបានបំផ្លិចបំផ្លាញដោយសង្គ្រាមឡើងវិញ ការដករបាំង |

| | |
|---|---|
| | ពាណិជ្ជកម្មចេញ និងការទប់ស្កាត់ការរីករាលដាលនៃលទ្ធិកុម្មុយនីស្ត។<br><br><br>រូបសញ្ញានៃកម្មវិធីស្តារអឺរ៉ុបឡើងវិញ |
| **៨៣- អង្គការសហប្រតិបត្តិការសេដ្ឋកិច្ចអឺរ៉ុប**<br>អ. Organisation for European Economic Cooperation<br>បារ. Organisation européenne de coopération économique | អង្គការដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៤៨ ដោយមានបន្ទុកក្នុងការបែងចែកឥណទាន ដែលផ្តល់ឱ្យដោយផែនការម៉ាសាល់(Marshall Plan)ក្នុងចំណោមប្រទេសអឺរ៉ុបខាងលិច។ អង្គការនេះបានរួមចំណែកដល់ការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងការពង្រឹងនូវការសម្របសម្រួលសេដ្ឋកិច្ចរវាងបណ្តាប្រទេសសមាជិក។<br><br>ប្រទេសអឺរ៉ុបខាងលិច ដែលទទួលជំនួយពីផែនការម៉ាសាល់ |
| **៨៤- ផែនការម៉ូឡូតូវ**<br>អ. Molotov Plan<br>បារ. Plan Molotov | ប្រព័ន្ធដែលត្រូវបានបង្កើតឡើងក្រោមឥទ្ធិពលសហភាពសូវៀតនៅឆ្នាំ១៩៤៧ ដើម្បីផ្តល់ជំនួយជួយកសាងបណ្តាប្រទេសនៅអឺរ៉ុបកណ្តាលនិងខាងកើតឡើងវិញនិងជាការបដិសេធជំនួយពីផែនការម៉ាសាល់(Marshall Plan)ក្នុងបំណងទប់ស្កាត់ឥទ្ធិពលរបស់សហរដ្ឋអាម៉េរិកទៅលើបណ្តាប្រទេស ដែលជាសម្ព័ន្ធ-មិត្តរបស់សហភាពសូវៀត។<br>ផែនការនេះ យកតាមឈ្មោះរបស់លោករដ្ឋមន្ត្រីការបរទេសសូវៀត វ្យ៉ាឆេស្លាវ ម៉ូឡូតូវ(Vyacheslav Molotov) ហើយមានប្រទេសចូលរួមចំនួន៧ គឺប៉ូឡូញ ឆេកូស្លូវ៉ាគី អាល្លឺម៉ង់ខាងកើត ហុងគ្រី ប៊ុលហ្គារី រូម៉ានី និងសហភាពសូវៀត។ ផែនការម៉ូឡូតូវ បានក្លាយជាអង្គការកូមេកុង(Comecon)នៅឆ្នាំ១៩៤៩។ |
| **៨៥- វាំងននដែក**<br>អ. Iron Curtain | ព្រំដែនរឹងមាំដែលភាគខ្លះមានកំពែង ហើយដែលបានចែកទ្វីបអឺរ៉ុបទៅជាតំបន់ពីរផ្សេងគ្នា ចាប់តាំងពីពេលបញ្ចប់សង្គ្រាមលោកលើកទី២ រហូតដល់ពេល |

| | |
|---|---|
| បារ. Rideau de fer | បញ្ចប់សង្គ្រាមត្រជាក់(១៩៤៥-១៩៩១)។<br>ភាគីទាំងសងខាងនៃវាំងននដែកបានខិតខំអភិវឌ្ឍសេដ្ឋកិច្ចអន្តរជាតិ និងសម្ព័ន្ធមិត្តយោធាតែរៀងៗខ្លួន : អង្គការសេដ្ឋកិច្ច«កូមេកុង»ជាមួយនឹងកតិកាសញ្ញាវ៉ាសូវីស្ថិតនៅខាងកើតនៃវាំងននដែក មានសហភាពសូវៀតជាសមាជិកដ៏សំខាន់ ហើយអង្គការអូតង់ជាមួយនឹងសហគមន៍អឺរ៉ុបស្ថិតនៅខាងលិចនៃវាំងននដែក មានសហរដ្ឋអាម៉េរិកជាសម្ព័ន្ធមិត្តដ៏រឹងមាំ។<br>កំពែងក្រុងបែរឡាំងគឺជាសក្ខីភាពមួយគួរឱ្យកត់សម្គាល់ ដែលបានដើរតួជានិមិត្តរូបដ៏យូរនៃវាំងននដែក។ ពាក្យ «វាំងននដែក» ត្រូវបានធ្វើឱ្យមានប្រជា-ប្រិយភាពដោយសារសុន្ទរកថារបស់លោក វីនស្តុន ឈើឈីល (Winston Churchill) ដែលបានថ្លែងនាថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៤៦។<br> |
| **៨៦- កំពែងបែរឡាំង**<br>អ. Berlin Wall<br>បារ. Mur de Berlin | កំពែងក្រុងបែរឡាំងជារបាំងបេតុង(កម្ពស់៣,៦ម.និងទទឹង១,២ម.) មានការយាមល្បាត ដែលបានបែងចែកក្រុងបែរឡាំងទាំងរូបវន្ត ទាំងមនោគមវិជ្ជាពីឆ្នាំ១៩៦១ដល់ឆ្នាំ១៩៨៩។ កំពែងនេះត្រូវបានសាងសង់នៅរាត្រីថ្ងៃទី១២ឆ្លងចូលថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៦១ ដោយសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់(អាល្លឺម៉ង់ខាងកើត)ក្នុងបំណងរារាំងប្រជាជនអាល្លឺម៉ង់ខាងកើតមិនឱ្យឆ្លងទៅអាល្លឺម៉ង់ខាងលិច។<br>អាល្លឺម៉ង់ខាងលិចបានហៅកំពែងនេះថា «កំពែងនៃភាពអាម៉ាស់» ចំណែកអាល្លឺម៉ង់ខាងកើតវិញបានហៅ«កំពែងការពារប្រឆាំងនឹងហ្វាស៊ីស»។ កំពែងនេះជានិមិត្តរូបនៃអឺរ៉ុបមួយ ដែលត្រូវបានបែងចែកដោយវាំងននដែក និងត្រូវបានបើកជាផ្លូវការក្នុងខែវិច្ឆិកា ឆ្នាំ១៩៨៩ ហើយត្រូវបានវាយរំលំជាផ្លូវការចាប់ផ្តើមនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៩០ និងបង្ហើយនៅឆ្នាំ១៩៩២។ |

| | |
|---|---|
| |  |
| **៨៧- សង្គ្រាមត្រជាក់**<br>អ. Cold War<br>បារ. Guerre froide | ការប្រឈមមុខគ្នារវាងមហាអំណាចក្នុងប្លុកលោកខាងកើត(សហភាពសូវៀត និងបណ្តារដ្ឋរណប) និងមហាអំណាចក្នុងប្លុកលោកខាងលិច(សហរដ្ឋអាម៉េរិក សម្ព័ន្ធមិត្តអូតង់ ...)ចាប់ពីពេលបញ្ចប់សង្គ្រាមលោកលើកទី២ ក្នុងឆ្នាំ១៩៤៥ រហូតដល់ពេលដួលរលំនៃសហភាពសូវៀតក្នុងឆ្នាំ១៩៩១។<br>ពាក្យ «ត្រជាក់» ត្រូវបានប្រើដោយសារតែមិនមានការប្រយុទ្ធគ្នាមានទ្រង់ទ្រាយធំដោយផ្ទាល់រវាងភាគីទាំងពីរនោះទេទោះបីជាមានសង្គ្រាមធំៗតាមតំបន់នានា(ដូចជាសង្គ្រាមនៅលើឧបទ្វីបកូរ៉េនិងឥណ្ឌូចិន) ហៅថា សង្គ្រាមតាមរយៈអ្នកតំណាង(Proxy war) ដែលបានគាំទ្រដោយភាគីទាំងពីរនោះក៏ដោយ។<br><br> |
| **៨៨- សាលាបារាំងចុងបូព៌ាប្រទេស**<br>អ. École Française d'Extrême-Orient (French School of the Far East)<br>បារ. École Française | ស្ថាប័នមួយដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៨៩៨នៅក្រុងព្រៃនគរ(សៃហ្គន) ដើម្បីសិក្សាស្រាវជ្រាវផ្នែកបុរាណវត្ថុវិទ្យានៅឥណ្ឌូចិន។ តាមរយៈសាលាបារាំងចុងបូព៌ាប្រទេស អ្នកស្រាវជ្រាវជាច្រើនបានចាប់ផ្តើមធ្វើការងារស្រាវជ្រាវរបស់ខ្លួនដោយផ្ទាល់នៅលើទឹកដីអាស៊ី គឺដូចអ្វីដែលគេធ្លាប់ធ្វើកន្លងមកនៅក្រុងអាថែន(ក្រិក) ក្រុងរ៉ូម(អ៊ីតាលី) និងក្រុងគែរ(អេហ្ស៊ីប)នោះដែរ។<br>នៅឆ្នាំ១៩០២ សាលានេះបានប្តូរទីតាំងពីក្រុងព្រៃនគរ (សៃហ្គន) ទៅហាណូយ និងបានពង្រីកការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រក្នុងការរុករកផ្នែក |

| | |
|---|---|
| d'Extrême-Orient (EFEO) | បុរាណវត្ថុវិទ្យា ព្រមទាំងបានផ្តោតការសិក្សាទៅលើការប្រមូលឯកសារទាំងឡាយដែលសរសេរដោយដៃ(សិលាចារឹក សត្រា ក្រាំង ជាដើម) អភិរក្សប្រាសាទបុរាណ ជាដើម។ ទន្ទឹមនឹងនោះគេក៏បានស្រាវជ្រាវទៅលើប្រវត្តិសាស្ត្រ អរិយធម៌នៃបណ្តាប្រជាជាតិអាស៊ីទាំងឡាយ ចាប់ពីប្រទេសឥណ្ឌារហូតដល់ប្រទេសជប៉ុន។ តាមរយៈការស្រាវជ្រាវបែបវិទ្យាសាស្ត្រនេះ សាលាបារាំងចុងបូព៌ាបានឈានទៅបង្កើតសារមន្ទីរជាតិប្រវត្តិសាស្ត្រ វៀតណាម និងសារមន្ទីរផ្សេងៗទៀតនៅឆ្នាំ១៩០៧ ដូចជា សារមន្ទីរក្រុងដាណាង ព្រៃនគរ(សៃហ្គន) វ៉ៃ ភ្នំពេញ បាត់ដំបង។ល។ ហើយសាលាបារាំងចុងបូព៌ាក៏ទទួលបន្ទុកអភិរក្សប្រាសាទអង្គរវត្តផងដែរ។ អ្នកស្រាវជ្រាវល្បីៗនៃសាលានេះរួមមាន លូ្វី ហ្វីណូ (Louis Finot), ហ្សក សឺដែស(Georges Coedès), ប៊ែណា ហ្គ្រោលីយេ (Bernard Groslier), ហ្សង់ ហ្វីលីយ៉ូហ្សា(Jean Filliozart) ជាដើម។ អ្នកស្រាវជ្រាវមួយចំនួននៃសាលានេះបានចាកចេញពីកម្ពុជា ដោយបង្ខំនៅថ្ងៃក្នុងខែមេសា ឆ្នាំ១៩៧៥។ សាលាបារាំងចុងបូព៌ានៅភ្នំពេញបានបើកទ្វារឡើងវិញនៅឆ្នាំ១៩៩២។ |
| **៨៩- រណសិរ្សរួបរួមជាតិកម្ពុជា**<br>អ. National United Front of Kampuchea<br>បារ. Front Uni National du Kampuchea (FUNK) | ចលនាតស៊ូដែលបង្កើតនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ នៅក្រុងប៉េកាំង ដឹកនាំដោយសម្តេច នរោត្តម សីហនុ រួមជាមួយក្រុមខ្មែរក្រហម ប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរ។<br>នាខែឧសភា ឆ្នាំ១៩៧០ រណសិរ្សនេះក៏បានបង្កើតជារាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា(Royal United National Government of Kampuchea (GRUNK)) ដែលមានសម្តេច នរោត្តម សីហនុ ជាប្រមុខរដ្ឋ សម្តេច ប៉ែន នុត ជានាយករដ្ឋមន្ត្រី និង ខៀវ សំផន ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិនិងជាមេបញ្ជាការកងទ័ពរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ ចាប់ពីពេលនោះហើយ ដែលប្រទេសកម្ពុជាមានរដ្ឋាភិបាលពីរគឺ រដ្ឋាភិបាលនៃរបបសាធារណរដ្ឋខ្មែរនៅក្រុងភ្នំពេញនិងរដ្ឋាភិបាលនិរទេសនៅក្រុងប៉េកាំង ដឹកនាំដោយសម្តេច នរោត្តម សីហនុ។ |
| **៩០- រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ**<br>អ. Coalition Government of Democratic Kampuchea<br>បារ. Gouvernement de coalition du Kampuchea démocratique | រដ្ឋាភិបាលមួយដែលត្រូវបានបង្កើតនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៨២ នៅក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី ដើម្បីរក្សាភាពស្របច្បាប់របស់រដ្ឋាភិបាលនេះនៅអ.ស.ប.ប្រឆាំងនឹងវត្តមានកងទ័ពវៀតណាមនៅកម្ពុជា និងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។ រដ្ឋាភិបាលចម្រុះនេះមានបីភាគីចូលរួម : កម្ពុជាប្រជាធិបតេយ្យ ហ៊្វុនស៊ិនប៉ិច និងរណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ។ រដ្ឋាភិបាលនេះមានសម្តេច នរោត្តម សីហនុ ជាប្រធាន សម្តេច សឺន សាន ជានាយករដ្ឋមន្ត្រី និងលោក ខៀវ សំផន ជារដ្ឋមន្ត្រីការបរទេស និងត្រូវបានបញ្ចប់នៅឆ្នាំ១៩៩៣។ |

| | |
|---|---|
| **៩១- រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ**<br>អ. Khmer People's National Liberation Front<br>បារ. Front National de Liberation du Peuple Khmer | ចលនាតស៊ូមួយដែលត្រូវបានបង្កើតឡើងជាផ្លូវការនៅថ្ងៃទី៩ ខែតុលា ឆ្នាំ ១៩៧៩ នៅក្នុងជំរំជាយដែនខ្មែរ-ថៃ ដែលមានកម្លាំងប្រដាប់អាវុធប្រមាណ ២០០០នាក់ មកពី១៣ក្រុមរួមបញ្ចូលគ្នា( ឧកញ៉ា មឿង ពស់វែក ចលនាខ្មែរ អ៊ិស្លាម ចលនាជាតិនិយម ឧកញ៉ា សឺន គុយ ជាដើម)។ រណសិរ្សនេះបាន ក្លាយជាគណបក្សនយោបាយនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩២ ដែលមាន ឈ្មោះថា «គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា» ហើយបាន ចូលរួមក្នុងការបោះឆ្នោតឆ្នាំ១៩៩៣ និងទទួលបានអាសនៈចំនួន១០។<br><br>ស្លាកសញ្ញារណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ |
| **៩២- បក្សពលករកម្ពុជា**<br>អ. Cambodia Workers' Party<br>បារ. Parti des travailleurs du Kampuchea | ឈ្មោះបក្សដែលត្រូវបានប្តូរពីបក្សប្រជាជនបដិវត្តន៍ខ្មែរតាមរយៈមហាសន្និ-បាតរបស់បក្សនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ នៅក្នុងបរិវេណស្ថានីយរថភ្លើង ក្រុងភ្នំពេញក្បែរវត្តនាគវន្ត។<br>គោលបំណងបក្សនេះមានបុព្វហេតុធំជាងគេគឺការតស៊ូប្រឆាំងនឹងចក្រពត្តិ អាម៉េរិក របបសក្តិភូមិ និងវណ្ណៈជិះជាន់ ព្រមទាំងធ្វើសកម្មភាពដើម្បីតស៊ូវណ្ណៈ និងបដិវត្តន៍សង្គម។ គំនិតនេះកើតឡើងដោយការប្រមូលកម្លាំងចេញពីសាលា ចម្រើនវិជ្ជានិងសាលាពីរទៀតគឺកម្ពុជបុត្រនិងសុគ្គន្ធប្រីជាឥន្ទ ដែល សាឡុត ស ធ្លាប់បានបង្រៀន។ ក្នុងបក្សដែលមានឈ្មោះថ្មីនេះ ប៉ុល ពត (សាឡុត ស) មានបំណងបន្ថយឥទ្ធិពលរបស់វៀតណាម ព្រោះគេបានមើលឃើញថា បក្សថ្មី មិននិយាយពីសាមគ្គីភាពឥណ្ឌូចិន ឬអន្តរជាតិនិយម វណ្ណៈអធន(ការចងបាច់ វណ្ណៈអធនជាអន្តរជាតិរវាងកម្ពុជា វៀតណាម ឡាវ)ទេ តែគេនិយាយថា ខិតខំ សម្រេចឱ្យបានឯករាជ្យពេញលេញ កសាងសេដ្ឋកិច្ចជាតិមួយ ហើយស្ថាបនា ជាតិកម្ពុជាមួយឯករាជ្យអធិបតេយ្យ និងសម្បូររុងរឿង។ សមាសភាពអ្នកដឹកនាំ សំខាន់ៗរួមមាន ទូ សាមុត ជាលេខាបក្ស នួន ជា ជាអនុលេខាបក្ស សាឡុត ស ជាសមាជិកលំដាប់ទី៣ និង អៀង សារី ជាសមាជិកគណៈកម្មាធិការមជ្ឈិម បក្ស។ បន្ទាប់ពី ទូ សាមុត បាត់ខ្លួននៅឆ្នាំ១៩៦២ មហាសន្និបាតវិសាមញ្ញ របស់បក្សត្រូវបានប្រារព្ធធ្វើឡើងនៅខែកុម្ភៈ ឆ្នាំ១៩៦៣ និងបានជ្រើសតាំង ប៉ុល ពត ជាលេខាបក្ស ចំណែក នួន ជា ដែលមានតំណែងខ្ពស់ជាង ប៉ុល ពត នៅក្នុងបក្សមិនត្រូវបានជ្រើសរើសទេ ដោយហេតុថា នួន ជា មានជាប់សាច់ញាតិ ជាមួយជនក្បត់បក្ស ស៊ីវ ហេង។ |

| | |
|---|---|
| **៩៣- គណបក្សចម្រើនជាតិខ្មែរ**<br>អ.Progressive Democratic Party( Kanapac Chamroeun Cheat Khmer )<br>បារ. Parti Démocrate Progressiste | គណបក្សដែលបង្កើតឡើងក្រោមការគាំទ្រពីសម្តេច នរោត្តម សីហនុ នៅខែមេសា ឆ្នាំ១៩៤៦។ គណបក្សនេះដឹកនាំដោយព្រះអង្គម្ចាស់ នរោត្តម ម៉ុងតាណា ដែលជាប្រធាន ហើយមាន នាល ស្មើក(ប្អូន នាល ផ្លេង), អូ ឈឿន, ជា ជិន កុក, ម៉ី ណូសី, សំ ធៀវ, ប៊ុន វូថាញ់ និង លី គឹមឃុត ជាសមាជិក។ គណបក្សនេះទទួលបរាជ័យផ្ទួនៗទាំងក្នុងការបោះឆ្នោតសភាធម្មនុញ្ញនៅឆ្នាំ១៩៤៦ ទាំងក្នុងការបោះឆ្នោតសភាជាតិនៅឆ្នាំ១៩៤៧។ មកដល់ឆ្នាំ១៩៥១ គណបក្សនេះ ក៏លែងមានសកម្មភាពក្នុងឆាកនយោបាយកម្ពុជា។ |
| **៩៤- ខ្មែរឥស្សរៈ (ខ្មែរឯករាជ្យ)**<br>អ. Khmers Issarak<br>បារ. Khmers Issarak | ចលនាតស៊ូខ្មែរត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៤០នៅក្រុងបាកកដឹកនាំដោយអ្នកឯករាជ្យនិយម ប៉ុក គុន ក្រោមការគាំទ្ររបស់ថៃ ក្នុងគោលបំណងប្រមូលផ្តុំកម្លាំងអ្នកតស៊ូខ្មែរដើម្បីទាមទារឯករាជ្យពីរបបអាណាព្យាបាលបារាំង។ នៅខែវិច្ឆិកា ឆ្នាំ១៩៤០ ដោយមានការគាំទ្រពីប្រទេសថៃ និងជប៉ុន ក្រុមអ្នកជាតិនិយមនេះបានចូលកាន់កាប់ខេត្តពីរ គឺបាត់ដំបងនិងសៀមរាប។ ចលនានេះបានរំលាយខ្លួនពេលដែលជប៉ុនចាញ់សង្គ្រាមលោកលើកទី២ នាឆ្នាំ១៩៤៥។ |
| **៩៥- រណសិរ្សខ្មែរឥស្សរៈ**<br>អ. United Issarak Front<br>បារ. Front uni Issarak | ចលនាតស៊ូមាននិន្នាការកុម្មុយនីស្ត បង្កើតឡើងនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៤២ នៅក្រុងភ្នំពេញ ដោយអាចារ្យ មៀន(ស៊ឹង ង៉ុកមិញ) និងអាចារ្យ សុក (ទូ សាមុត) ដែលជាអតីតព្រះសង្ឃ និងក្រោយមកមានការចូលរួមពីពួកអ្នកជាតិនិយមដូចជាប៉ាច ឈឺន នួន ដួង និងអាចារ្យ ហែម ចៀវ ជាដើម។ រណសិរ្សនេះបង្កើតឡើងមានគោលបំណងប្រមូលផ្តុំកម្លាំងអ្នកតស៊ូរំដោះជាតិក្នុងប្រទេសកម្ពុជាផ្ទាល់ ដើម្បីប្រយុទ្ធប្រឆាំងនឹងរបបអាណាព្យាបាលបារាំង។ បន្ទាប់ពីមានឧប្បត្តិហេតុទម្លាក់គ្រាប់បែកនៅក្រុងភ្នំពេញឆ្នាំ១៩៤៥ ចលនានេះក៏បានរំលាយខ្លួន ហើយអ្នកដឹកនាំចលនានេះបានរត់គៀសខ្លួនទៅចូលរួមជាមួយចលនាតស៊ូវៀតមិញ។ |
| **៩៦- បក្សកុម្មុយនីស្តឥណ្ឌូចិន**<br>អ. Indochinese Communist Party<br>បារ. Parti Communiste Indochinois | បក្សដែលបានបង្កើតឡើងនៅក្រុងហុងកុង ដោយលោក ង្វៀន អាយគួក (ហូជីមិញ) នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៩៣០ ក្នុងគោលបំណងប្រមូលផ្តុំចលនាតស៊ូកុម្មុយនីស្តក្នុងតំបន់ឥណ្ឌូចិន តែដោយសារអ្នកចូលរួមក្នុងបក្សនេះសុទ្ធតែជាជនជាតិវៀតណាម ហើយដោយសារតែឥណ្ឌូចិនជាអង្គភាពសេដ្ឋកិច្ចតែមួយ(A single economic unit) ហេតុនេះ ក្រុងម៉ូស្គូ(សហភាពសូវៀត) បានណែនាំឱ្យរៀបចំបង្កើតបក្សកុម្មុយនីស្តដោយឡែកៗនៅប្រទេសកម្ពុជានិងឡាវថែមទៀត។ សមាជិកបក្សដំបូងៗ ដែលបានចូលរួមទាំងនៅកម្ពុជា ទាំងនៅឡាវ ភាគច្រើនជាជនជាតិវៀតណាមដែលធ្វើការនៅក្នុងចម្ការកៅស៊ូរបស់បារាំង។ នៅឆ្នាំ១៩៥១ បក្សកុម្មុយនីស្តឥណ្ឌូចិនត្រូវបានជំនួសដោយការបង្កើត |

| | |
|---|---|
| | បក្សរបស់ជាតិរៀងៗខ្លួនចំនួន៣គឺ បក្សពលករវៀតណាម(Workers' Party of Vietnam) បក្សប្រជាជនបដិវត្តន៍ខ្មែរ(Khmer People's Revolutionary Party) និងបក្សប្រជាជនឡាវ(Laotian People's Party)។ |
| **៩៧- ខ្មែរឥស្សរៈ**<br>អ. Khmer Issarak<br>បារ. Khmers Issarak | បុគ្គលឬក្រុមដែលបានកាន់អាវុធប្រឆាំងនឹងបារាំង ក្នុងការតស៊ូដើម្បីឯករាជ្យពីឆ្នាំ១៩៤៥ដល់ឆ្នាំ១៩៥៣ ហើយមាននិន្នាការនយោបាយនិងមនោគមវិជ្ជាផ្សេងៗពីគ្នា។<br>ដោយមានការគាំទ្រពីរដ្ឋាភិបាលថៃ ក្រុមខ្លះត្រូវបានបង្កើតឡើងនៅពេលលោក ស៊ឺង ង៉ុកថាញ់ ត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៤៥។ ក្រោយពីការដោះលែងលោក ស៊ឺង ង៉ុកថាញ់ បានបង្កើតក្រុមមួយដែលមានឈ្មោះជាផ្លូវការថា «ឥស្សរៈប្រជាចលនា»ក្នុងខែមីនា ឆ្នាំ១៩៥២ ហើយដែលអ្នកផងហៅថា ចលនាប្រជាជនសេរី។<br>ក្រុមខ្មែរឥស្សរៈវៀតមិញ ជាក្រុមដែលបានទទួលការបណ្ដុះបណ្ដាលនិងអាវុធពីពួកកុម្មុយនីស្តវៀតណាមនៅឆ្នាំ១៩៤៨។ បន្ទាប់ពីបារាំងបានប្រគល់ឯករាជ្យ(មិនទាន់ពេញលេញ)ឱ្យប្រទេសកម្ពុជានៅឆ្នាំ១៩៤៩ ពួកឥស្សរៈមួយចំនួនដូចជា លោក ដាប ឈួន បានចុះចូលជាមួយព្រះមហាក្សត្រ ព្រះបាទនរោត្តម សីហនុ នៅសល់តែពួក ស៊ឺង ង៉ុកថាញ់ ជាអ្នកសាធារណរដ្ឋសេរី និងពួកឥស្សរៈដែលគាំទ្រដោយវៀតមិញ។ |
| **៩៨- ខ្មែរសេរី**<br>អ. Khmer Serei<br>បារ. Khmer Serei | ចលនាតស៊ូមួយដែលលេចឡើងតាំងពីខែមីនា ឆ្នាំ១៩៥២ ដោយមានឈ្មោះថា ចលនាប្រជាជនសេរី ដឹកនាំដោយលោក ស៊ឺង ង៉ុកថាញ់។ ចលនានេះបានដូរឈ្មោះថា ខ្មែរសេរី នៅក្រោយឆ្នាំ១៩៥៥ និងភាគច្រើនមានខ្មែរក្រោមជាសមាជិក។ អង្គភាពខ្មែរសេរី ទទួលការបណ្ដុះបណ្ដាលនិងគាំទ្រដោយថៃ ហើយទទួលសព្វាវុធពីសហរដ្ឋអាម៉េរិកដើម្បីប្រឆាំងនឹងកុម្មុយនីស្តនិងសម្ដេចនរោត្តម សីហនុ។ នៅចុងឆ្នាំ១៩៦៩ ពួកខ្មែរសេរីប្រមាណ៨០០នាក់ បានចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា។ ចលនានេះបានរំសាយនៅឆ្នាំ១៩៧០ ហើយកងទ័ពរបស់គេត្រូវបានបញ្ចូលទៅក្នុងកងកម្លាំងនៃសាធារណរដ្ឋខ្មែរ។ |
| **៩៩- ខ្មែរក្រហម**<br>អ. Khmer Rouge<br>បារ. Khmer Rouge | ក្រុមខ្មែរឆ្វេងនិយម(អ្នកមាននិន្នាការកុម្មុយនីស្ត) ដែលសម្ដេចព្រះ នរោត្តម សីហនុ បានហៅនៅចុងទសវត្សរ៍ទី៦នៃសតវត្សរ៍ទី២០។ ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ ខ្មែរសាធារណរដ្ឋបានហៅក្រុមនេះថា ខ្មែរកុម្មុយនីស្ត។ ចាប់ពីឆ្នាំ១៩៧៥មក ពាក្យខ្មែរក្រហម មានន័យថាពួក ប៉ុល ពត។ |
| **១០០- សាធារណរដ្ឋខ្មែរ**<br>អ. Khmer Republic<br>បារ. République Khmère | របបនយោបាយមួយដែលត្រូវបានប្រកាសនៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧០ ដើម្បីបញ្ចប់របបរាជាធិបតេយ្យនៅកម្ពុជា។ របបនេះមានអត្ថិភាពជាង៤ឆ្នាំកន្លះ និងត្រូវបានផ្ដួលរំលំដោយពួកខ្មែរក្រហម នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ មេដឹកនាំសំខាន់ៗនៃរបបនេះមាន លោក លន់ នល់ ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ លោក អ៊ិន តាំ លោក ឡុង បូរ៉េត ជាដើម។ |

| | |
|---|---|
| **១០១- វៀតមិញ**<br>អ. Viet Minh<br>បារ. Viet Minh | ចលនាសម្ព័ន្ធដើម្បីឯករាជ្យវៀតណាម បង្កើតឡើងនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៤១ ដើម្បីបង្រួបបង្រួមកម្លាំងកុម្មុយនីស្តនិងអ្នកជាតិនិយមវៀតណាម ក្នុងការប្រយុទ្ធប្រឆាំងនឹងមហាអំណាចអាណានិគមបារាំងនិងពួកជប៉ុន។ សមាសភាពចូលរួមក្នុងចលនានេះភាគច្រើនមកពីបក្សកុម្មុយនីស្តឥណ្ឌូចិន។ ចលនាវៀតមិញ ដែលមានលោក វ៉ូ ង្វៀនយ៉ាប់(Vo Nguyen Giap) ជាមេបញ្ជាការកងទ័ពបានក្លាយជាក្រុមតស៊ូប្រដាប់អាវុធ ចាប់ពីឆ្នាំ១៩៤៦ដល់ឆ្នាំ១៩៥៤។ ចលនាវៀតមិញបានបញ្ចប់ក្រោយសន្និសីទក្រុងហ្សឺណែវឆ្នាំ១៩៥៤ នៅពេលដែលប្រទេសវៀតណាមត្រូវបានបែងចែកជាពីរគឺវៀតណាមខាងត្បូង និងវៀតណាមខាងជើង។ |
| **១០២- ខ្មែរវៀតមិញ**<br>អ. Khmer Vietminh<br>បារ. Khmer Vietminh | ចលនាតស៊ូខ្មែរមាននិន្នាការកុម្មុយនីស្តនិងចលនាខ្មែរឥស្សរៈនានាដែល ត្រូវបានហៅដោយសម្តេចព្រះនរោត្តម សីហនុ ហើយដែលមានសម្ព័ន្ធភាពជាមួយចលនាតស៊ូវៀតមិញ ក្នុងការទាមទារឯករាជ្យពីមហាអំណាចអាណានិគមបារាំង និងបានបន្តការតស៊ូរបស់ខ្លួនប្រឆាំងនឹងរាជរដ្ឋាភិបាលរបស់ព្រះអង្គក្រោយពីសន្និសីទអន្តរជាតិក្រុងហ្សឺណែវឆ្នាំ១៩៥៤។<br>មេដឹកនាំសំខាន់ៗរបស់ខ្មែរវៀតមិញ គឺលោក ស៊ឺង ង៉ុកមិញនិងលោក ទូ សាមុត ហើយអ្នកចូលរួមក្នុងចលនានេះភាគច្រើនជាខ្មែរក្រោម(ខ្មែរកម្ពុជាក្រោម)។ |
| **១០៣- គណៈជាតិមុត្តគា-ហាមជ្ឈិមនគរខ្មែរ**<br>អ. Khmer People's Liberation Committee<br>*(Kana Cheat Mouta Keaha Mocchim Nokor Khmer)*<br>បារ. Comité de Libération du Peuple Khmer | ចលនាតស៊ូបង្កើតឡើងនៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៤៨ ដោយលោក ដាប ឈួន ក្នុងខេត្តបាត់ដំបង មានគោលបំណងប្រមូលផ្តុំកម្លាំងអ្នកតស៊ូខ្មែរឯករាជ្យនិយម ដើម្បីទាមទារឯករាជ្យពីរបបអាណាព្យាបាលបារាំង។ ចលនាតស៊ូនេះមានសម្ព័ន្ធភាពជាមួយយោធាថៃ និងពេលខ្លះមានសម្ព័ន្ធភាពជាមួយចលនាតស៊ូកុម្មុយនីស្ត។ នៅចុងឆ្នាំ១៩៤៨ ចលនានេះចែកជាបួនក្រុម គឺ មួយក្រុមដឹកនាំដោយលោក ដាប ឈួន និងបីក្រុមទៀតដឹកនាំដោយក្រុមឆ្វេងនិយម។ នៅឆ្នាំ១៩៤៩ ចលនានេះបានបញ្ចប់ពេលលោក ដាប ឈួន ចុះចូលជាមួយសម្តេចព្រះនរោត្តម សីហនុ។ |
| **១០៤- គណៈកម្មាធិការខ្មែរសាងជាតិ**<br>អ. Khmer National Liberation Committee<br>(Kana Kamathikar Khmer Sang Cheat)<br>បារ. Comité National Khmer de Libération | ចលនាតស៊ូដែលប្តូរឈ្មោះពីគណៈជាតិមុត្តគាហាមជ្ឈិមនគរខ្មែរ នៅដើម ឆ្នាំ១៩៤៩ ដឹកនាំដោយលោក លាវ កែវ មុន្នី និងមានព្រះអង្គម្ចាស់ នរោត្តម ច័ន្ទរង្សី ជាមេបញ្ជាការកងទ័ពនៃចលនាតស៊ូនេះ ក្នុងគោលបំណងបន្តការតស៊ូរបស់ខ្លួនប្រឆាំងរបបអាណាព្យាបាលបារាំង។ សមាសភាពសំខាន់ៗនៃចលនានេះមានមួយចំនួនជាក្រុមស្តាំនិយម មួយចំនួនទៀតជាក្រុមឆ្វេងនិយម និងមួយចំនួនផ្សេងទៀតជាក្រុមជាតិនិយម ហើយមានមូលដ្ឋានតស៊ូរៀងៗខ្លួន។ នៅឆ្នាំ១៩៥២ ព្រះអង្គម្ចាស់ នរោត្តម ច័ន្ទរង្សី បានដឹកនាំកម្លាំង ជិតមួយពាន់នាក់ចុះចូលជាមួយចលនាទាមទារឯករាជ្យរបស់សម្តេចព្រះនរោត្តម សីហនុ។ ចលនានេះបានបញ្ចប់នៅពេលដែលលោក លាវ កែវមុន្នី បានទៅចូលរួមជាមួយរណសិរ្សខ្មែរឥស្សរៈ។ |

| | |
|---|---|
| **១០៥- រណសិរ្សខ្មែរឥស្សរៈ (សមាគមខ្មែរឥស្សរៈ)**<br>អ. United Issarak Front (Samakum Khmer Issarak)<br>បារ. Front uni Issarak (Samakum Khmer Issarak) | សមាគមដែលបង្កើតឡើងក្នុងខែមេសា ឆ្នាំ១៩៥០ នៅកំពង់សោមលើ ក្នុងខេត្តកំពត ដោយក្រុមខ្មែរឥស្សរៈនានា ដឹកនាំដោយ លោក ស៊ឹង ង៉ុកមិញ ជាប្រធាន លោក ចាន់ សម័យ និងលោក ទូ សាមុត ជាអនុប្រធាន។ គោលបំណងសំខាន់នៃការបង្កើតសមាគមនេះគឺដើម្បីសម្របសម្រួល និងគាំទ្រដល់ចលនាតស៊ូនានាដែលប្រឆាំងនឹងរបបអាណាព្យាបាលបារាំង។ នៅមុនឆ្នាំ១៩៥៤ សមាគមនេះបានត្រួតត្រាទឹកដីប្រមាណពាក់កណ្ដាលនៃប្រទេសកម្ពុជា និងបានរំសាយនៅឆ្នាំ១៩៥៤ ក្រោយសន្និសីទអន្តរជាតិក្រុងហ្សឺណែវ។ |
| **១០៦- បុណ្យទឹក**<br>អ. Water Ceremony<br>បារ. Cérémonie des Eaux | ពិធីមួយដែលបានបង្កើតឡើងនៅឆ្នាំ១៩៥៩ នាសម័យសង្គមរាស្ត្រនិយម ដោយបានកំណត់ធ្វើនៅថ្ងៃណាមួយនៃខែមីនារៀងរាល់ឆ្នាំ ដើម្បីរៀបចំពិធីរំលឹកគុណដល់ទឹកដែលបានផ្ដល់អត្ថប្រយោជន៍ចំពោះប្រជាជនកម្ពុជាក្នុងការដាំដុះប្រកបដោយភោគផលនានា។ ពិធីបុណ្យនេះធ្វើឡើងមិនមែនសម្រាប់តែទឹកធម្មជាតិប៉ុណ្ណោះទេ ប៉ុន្តែគេធ្វើឡើងដើម្បីរំលឹកគុណប្រភពទឹកទាំងឡាយដែលកើតឡើងដោយកិច្ចការហត្ថកម្មជាតិ និងលទ្ធផលនយោបាយទឹករបស់រដ្ឋាភិបាលក្នុងឆ្នាំនីមួយៗផងដែរ។ |
| **១០៧- បុណ្យទន្លេ**<br>អ. River Festival<br>បារ. Festival du Fleuve | ព្រឹត្តិការណ៍ដែលបានបង្កើតឡើងចាប់តាំងពីឆ្នាំ២០១៤ ដោយក្រសួងទេសចរណ៍ ដែលបានកំណត់យកសប្ដាហ៍ទី១ឬទី២ចំនួន៣ថ្ងៃនៃខែមីនារៀងរាល់ឆ្នាំ ដើម្បីរៀបចំពិធីបុណ្យតាមវេននៃបណ្ដាខេត្តជាប់ដងទន្លេ ក្នុងគោលបំណងបំផុសចលនាមហាជនឱ្យចូលរួមក្នុងការងារអភិរក្ស និងអភិវឌ្ឍធនធានទន្លេប្រកបដោយនិរន្តរភាព និងចូលរួមសម្រេចយុទ្ធសាស្ត្រពិពិធកម្មទេសចរណ៍តាមរយៈការបង្កើតព្រឹត្តិការណ៍ទេសចរណ៍ថ្មីៗសម្រាប់បណ្ដាខេត្តតាមដងទន្លេនៃព្រះរាជាណាចក្រកម្ពុជា។ |
| **១០៨- ទំនាក់ទំនងបារាំងកម្ពុជាក្នុងរជ្ជកាលព្រះបាទអង្គដួង**<br>អ. Franco-Cambodian relations during the reign of Ang Duong<br>បារ. Relations franco-cambodgiennes sous le règne de Ang Duong | ទំនាក់ទំនងរវាងបារាំងនិងកម្ពុជាពីឆ្នាំ១៨៥៣ដល់ឆ្នាំ១៨៥៦ បង្កើតឡើងដោយព្រះបាទអង្គដួងនិងព្រះចៅអធិរាជបារាំង ណាប៉ូឡេអុងទី៣ (Napoléon III)។<br>ព្រះបាទអង្គដួងបានឡើងគ្រងរាជសម្បត្តិនៅឆ្នាំ១៨៤៨។ ព្រះអង្គជាព្រះមហាក្សត្រខ្មែរដំបូងដែលបានផ្ដួចផ្ដើមគំនិតចង់ឱ្យបារាំងមកជួយការពារប្រទេសកម្ពុជាឱ្យផុតពីឥទ្ធិពលរបស់ប្រទេសជិតខាងទាំងពីរ គឺប្រទេសអណ្ណាម និងជាពិសេសប្រទេសសៀម។<br>ទំនាក់ទំនងរបស់ព្រះបាទអង្គដួងដើម្បីបញ្ចប់ឥទ្ធិពលសៀមមកលើកម្ពុជាបានចាប់ផ្ដើមនៅឆ្នាំ១៨៥៣ ដោយការបញ្ជូនមន្ត្រីជាន់ខ្ពស់ខ្មែរពីររូបឈ្មោះ កុយ និង ប៉ែន(ដែលមានខ្សែលោហិតពីជនជាតិព័រទុយហ្គាល់)ទៅកាន់សិង្ហបុរីជាសម្ងាត់ ដើម្បីនាំព្រះរាជសារលិខិតទៅជូនមន្ត្រីកុងស៊ុលបារាំង ដែលត្រូវបញ្ជូនបន្តទៅថ្វាយព្រះចៅអធិរាជបារាំង ណាប៉ូឡេអុងទី៣(Napoléon III)។ |

| | |
|---|---|
| | បន្ទាប់មក លោក សាល ដឺ ម៉ុងទីញី(Charles de Montigny) អ្នកការទូតបារាំង ដែលបានមកដល់កំពង់ផែកំពត នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ១៨៥៦នោះ បានតាក់តែងអត្ថបទអនុសញ្ញាពាណិជ្ជកម្ម និងសាសនា ដើម្បីស្ថាបនាទំនាក់ទំនងជាមួយកម្ពុជា។ ប៉ុន្តែដោយមានការគាបសង្កត់ពីសៀម ព្រះបាទអង្គដួង មិនបានយាងទៅឡាយព្រះហស្តលេខាលើអនុសញ្ញានោះឡើយ។ នេះជាការប៉ុនប៉ងលើកដំបូងរបស់ព្រះរាជាខ្មែរ ក្នុងការបញ្ចប់ឥទ្ធិពលសៀមមកលើកម្ពុជា ប៉ុន្តែមិនបានសម្រេច។ |
| **១០៩- លិខិតព្រះបាទអង្គដួង ថ្វាយព្រះចៅណាប៉ូឡេ-អុងទី៣ ឆ្នាំ១៨៥៣**<br>អ. Letter from Ang Duong to Napoleon III in 1853<br>បារ. Lettre de Ang Duong à Napoléon III en 1853 | លិខិតព្រះបាទអង្គដួងលើកទី១ថ្វាយព្រះចៅអធិរាជណាប៉ូឡេអុងទី៣ (Napoléon III) ដែលមានខ្លឹមសារថា «ពួកបេសកបព្វជិតបារាំងបានប្រាប់ឱ្យយើងដឹងថា អធិរាជបារាំងមានចិត្តសប្បុរសចំពោះគ្រប់ប្រជាជាតិ ព្រះអង្គជួយការពារប្រជាជាតិទាំងនោះ ដើម្បីជានាស្ថិរភាពនិងសុខុមាលភាព ដោយមិនធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ជនម្ចាស់ស្រុក និងថា អធិរាជបារាំងល្អនិងពុំមានការប៉ុនប៉ងដូចព្រះមហាក្សត្រដទៃទៀតនៃទ្វីបអឺរ៉ុប ដែលគិតតែជិះជាន់ប្រទេសដទៃ។ ដោយហេតុនេះ យើងមានសេចក្តីរីករាយនឹងចងសម្ព័ន្ធភាពមួយរឹងមាំជាមួយព្រះចៅអធិរាជដែលនឹងធ្វើឱ្យប្រទេសរបស់យើងធំនិងសម្បូណ៌ ដើម្បីសេចក្តីរុងរឿងរបស់ប្រទេសយើង»។ |
| **១១០- លិខិតព្រះបាទអង្គដួង ថ្វាយព្រះចៅណាប៉ូឡេអុង ទី៣ ឆ្នាំ១៨៥៦**<br>អ. Letter from Ang Duong to Napoleon III in 1856<br>បារ. Lettre de Ang Duong à Napoléon III en 1856 | លិខិតព្រះបាទអង្គដួងលើកទី២ថ្វាយព្រះចៅអធិរាជណាប៉ូឡេអុងទី៣ (Napoléon III) ដែលមានខ្លឹមសារថា «ចាប់ពីឆ្នាំ១៨៤៦ ស្តេចនៅកូសាំងស៊ីនបានប្រកាសថា បណ្តាខេត្តដែលគេយកបានពីកម្ពុជានោះ មិនត្រូវស្តាប់បង្គាប់ខ្ញុំនិងមិនត្រូវបង់សួយសាអាករមកឱ្យខ្ញុំទៀតទេ។ លើសពីនេះ គេបានរារាំងមិនឱ្យធ្វើពាណិជ្ជកម្មនៅ ក្នុងប្រទេសខ្ញុំរួមទាំងនៅតាមកំពង់ផែនានាផងដែរ។ នេះហើយ ជាស្ថានភាពជាក់ស្តែងនៃព្រះរាជាណាចក្រកម្ពុជា។ សូមព្រះអង្គទ្រង់ជ្រាបនូវខេត្តទាំងនោះដែលមានឈ្មោះដូចតទៅ៖ ខេត្តដូនណៃ ដែលបានបាត់ជាង២០០ឆ្នាំមកហើយ ប៉ុន្តែខេត្តជាច្រើនទើបបានបាត់ពេលថ្មីៗនេះគឺ ខេត្តព្រៃនគរ លង់ហោ ផ្សារដែក មេសរ ព្រះត្រពាំង អុងម៉ ក្រមួនស ទឹកខ្មៅ ពាមឬហាទៀង កោះត្រល់ និងកោះត្រឡាច។ ប្រសិនបើដោយចៃដន្យ ពួកអណ្ណាមប្រគល់ខេត្តណាមួយថ្វាយព្រះអង្គ សូមព្រះអង្គកុំទទួល ពីព្រោះគឺជាខេត្តរបស់កម្ពុជាទេ។ សូមព្រះអង្គមេត្តាករុណាដល់ខ្ញុំនិងប្រជាជនខ្ញុំផង ដើម្បីបញ្ចប់នូវការបាត់បង់នេះ»។ |
| **១១១- អនុសញ្ញាពាណិជ្ជកម្ម និងសាសនា ឆ្នាំ១៨៥៦**<br>អ. Commercial and Religious Convention of 1856 | អនុសញ្ញាដែលត្រូវបានតាក់តែងដោយលោកសាល ដឺម៉ុងទីញី(Charles de Montigny) អ្នកការទូតបារាំង ក្នុងពេលស្នាក់នៅឯកំពង់ផែកំពត ចាប់ពីថ្ងៃទី៧ ខែតុលា ឆ្នាំ១៨៥៦ ដើម្បីស្ថាបនាទំនាក់ទំនងគតិយុត្តរវាងបារាំងនិងកម្ពុជាជាលើកដំបូង។ ដោយសារមានការគាបសង្កត់ពីសៀម ព្រះបាទអង្គដួងមិនបាន |

| | |
|---|---|
| បារ. Convention Commerciale et Religieuse de 1856 | យាងពីឧដុង្គទៅកំពត ដើម្បីឡាយព្រះហស្តលេខាលើអនុសញ្ញានេះទេ។ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ១៨៥៦ លោក សាល ដឺ ម៉ុងទីញី បាន ចុះហត្ថលេខាលើអនុសញ្ញានេះតែម្នាក់ឯង រួចផ្ញើមកថ្វាយព្រះបាទអង្គដួងនៅរាជវាំងឧដុង្គ មុននឹងបន្តដំណើរទៅកាន់អណ្ណាម។ ដូច្នេះព្រះរាជបំណង ចង់ស្ថាបនាសម្ព័ន្ធភាពជាមួយបារាំងនៅពេលនោះត្រូវទទួលបរាជ័យ ព្រោះព្រះបាទអង្គដួងមិនបានឡាយព្រះហស្តលេខាលើអនុសញ្ញានោះទេ។<br>អនុសញ្ញាពាណិជ្ជកម្មនិងសាសនាដែលមានចំនួន១៤មាត្រានោះមានចែងជាអាទិ៍ថា នាវាចម្បាំងនិងនាវាជំនួញបារាំងនឹងចូលមកកាន់កំពង់ផែទាំងអស់នៃកម្ពុជាដោយសេរី ដោយមិនត្រូវបង់ពន្ធ និងត្រូវចាត់ទុកដូចជានាវារបស់កម្ពុជានិងរបស់ព្រះរាជាផ្ទាល់ព្រះអង្គ(មាត្រា៥)។ |
| **១១២- សន្ធិសញ្ញាបារាំង-កម្ពុជា ថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣**<br>អ. Franco-Cambodian Treaty of 11 August 1863<br>បារ. Traité Franco-Cambodgien du 11 août 1863 | សន្ធិសញ្ញាអាណាព្យាបាលបារាំងដែលត្រូវបានចុះហត្ថលេខា នៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ នៅព្រះរាជវាំងឧដុង្គរវាងព្រះបាទនរោត្តម និងលោកឧត្តមនាវី ដឺឡាក្រង់ឌីយ៉ែ(De la Grandière) ដែលជាទេសាភិបាលបារាំងនៅកូសាំងស៊ីន(Gouverneur de la Cochinchine)។ សន្ធិសញ្ញាដែលមានចំនួន១៩មាត្រានោះមានចែងជាអាទិ៍ថា ព្រះចៅអធិរាជបារាំងផ្តល់នូវកិច្ចការពាររបស់ខ្លួនចំពោះព្រះរាជាកម្ពុជា(មាត្រា១)។ ព្រះចៅអធិរាជបារាំង ដែលទទួលស្គាល់អធិបតេយ្យនៃព្រះរាជាកម្ពុជានោះ សន្យាថានឹងជួយរក្សាសណ្តាប់ធ្នាប់និងភាពស្ងប់ស្ងាត់នៅក្នុងប្រទេស ព្រមទាំងការពារកម្ពុជាទល់នឹងរាល់ការវាយប្រហារពីខាងក្រៅ ជួយកម្ពុជាក្នុងការទារពន្ធដារពាណិជ្ជកម្ម និងផ្តល់នូវភាពងាយស្រួលក្នុងការស្ថាបនាគមនាគមន៍រវាងកម្ពុជានិងសមុទ្រ(មាត្រា១៦)។ |
| **១១៣- សន្ធិសញ្ញាបារាំង-សៀម ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៨៦៧**<br>អ. Franco-Siamese Treaty of 15 July 1867<br>បារ. Traité Franco-Siamois du 15 juillet 1867 | សន្ធិសញ្ញាដំបូងរវាងបារាំងនិងសៀម ដែលមានខ្លឹមសារដូចតទៅៈ<br>- ព្រះរាជាសៀមទទួលស្គាល់ជាឱឡារិកនូវរបបអាណាព្យាបាលរបស់ព្រះចៅអធិរាជបារាំងលើប្រទេសកម្ពុជា(មាត្រា១)។<br>- សន្ធិសញ្ញាដែលបានចុះហត្ថលេខានៅខែធ្នូ ឆ្នាំ១៨៦៣ រវាងព្រះរាជាណាចក្រសៀម និងព្រះរាជាណាចក្រកម្ពុជា ត្រូវប្រកាសជាមោឃៈ ដោយរដ្ឋាភិបាលសៀមមិនអាចលើកយកមកអះអាងនៅពេលអនាគតក្នុងកាលៈទេសៈណាក៏ដោយ(មាត្រា២)។<br>- ព្រះរាជាសៀមលែងទទួលរាល់សួយសារអាករ វត្ថុអនុស្សាវរីយ៍ឬសញ្ញាផ្សេងៗទៀតនៃភាពជាចំណុះពីសំណាក់ប្រទេសកម្ពុជាសម្រាប់ព្រះអង្គឬអ្នកស្នងរាជ្យទាំងឡាយតពីព្រះអង្គ។ ចំណែកព្រះចៅអធិរាជបារាំងវិញសន្យាថានឹងមិនដណ្តើមយករាជាណាចក្រនេះ(សៀម)ទៅបញ្ចូលក្នុងទឹកដីជាកម្មសិទ្ធិរបស់ខ្លួននៅកូសាំងស៊ីនឡើយ(មាត្រា៣)។<br>- ខេត្តបាត់ដំបងនិងអង្គរ(សៀមរាប)នឹងស្ថិតនៅក្នុងរាជាណាចក្រសៀម។ |

| | |
|---|---|
| | ព្រំប្រទល់នៃខេត្តទាំងនេះនិងខេត្តផ្សេងៗទៀតនៅជាប់អាណាខេត្តសៀម ដែលសព្វថ្ងៃនេះ(ឆ្នាំ១៨៦៧)មានការទទួលស្គាល់ ទៅវិញទៅមកនោះ នឹងត្រូវកំណត់ដោយបង្គោលព្រំដែនឬដោយសញ្ញាផ្សេងៗទៀត នៅពេលឆាប់ៗដោយគណៈកម្មការមួយមានសមាសភាពនាយទាហានសៀម និងខ្មែរដោយមានវត្តមាន និងជំនួយពីនាយទាហានបារាំង ដែលចាត់តាំងដោយទេសាភិបាលកូសាំងស៊ីន។ នៅពេលដែលមានការកំណត់ព្រំដែនរួចហើយនោះ ផែនទីជាក់លាក់មួយនឹងត្រូវគូរដោយនាយទាហានបារាំង(មាត្រា៤)។ |
| **១១៤- អនុសញ្ញាបារាំង-កម្ពុជា ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤**<br>អ. Franco-Cambodian Convention of 17 June 1884<br>បារ.Convention Franco-Cambodgienne du 17 juin 1884 | អនុសញ្ញាដែលត្រូវបានចុះហត្ថលេខា នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤ នៅព្រះរាជវាំងភ្នំពេញ រវាងព្រះបាទនរោត្តម និង លោក សាល ថមសុន (Charles Thomson) ដែលជាទេសាភិបាលបារាំងនៅកូសាំងស៊ីន។ អនុសញ្ញាដែលមានចំនួន១១មាត្រានោះ មានចែងជាអាទិ៍ថា៖<br>- ព្រះរាជាកម្ពុជាទទួលយករាល់កំណែទម្រង់រដ្ឋបាល តុលាការ ហិរញ្ញវត្ថុ និងពាណិជ្ជកម្ម ដែលរដ្ឋាភិបាលសាធារណរដ្ឋបារាំងយល់ថា នឹងមានប្រយោជន៍ដល់ដំណើរការអនុវត្តរបបអាណាព្យាបាលរបស់ខ្លួន នៅពេលអនាគត(មាត្រា១)។<br>- ព្រះរាជាកម្ពុជានឹងបន្តគ្រប់គ្រងរដ្ឋនិងដឹកនាំរដ្ឋបាល ដូចក្នុងអតីតកាល លើកលែងតែការកម្រិតនានាដែលមានចែងនៅក្នុងអនុសញ្ញានេះ (មាត្រា២)។<br>- មន្ត្រីខ្មែរនឹងនៅបន្តគ្រប់គ្រងអាណាខេត្តក្រោមការត្រួតពិនិត្យពីអាជ្ញាធរបារាំង លើកលែងតែកិច្ចការណាដែលទាក់ទងនឹងការធ្វើបញ្ជីនិងការទារពន្ធដារ ពន្ធគយ វិភាគទានមិនផ្ទាល់ សាធារណការ និងជាទូទៅ កិច្ចការដែលតម្រូវឱ្យមានការដឹកនាំតែមួយ ឬការប្រើប្រាស់វិស្វករឬភ្នាក់ងារអឺរ៉ុប (មាត្រា៣)។<br>- ទាសភាពត្រូវលុបចោល នៅលើផ្ទៃនៃព្រះរាជាណាចក្រកម្ពុជាទាំងមូល (មាត្រា៨)។ |
| **១១៥- កុងស៊ីយ៍សេនាបតី**<br>អ. Council of Ministers<br>បារ. Conseil des Ministres | ក្រុមប្រឹក្សារដ្ឋមន្ត្រីឬគណៈរដ្ឋមន្ត្រីខ្មែរ ដែលត្រូវបានបង្កើតឡើងតាមព្រះរាជប្រកាសចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៨៩៧ ហើយដែលមានរដ្ឋមន្ត្រី៥រូបគឺ អគ្គ-មហាសេនា យមរាជ ក្រឡាហោម ចក្រី និងវាំង និងមានភារកិច្ចពិនិត្យនិងអនុវត្តច្បាប់ព្រមទាំងធ្វើការសិក្សាលើកំណែទម្រង់ឬការផ្លាស់ប្តូរដែលអាចនឹងកើតមាន។ ក្រុមប្រឹក្សាធ្វើការសម្រេចដោយមិនមានវត្តមានរបស់ព្រះរាជាខ្មែរនៅក្រោមអធិបតីភាពរបស់រ៉េស៊ីដង់ជាន់ខ្ពស់ បន្ទាប់មកដាក់ថ្វាយព្រះរាជាខ្មែរនូវវិធានការនយោបាយនិងរដ្ឋបាល ដែលមានប្រយោជន៍ចំពោះប្រទេស។ |

| | |
|---|---|
| **១១៦- ការដកថយរបស់សៀមពីភូមិភាគឦសានកម្ពុជា**<br>អ. Siamese withdrawal from North-East Cambodia<br>បារ. Retrait siamois du Nord-Est du Cambodge | ការដកថយរបស់សៀមពីទឹកដីកម្ពុជា ពីតំបន់ឆ្លូងលើនៅឆ្នាំ១៨៩០ និងពីត្រើយខាងកើតទន្លេមេគង្គនៃខេត្តស្ទឹងត្រែងនៅឆ្នាំ១៨៩៣។ ខេត្តមណ្ឌលគិរីបច្ចុប្បន្ន ពីមុនមានឈ្មោះថាតំបន់ឆ្លូងលើ ជាតំបន់ដែលមានប្រជាជនតិចនៃប្រទេសកម្ពុជា។ នៅចន្លោះឆ្នាំ១៨៦៦និង១៨៧៥ ព្រះបាទនរោត្តមបានចាប់ផ្ដើមពង្រឹងអំណាចខ្មែរនៅតំបន់ឆ្លូងលើ ហើយនៅឆ្នាំ១៨៨៤ ចៅហ្វាយខេត្តខ្មែរម្នាក់បានទៅគ្រប់គ្រងនៅស្រែខ្ទុម។ នៅពាក់កណ្ដាលទី២នៃសតវត្សរ៍ទី១៩នោះដែរ ពួកសៀមបានបន្តការលុកលុយនៅក្នុងតំបន់នោះ។<br>ការដកថយដោយបង្ខំរបស់សៀមចេញពីតំបន់នោះ មានប្រវត្តិដ៏អស្ចារ្យមួយ។ មេបញ្ជាការសៀមម្នាក់ដែលបញ្ជាទាហានឡាវ៣៧០នាក់ ទាហានសៀម២២នាក់និងដំរី១៤ក្បាល បានបោះទីតាំងនៅតំបន់បានដន(គឺភូមិកោះនៅចម្ងាយ៣០គីឡូម៉ែត្រខាងកើតព្រំដែនខេត្តមណ្ឌលគិរីសព្វថ្ងៃនិងក្នុងទឹកដីវៀតណាមសព្វថ្ងៃ) នៅខែកុម្ភៈ ឆ្នាំ១៨៩០។ លោកអនុសេនីយ៍ឯកបារាំងឈ្មោះ គុយប៉េ (Cupet) ដែលអមដំណើរដោយទាហានខ្មែរម្នាក់ ត្រូវបានបញ្ជូនទៅកាន់ទីនោះដើម្បីបញ្ឈប់ដំណើររបស់ទ័ពសៀម។ លោកអនុសេនីយ៍ឯកបានបញ្ជាដាច់ណាត់ឱ្យទ័ពសៀមត្រឡប់ក្រោយវិញ។ ទ័ពសៀមបានគោរពតាម ដោយដកថយក្រោយឆ្ពោះទៅកាន់ស្ទឹងត្រែង នៅក្រោមការវាយប្រហារពីអ្នកភូមិ ដែលនៅចងចាំអំពីអំពើឃោរឃៅរបស់សៀម ហើយនៅឆ្នាំ១៨៩៣ ទ័ពសៀមបានឆ្លងផុតទន្លេមេគង្គជាស្ថាពរទៅទិសខាងលិច តាមរយៈសន្ធិសញ្ញាបារាំង-សៀម ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ១៨៩៣។<br><br> |
| **១១៧- ការដកថយរបស់សៀមពីភូមិភាគឧត្តរកម្ពុជា** | ការដកថយរបស់សៀមពីទឹកដីកម្ពុជា ចេញពីខេត្តម្លូព្រៃនិងទន្លេរពៅ ដែលស្ថិតនៅត្រើយខាងលិចនៃទន្លេមេគង្គនិងដែលមាន «ប្រាសាទព្រះវិហារ» នៅក្នុងនោះ តាមរយៈអនុសញ្ញាបារាំង-សៀម ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩០៤។ |

| | |
|---|---|
| អ. Siamese withdrawal from North Cambodia<br>បារ. Retrait siamois du Nord du Cambodge | <br><br>ផែនទីខាងលើនេះបង្ហាញពីការដកថយរបស់ទ័ពសៀមចេញពីទឹកដីខ្មែរនៅភូមិភាគឦសាន ខាងជើង និងពាយ័ព្យ ជា៤ដំណាក់កាលគឺៈ<br>- នៅឆ្នាំ១៨៩០ ដកពីធ្លូងលើ<br>- នៅឆ្នាំ១៨៩៣ ដកពីខេត្តស្ទឹងត្រែង<br>- នៅឆ្នាំ១៩០៤ ដកពីខេត្តម្លូព្រៃនិងទន្លេរពៅ និង<br>- នៅឆ្នាំ១៩០៧ ដកពីខេត្តបាត់ដំបង សៀមរាប និងសិរីសោភ័ណ។ |
| **១១៨- ការដកថយរបស់សៀមពីភូមិភាគពាយ័ព្យកម្ពុជា**<br>អ. Siamese withdrawal from North-West Cambodia<br>បារ. Retrait siamois du Nord-Ouest du Cambodge | ការដកថយរបស់សៀមពីទឹកដីកម្ពុជាចេញពីខេត្តបាត់ដំបង សៀមរាប និងសិរីសោភ័ណ តាមរយៈសន្ធិសញ្ញាបារាំង-សៀមថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩០៧។ បន្ទាប់មក បារាំងបានថ្វាយខេត្តទាំង៣នោះមកសម្តេចព្រះបាទស៊ីសុវត្ថិ នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩០៧។<br>រូបសំណាកសម្តេចព្រះស៊ីសុវត្ថិ នៅវត្តភ្នំ រាជធានីភ្នំពេញ ដោយមានរូបទេពធីតា៣អង្គកាន់ជើងពាន៣មកថ្វាយដែលតំណាងខេត្តទាំង៣រំលឹកពីការថ្វាយនូវខេត្តទាំង៣នោះចំពោះព្រះអង្គនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩០៧។ រូបសំណាកនេះស្ថិតនៅវត្តភ្នំប៉ែកខាងត្បូង(សម្ពោធនៅឆ្នាំ១៩០៩)។<br>  |
| **១១៩- ការអប់រំបែបផ្លូវការ**<br>អ. Official education<br>បារ. Enseignement officiel | ការអប់រំនៅក្នុងសាលាបារាំង-ខ្មែរនៅសម័យអាណាព្យាបាលបារាំង ដែលមានកម្មវិធីសិក្សាជាភាសាបារាំងនិងជាភាសាខ្មែរចាប់ពីបឋមសិក្សាដល់មធ្យមសិក្សា។<br>ការអប់រំបែបផ្លូវការនេះមានលក្ខណៈជាប្រព័ន្ធ គឺចាប់ពីសាលាបឋមសិក្សា |

| | |
|---|---|
| | ជាន់ដំបូង(Ecole primaire élémentaire) ដែលមាន៣ថ្នាក់(ទី១២ ទី១១ និងទី១០) សាលាបឋមសិក្សាបំពេញវិជ្ជា(Ecole primaire complémentaire) ដែលបន្ថែម៣ថ្នាក់ទៀត(ទី៩ ទី៨ និងទី៧) អនុវិទ្យាល័យដែលមាន៤ថ្នាក់ (ទី៦ ទី៥ ទី៤ និងទី៣) និងវិទ្យាល័យដែលបន្ថែម៣ថ្នាក់ទៀត(ទី២ ទី១និងទីបញ្ចប់)។ នៅក្រុងភ្នំពេញ ការអប់រំផ្លូវការក្នុងសាលាបារាំង-ខ្មែរបានចាប់ផ្ដើមពីអនុវិទ្យាល័យអាណាព្យាបាលដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៨៩៣។<br>អនុវិទ្យាល័យនេះបានក្លាយជាសាលាបឋមសិក្សាជាន់ខ្ពស់ (សាលាព្រះស៊ីសុវត្ថិ) នៅឆ្នាំ១៩០៥ និងបានឡើងជាអនុវិទ្យាល័យព្រះស៊ីសុវត្ថិនៅឆ្នាំ ១៩១១ និងបានក្លាយជាវិទ្យាល័យនៅឆ្នាំសិក្សា១៩៣៥-១៩៣៦។<br><br>Photo : In Norodom Sihanouk,... Cambodge (Annees 1960) |
| **១២០- ការអប់រំបែបប្រពៃណី**<br>អ. Traditional education<br>បារ. Enseignement traditionnel | ការអប់រំនៅក្នុងសាលាវត្តកែប្រែថ្មី (Ecole de pagode rénovée) នៅប្រទេសកម្ពុជា ក្នុងសម័យអាណាព្យាបាលបារាំង ដែលមានកម្មវិធីសិក្សាជាភាសាខ្មែរ នៅតាមវត្តអារាម មានថ្នាក់រៀនរួមគ្នា (លែងរៀនដោយឡែកៗតាមកុដិព្រះសង្ឃ) មានកម្មវិធីសិក្សាច្បាស់លាស់ប្រចាំឆ្នាំ(ពេលសិក្សានិងវិស្សមកាល) មានព្រះសង្ឃជាគ្រូបង្រៀន មានសិស្សជាក្មេងប្រុស និងមានរយៈពេលតែបីឆ្នាំ ហើយដែលត្រូវបានចាត់ទុកថាជាការអប់រំបែបប្រពៃណីដែលមានការកែទម្រង់នៅសម័យបារាំងនិងបន្តមកសម័យឯករាជ្យ។<br>បន្ទាប់ពីមានការបង្កើតសាលាវត្តកែប្រែថ្មីនៅឆ្នាំ១៩០៨នៅខេត្តកំពង់ចាម ព្រះរាជប្រកាសចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩១១ តម្រូវឱ្យរៀនភាសាខ្មែរនៅគ្រប់វត្តអារាមទូទាំងប្រទេស។ ឪពុកម្ដាយដែលមានកូនប្រុសគ្រប់អាយុ៨ឆ្នាំត្រូវបញ្ជូនកូនឱ្យទៅរៀននៅសាលាវត្ត។ ចាប់ពីឆ្នាំ១៩១២ អ្នកមិនគោរពតាមព្រះរាជប្រកាសនេះត្រូវទទួលការពិន័យ។ សាលាវត្តកែប្រែថ្មីមានជោគជ័យពិតប្រាកដនៅខេត្តកំពតពីឆ្នាំ១៩២៤ដល់ឆ្នាំ១៩៣០ និង មានការអភិវឌ្ឍទូទាំងប្រទេសចាប់ពីឆ្នាំ១៩៣១។ ចាប់ពីឆ្នាំសិក្សា១៩៣៥-១៩៣៦ ក្មេងស្រីជាច្រើននាក់ត្រូវបានអនុញ្ញាតឱ្យចូលរៀននៅក្នុងសាលាវត្តកែប្រែថ្មីជាលើកដំបូង (សាលា ដែលបង្រៀនដោយព្រះសង្ឃ)។ |

| | |
|---|---|
| **១២១- ការអប់រំបែបសាសនា**<br>អ. Religious education<br>បារ. Enseignement religieux | ការអប់រំនៅក្នុងសាលាបរិយត្តិឬសាលាបាលីនៅក្រុងភ្នំពេញ ចាប់ផ្ដើមនៅឆ្នាំ១៩១៤ ក្នុងសម័យអាណាព្យាបាលបារាំង សម្រាប់បណ្ដុះបណ្ដាលព្រះសង្ឃពុទ្ធសាសនានៅក្នុងប្រទេសកម្ពុជា ផ្នែកចំណេះទូទៅ ជាពិសេសភាសាបាលី និងពុទ្ធសាសនា។ សាលាបរិយត្តិនៅក្រុងភ្នំពេញ ដែលត្រូវបានបង្កើតដោយព្រះរាជប្រកាសចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩១៤នោះ បានក្លាយជាសាលាបរិ-យត្តិជាន់ខ្ពស់ឬសាលាបាលីជាន់ខ្ពស់នៅឆ្នាំ១៩២២។ នៅឆ្នាំ១៩៣៣ មានការបង្កើតសាលាបាលីរង (Ecole élémentaire de Pali) នៅទូទាំងប្រទេស។ សាលាបាលីជាន់ខ្ពស់បានប្រែឈ្មោះមកជា ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត នៅឆ្នាំ១៩៥៥។ ពុទ្ធិកឧត្ដមសិក្សាបានចាប់ផ្ដើមនៅពេលបង្កើតពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ នៅឆ្នាំ១៩៥៤។ |
| **១២២- ខ្មែរនីយកម្មក្នុងតំបន់ដាច់ស្រយាលកម្ពុជា**<br>អ. Khmerization in remote areas of Cambodia<br>បារ. Khmérisation dans les régions éloignées du Cambodge | សកម្មភាពផ្សព្វផ្សាយភាសានិងវប្បធម៌ខ្មែរទៅកាន់តំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា តាមរយៈសាលាវត្តកែប្រែថ្មីនៅសម័យអាណាព្យាបាលបារាំង។ សាលាវត្តកែប្រែថ្មី ក្រៅពីជួយបណ្ដុះបណ្ដាលកូនកសិករខ្មែរ នៅតំបន់វាលរាបកណ្ដាល ក៏បានផ្ដល់ផលប្រយោជន៍ខាងនយោបាយដល់រដ្ឋាភិបាលកម្ពុជា តាមរយៈសកម្មភាពផ្សព្វផ្សាយភាសានិងវប្បធម៌ខ្មែរទៅកាន់តំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា។ នៅឆ្នាំ១៩៣៤ ព្រះសង្ឃ៨អង្គបាននិមន្តពីក្រុងភ្នំពេញទៅសម្ពោធវត្តមួយនៅក្នុងប៉ុស្ដិ៍ឡឺរ៉ូឡង់(Poste Le Roland) ក្នុងតំបន់ខ្ពង់រាបខ្ពស់ (ខេត្តមណ្ឌលគិរីសព្វថ្ងៃ) ហើយគង់នៅទីនោះដើម្បីបង្រៀនភាសានិងវប្បធម៌ខ្មែរដល់ជនជាតិព្នង។ ក្នុងពេលជំណាលគ្នានោះ ព្រះសង្ឃ២អង្គគង់នៅវត្តអង្គសុភី ស្រុកកំពង់ត្រាច ខេត្តកំពត បាននិមន្តទៅខេត្តកោះកុង ដើម្បីបង្កើតសាលាវត្តកែប្រែថ្មី និងបង្រៀនភាសាខ្មែរនៅទីនោះ។ នៅក្នុងខេត្តបាត់ដំបង តាមដងស្ទឹងមង្គលបុរី(បច្ចុប្បន្ន ស្ទឹងនេះកាត់ចូលមកខេត្តបន្ទាយមានជ័យ) ព្រះសង្ឃបានបង្រៀនភាសាខ្មែរដល់សិស្សជនជាតិឡាវនិងសៀម។ សកម្មភាពខ្មែរនីយកម្មនេះក៏បានធ្វើនៅក្នុងចំណោមជនជាតិសម្រែ និងកួយនៅខេត្តកំពង់ធំព្រមទាំងជនជាតិស្ទៀងនិងព្នងនៅខេត្តក្រចេះ នៅក្នុងសម័យនោះដែរ។ |
| **១២៣- ម៉ាស៊ីនចុះហត្ថលេខា**<br>អ. Signing Machines<br>បារ. Machines à signer | ពាក្យរបស់សម្ដេចព្រះនរោត្តម សីហនុ នៅឆ្នាំ១៩៧២ ដែលបានហៅព្រះរាជាខ្មែរទាំងឡាយ ជាអាទិ៍ព្រះបាទមុនីវង្ស នៅសម័យអាណាព្យាបាលបារាំងពីឆ្នាំ១៨៨៤ដល់ឆ្នាំ១៩៤៥ ដែលចាំតែឡាយព្រះហស្ដលេខាលើលិខិតបទ-ដ្ឋានគតិយុត្ត ដែលកុង្ស៊ីយ៍សេនាបតីនៅក្រោមរ៉េស៊ីដង់ជាន់ខ្ពស់បារាំងបានរៀបចំថ្វាយ។<br>ចំពោះប្រវត្តិវិទូ ជាអាទិ៍ឯកឧត្ដមបណ្ឌិតសភាចារ្យ ស៊ិន សំណាង យល់ឃើញថា ម៉ាស៊ីនចុះហត្ថលេខានេះ ស្ដែងពីព្រះមហាក្សត្រខ្មែរដែលគ្រាន់តែឡាយព្រះហស្ដលេខាលើលិខិតផ្លូវការដោយមិនបានអាន ចាប់ពីឆ្នាំ១៨៩៧ រហូតដល់ឆ្នាំ១៩៤៥។ |

| | |
|---|---|
| **១២៤- សាលាវត្តកែប្រែថ្មី**<br>អ. Renovated pagoda school<br>បារ. Ecole de pagode rénovée | សាលារៀននៅក្នុងវត្ត ដែលបានអប់រំសិស្សប្រុសខ្មែរតាមបែបប្រពៃណី ប៉ុន្តែមានការកែទម្រង់ ដើម្បីឱ្យការអប់រំនោះមានប្រសិទ្ធភាពជាងមុន។ សាលាវត្តកែប្រែថ្មីនៅប្រទេសកម្ពុជាដែលបានចាប់ផ្តើមពីសម័យអាណាព្យាបាលបារាំង ហើយបន្តមកដល់សម័យឯករាជ្យមានថ្នាក់រៀនរួមគ្នា(លែងរៀនដោយឡែកៗតាមកុដិព្រះសង្ឃ)មានកម្មវិធីសិក្សាច្បាស់លាស់ប្រចាំឆ្នាំ(ពេលសិក្សា វិស្សមកាល ...) មានព្រះសង្ឃជាគ្រូបង្រៀន មានសិស្សជាក្មេងប្រុស មានថ្នាក់ទី១២ ទី១១ និងទី១០ និងរៀនតែពេលរសៀលពីម៉ោង២ទៅម៉ោង៥កន្លះ។ |
| **១២៥- សាលាវត្តកែប្រែថ្មីនៅខេត្តកំពង់ចាម**<br>អ. Renovated pagoda school of Kampong Cham province<br>បារ. Ecole de pagode rénovée de la province de Kampong Cham | សាលាវត្តកែប្រែថ្មីនៅខេត្តកំពង់ចាមបានចាប់ផ្តើមក្នុងឆ្នាំ១៩០៨ នៅខេត្តកំពង់ចាម ដោយសារមន្ត្រីបារាំង២នាក់គឺ លោកបូដូវាំង(Baudoin) ជាចៅហ្វាយខេត្ត និងលោកមើនើទ្រីយេ(Menetrier) ជានាយកសាលាទីរួមខេត្ត (សាលាទក្សិណ)។ ដោយមានការគាំទ្រពីព្រះសង្ឃ និងប្រជាកសិករខ្មែរ សាលាវត្តកែប្រែថ្មីនៅខេត្តកំពង់ចាម មានការរីកចម្រើនយ៉ាងលឿន ដោយសារសាលានៅជិតផ្ទះ កូនខ្មែរស្រុកស្រែចម្ការអាចចេះអក្សរ ចេះលេខ ចេះប្រវត្តិសាស្ត្រ និងវប្បធម៌ខ្មែរ សមល្មមអាចកសាងជីវភាពរស់នៅបានសមរម្យក្នុងសង្គមប្រពៃណីនិយមនេះ។ ប៉ុន្តែ ទន្ទឹមនឹងនេះ បារាំងបានដាក់បញ្ចូលភាសាបារាំងទៅក្នុងកម្មវិធីសិក្សា និងចាត់ឱ្យគ្រូបង្រៀនជាគ្រហស្ថទៅធ្វើអធិការកិច្ចលើការបង្រៀនរបស់ព្រះសង្ឃ។ គឺចំណុចទាំងពីរនេះហើយដែលនាំឱ្យព្រះសង្ឃលែងគាំទ្រ ហើយសាលានេះក៏ត្រូវបញ្ចប់នៅខេត្តកំពង់ចាមនៅឆ្នាំ១៩១៦។<br><br>សាលាទក្សិណ |
| **១២៦- សាលាវត្តកែប្រែថ្មីនៅខេត្តកំពត**<br>អ. Renovated pagoda school of Kampot province<br>បារ. Ecole de pagode rénovée de la province de Kampot | សាលាវត្តកែប្រែថ្មីនៅខេត្តកំពតបានចាប់ផ្តើមឡើងវិញ ក្នុងឆ្នាំ១៩២៤ នៅខេត្តកំពត ដោយសារលោកមើនើទ្រីយេ(Menetrier) ដែលបានផ្លាស់ទៅនៅខេត្តនេះ។ ដោយផ្អែកលើបទពិសោធន៍ពីកំពង់ចាមនោះ សាលាវត្តកែប្រែថ្មីមានតែកម្មវិធីសិក្សាជាភាសាខ្មែរប៉ុណ្ណោះ មានអធិការបារាំងដែលចេះភាសាខ្មែរ និងមានការបណ្តុះបណ្តាលគរុកោសល្យដល់ព្រះសង្ឃជាគ្រូបង្រៀនជាមុននៅក្នុង «សាលាអនុវត្តន៍» (Ecole d'Application) សម្រាប់ព្រះសង្ឃ ដែលមាននាយកសាលាជាគ្រូបង្រៀនមកពីសាលាផ្លូវការ(មានទាំងសីលធម៌ និង |

| | |
|---|---|
| | ជំនាញវិជ្ជាជីវៈខ្ពស់)។ សាលាអនុវត្តន៍បានចាប់ផ្តើមពីវត្តជុំគ្រៀល និងបានបន្តទៅវត្តសំខាន់ៗដទៃទៀត នៅក្នុងខេត្តកំពត។ សាលាវត្តកែប្រែថ្មីមានជោគជ័យពិតប្រាកដនៅខេត្តកំពត ពីឆ្នាំ១៩២៤ដល់ឆ្នាំ១៩៣០។<br> <br><br>វត្តជុំគ្រៀល ជាសាលាអនុវត្តន៍សម្រាប់ព្រះសង្ឃដំបូង<br>ផែនទីបង្ហាញអំពីសាលាអនុវត្តន៍នានានៅខេត្តកំពត |
| **១២៧- សាលាវត្តកែប្រែថ្មីទូទាំងប្រទេស**<br>អ. Renovated pagoda school through out Cambodia<br>បារ. Ecole de pagode rénovée dans tout le pays | សាលាវត្តកែប្រែថ្មីបានចាប់ផ្តើមក្នុងឆ្នាំ១៩០៨ នៅខេត្តកំពង់ចាម និងត្រូវបញ្ចប់នៅឆ្នាំ១៩១៦។ សាលាវត្តកែប្រែថ្មីបានចាប់ផ្តើមឡើងវិញក្នុងឆ្នាំ១៩២៤ នៅខេត្តកំពត និងមានជោគជ័យនៅខេត្តនោះ ពីឆ្នាំ១៩២៤ដល់ឆ្នាំ១៩៣០។ ចាប់ពីឆ្នាំ១៩៣១ មានការបង្កើតសាលាវត្តកែប្រែថ្មី នៅទូទាំងប្រទេស។ ក្មេងស្រីជាច្រើននាក់ ត្រូវបានអនុញ្ញាតឱ្យចូលរៀននៅក្នុងសាលាវត្តកែប្រែថ្មី ជាលើកដំបូងចាប់ពីឆ្នាំសិក្សា១៩៣៥-១៩៣៦។ កម្មវិធីសិក្សានៅសាលាវត្តកែប្រែថ្មីបានផ្តល់ជាពិសេសដល់សិស្សនូវចំណេះដឹងដែលមានប្រយោជន៍សម្រាប់ជីវភាពប្រចាំថ្ងៃ ដូចជា ការចេះអាននិងសរសេរ ការចេះគិតលេខ ការចេះប្រើរង្វាស់រង្វាល់នានា ការចេះសរសេរលិខិតផ្សេងៗ(ការតវ៉ា ការទិញដូរ បំណុល...)។ ក្រៅពីនេះ មានកម្មវិធីបង្រៀនប្រវត្តិសាស្ត្រខ្មែរពីពេលចាប់ផ្តើមជោគជ័យនៃព្រះមហាក្សត្រដែលបានកសាងអង្គរ បុព្វហេតុនៃការធ្លាក់ចុះ កិច្ចខិតខំរបស់បារាំងដើម្បីជួយសង្គ្រោះខ្មែរឱ្យផុតពីគ្រោះមហន្តរាយ និងការកសាងមាតុភូមិខ្មែរឡើងវិញឱ្យបានធំ និងសម្បូណ៌រុងរឿង។ |
| **១២៨- បណ្ណសារដ្ឋានជាតិកម្ពុជា**<br>អ. National Archives of Cambodia<br>បារ. Archives Nationales du Cambodge | មជ្ឈមណ្ឌលតម្កល់ឯកសារដើម(បណ្ណសារ)នៃព្រះរាជាណាចក្រកម្ពុជា ចាប់តាំងពីរបបអាណាព្យាបាលបារាំងរហូតមកដល់បច្ចុប្បន្ន។<br>បទបញ្ញត្តិនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩១១ ដែលចេញដោយលោករេស៊ីដង់ជាន់ខ្ពស់បារាំងនៅកម្ពុជាបានបង្កើតបណ្ណសារដ្ឋានជាផ្លូវការ។ តាមរយៈលោក ប៉ូល ប៊ូដេ(Paul Boudet) នៅឆ្នាំ១៩១៧និងឆ្នាំ១៩១៨ បទបញ្ញត្តិនានាត្រូវបានបង្កើតឡើងសម្រាប់រៀបចំចំណាត់ថ្នាក់ឯកសារទៅតាមវិស័យសម្រាប់តម្កល់ |

| | |
|---|---|
| | ទុកនៅក្រុងភ្នំពេញ នៅក្រុងហាណូយ និងក្រុងប៉ារីស។ សព្វថ្ងៃបណ្ណសារក្រុងប៉ារីសត្រូវតម្កល់ទុកនៅ *បណ្ណសារដ្ឋានឯនាយសមុទ្រ(Archives d'Outre-Mer)* នៅទីក្រុងអ៊ិចអង់ប្រូវ៉ង់(Aix-en-Provence) ដែលស្ថិតភាគខាងត្បូងនៃប្រទេស បារាំង។<br>អគារបណ្ណសារដ្ឋានជាតិត្រូវបានសាងសង់នៅខែធ្នូ ឆ្នាំ១៩២៤ និងបានដាក់ឱ្យប្រើប្រាស់នៅខែតុលា ឆ្នាំ១៩២៦ ហើយសព្វថ្ងៃមានទីតាំងនៅខាងលិចវត្តភ្នំ ក្រោយបណ្ណាល័យជាតិ។ ពីឆ្នាំ១៩៥៤ដល់ឆ្នាំ១៩៧៥ បណ្ណសារ-ដ្ឋានស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលកម្ពុជា។ បណ្ណសារដ្ឋានជាតិត្រូវបានរៀបចំជាមជ្ឈមណ្ឌលតម្កល់ឯកសារជាតិឡើងវិញ ចាប់ពីឆ្នាំ១៩៨០ដល់បច្ចុប្បន្ន។<br> |
| **១២៩- សារមន្ទីរជាតិ**<br>អ. National Museum of Cambodia<br>បារ. Musée national du Cambodge | មជ្ឈមណ្ឌលប្រមូលផ្តុំសម្បត្តិវប្បធម៌ និងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាដែលត្រូវបានចាប់ផ្តើមរៀបចំនៅឆ្នាំ១៩០៥ នៅក្នុងព្រះបរមរាជវាំង។ នៅឆ្នាំ១៩១៤ លោកហ្សក ហ្គ្រោលីយេ(George Groslier) បានទទួលភារកិច្ចពីអគ្គទេសាភិបាលឥណ្ឌូចិន និងព្រះមហាក្សត្រខ្មែរឱ្យដឹកនាំការសាងសង់សារមន្ទីរជាតិនៅទីតាំងបច្ចុប្បន្ន។ បន្ទាប់មក ការសាងសង់បានចាប់ផ្តើមនៅឆ្នាំ១៩១៧ ហើយពិធីសម្ពោធបានប្រព្រឹត្តទៅនៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩២០ ក្រោមព្រះរាជាធិបតីភាព ព្រះបាទសម្តេចស៊ីសុវត្ថិ និងមានឈ្មោះថា សារមន្ទីរ អាល់ប៊ែ សារ៉ូ (Musée Albert Sarraut) ដែលជាឈ្មោះរបស់អគ្គទេសាភិបាលឥណ្ឌូចិនពីឆ្នាំ១៩១១ដល់ឆ្នាំ១៩១៤ ដោយសារតែគុណបំណាច់របស់លោកក្នុងការបញ្ជូនវត្ថុបុរាណ ដែលជាសម្បត្តិវប្បធម៌ខ្មែរពីទីក្រុងព្រៃនគរមកតម្កល់ទុកនៅភ្នំពេញវិញ។ មុនពេលសម្ពោធ សារមន្ទីរនេះមានឈ្មោះថា សារមន្ទីរក្រុងកម្ពុជាធិបតី។ នៅឆ្នាំ១៩៥០ សារមន្ទីរនេះបានប្តូរឈ្មោះមកជាសារមន្ទីរជាតិនៃកម្ពុជា និងបានប្រែក្លាយជាសារមន្ទីរវត្ថុបុរាណនៅក្រោយឆ្នាំ១៩៧៩។ ចាប់ពីឆ្នាំ១៩៨៦មក សារមន្ទីរនេះបានប្តូរឈ្មោះមកជាសារមន្ទីរជាតិនៃកម្ពុជាវិញរហូតដល់សព្វថ្ងៃ។ |

| | |
|---|---|
| **១៣០- រេស៊ីដង់ជាន់ខ្ពស់**<br>អ. Résident supérieur/<br>Resident Superior<br>បារ. Résident supérieur | មន្ត្រីបារាំងថ្នាក់ជាតិខ្ពស់បំផុតជាអ្នកតំណាងផ្លូវការនៃរដ្ឋាភិបាលបារាំងប្រចាំនៅប្រទេសកម្ពុជា នាសម័យអាណាព្យាបាលបារាំង។<br>មន្ត្រីដែលជាអ្នកតំណាងរដ្ឋាភិបាលបារាំងនៅប្រទេសកម្ពុជាក្នុងរបបអាណាព្យាបាលបារាំង មានងារជាលំដាប់ដូចតទៅ៖<br>- អ្នកតំណាងរបបអាណាព្យាបាល (Représentant du Protectorat) ពីឆ្នាំ១៨៦៣ដល់ឆ្នាំ១៨៨៥ ដូចជាលោក ឌូដាដឺឡាគ្រេ (Doudart de Lagrée) ជាដើម។<br>- អគ្គរេស៊ីដង់ (Résident général) ពីឆ្នាំ១៨៨៥ដល់ឆ្នាំ១៨៨៩ ដូចជាលោក ពិចកេ (Piquet) ជាដើម។<br>- រេស៊ីដង់ជាន់ខ្ពស់ (Résident supérieur) ពីឆ្នាំ១៨៨៩ដល់ឆ្នាំ១៩៤៥ ដូចជាលោក ហ្គោដេ (Gautier) ជាដើម។<br>ប៉ុន្តែក្នុងឯកសារផ្លូវការជាភាសាខ្មែរ ងាររពេញរបស់រេស៊ីដង់ជាន់ខ្ពស់ដែលត្រូវបានប្រើក្នុងលិខិតផ្លូវការនៅសម័យនោះ (ឧ.ខេត្តក្រាតឆ្នាំ១៩០៦) គឺ«លោកឡឺរ៉េស៊ីដង់ សូប៉េរីយ៉ឺ ដឺឡារេពូព្លិក បារាំងសែស្ន ក្នុងក្រុងកម្ពុជា» (Résident supérieur de la République française au Cambodge)។<br><br><br>លិខិតចៅហ្វាយស្រុកខេត្តក្រាតផ្ញើជូនលោករេស៊ីដង់ជាន់ខ្ពស់នៅភ្នំពេញស្តីពីការចាប់អាកៀននៅខេត្តកោះកុង ក្នុងខែវិច្ឆិកា ឆ្នាំ១៩០៦ជាភាសាខ្មែរ |
| **១៣១- រេស៊ីដង់រួមខេត្ត**<br>អ. Résident de France<br>បារ. Résident de France | មន្ត្រីបារាំងថ្នាក់ក្រោមជាតិដែលគ្រប់គ្រងលើទីរេស៊ីដង់ (Circonscription résidentielle) ដែលមានខេត្តមួយចំនួននៅក្រោមឱវាទ (មុនឆ្នាំ១៩២១) និងស្រុកមួយចំនួននៅក្រោមឱវាទ (ក្រោយឆ្នាំ១៩២១)។ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩២១ វិស័យរដ្ឋបាលត្រូវបានរៀបចំឡើងវិញតាមរយៈព្រះរាជប្រកាសលេខ១០២ដោយមានការបង្កើត *ខណ្ឌ* នៅចន្លោះ *ស្រុក* និង *ឃុំ* ពោលគឺរដ្ឋបាលថ្នាក់ខេត្តមាន៖ ខេត្ត ស្រុក ខណ្ឌ ឃុំ។ ប៉ុន្តែគេបានលុបខណ្ឌចេញវិញនៅឆ្នាំ១៩៣៤។<br>ក្រោយឆ្នាំ១៩២១ ពាក្យ *ទីរេស៊ីដង់* ដែលគ្រប់គ្រងដោយបារាំងត្រូវបានប្រើ |

| | |
|---|---|
| | ជាបន្ត ប៉ុន្តែពាក្យ*ខេត្ត(Province)* ដែលគ្រប់គ្រងដោយចៅហ្វាយស្រុកត្រូវបានប្តូរមកជាពាក្យ*ស្រុក(Srok)*(ដែលគ្រប់គ្រងដោយចៅហ្វាយស្រុក)។<br>ងាររបស់រេស៊ីដង់រួមខេត្តដែលត្រូវបានប្រើក្នុងលិខិតផ្លូវការនោះគឺ«រេស៊ីដង់បារាំង ...» (Résident de France ...)។<br>ឧ. លោកឡឺរេស៊ីដង់ជីប្រហ្វង់ កំពត។<br><br><br><br> |
| **១៣២- ចៅហ្វាយស្រុកក្រោមអាណាព្យាបាលបារាំង**<br>អ. Governor/ Chauvai-Srok under the French Protectorate<br>បារ. Gouverneur/ Chauvai-Srok sous le Protectorat français | មន្ត្រីខ្មែរថ្នាក់ក្រោមជាតិគ្រប់គ្រងលើខេត្តដែលនៅក្រោមឱវាទទីរេស៊ីដង់ (មុនឆ្នាំ១៩២១) និងគ្រប់គ្រងលើស្រុក(ក្រោយឆ្នាំ១៩២១)។ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩២១ វិស័យរដ្ឋបាលត្រូវបានរៀបចំឡើងវិញតាមរយៈព្រះរាជប្រកាសលេខ១០២ដោយមានការបង្កើត*ខណ្ឌ* នៅចន្លោះ*ស្រុក* និង*ឃុំ* ពេលគឺរដ្ឋបាលថ្នាក់ខេត្តមាន៖ ខេត្ត ស្រុក ខណ្ឌ ឃុំ។ ប៉ុន្តែគេបានលុបខណ្ឌចេញវិញនៅឆ្នាំ១៩៣៤។ ក្រោយឆ្នាំ១៩២១ ពាក្យ*ទីរេស៊ីដង់* ដែលគ្រប់គ្រងដោយបារាំងត្រូវបានប្រើជាបន្ត ប៉ុន្តែ ពាក្យ *ខេត្ត(Province)* ដែលគ្រប់គ្រងដោយចៅហ្វាយស្រុកត្រូវបានប្តូរមកជាពាក្យ*ស្រុក(Srok)*(ដែលគ្រប់គ្រងដោយចៅហ្វាយស្រុក)។<br>ឧ. មុនឆ្នាំ១៩២១ គេហៅថា ចៅហ្វាយស្រុកខែត្រកោះកុង ។ |

| | |
|---|---|
| |  |
| **១៣៣- ទីរេស៊ីដង់**<br>អ. Resident's Circumscription<br>បារ. Circonscription résidentielle | ដែនដីរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលគ្រប់គ្រងដោយរេស៊ីដង់បារាំងដោយមានខេត្តមួយចំនួននៅក្រោមឱវាទ(មុនឆ្នាំ១៩២១) ឬ ស្រុកមួយចំនួន(ក្រោយឆ្នាំ១៩២១)។<br>ដែនដីរដ្ឋបាលនេះក៏មានឈ្មោះថា *ទីរួមខេត្តរេស៊ីដង់* ផងដែរ ដែលនៅសម័យកាលនោះមានសរសេរជា *ទីរួមខែត្ររេស៊ីដង្ស* ខ្លះដែរ។<br>ឧ. «ទីរួមខែត្ររេស៊ីដង្ស ស្ទឹងត្រែង» នៅឆ្នាំ១៩១២។<br><br><br>**ទីរេស៊ីដង់កំពត នៅឆ្នាំ១៩០៥**<br>Circonscription résidentielle de Kampot en 1905<br><br> |
| **១៣៤- ខេត្តខ្មែរក្រោមអាណាព្យាបាលបារាំង** | ដែនដីរដ្ឋបាលថ្នាក់ក្រោមជាតិ(របៀបរាជ្ការរដ្ឋបាលស្រុកអាយ្យ) គ្រប់គ្រងដោយចៅហ្វាយស្រុកដែលជាមន្ត្រីខ្មែរ (មុននិងក្រោយឆ្នាំ១៩២១)។ ទំហំនៃដែនដីនោះនៅដដែល ប៉ុន្តែមុនឆ្នាំ១៩២១ គេហៅថាខេត្ត ហើយក្រោយឆ្នាំ |

| | |
|---|---|
| អ.Cambodian province under the French Protectorate<br>បារ. Province cambodgienne sous le Protectorat français | ១៩២១ គេហៅថាស្រុក។<br>ឧទាហរណ៍ នៅឆ្នាំ១៩១៧ ប្រទេសកម្ពុជាមាន៥១ខេត្ត។ ខេត្តទាំង៥១នោះ ត្រូវបានបែងចែកជា៦ប្រភេទ ដូចខាងក្រោម៖<br>១- ខេត្តផុតលេខ មាន៣ គឺបាត់ដំបង ត្បូងឃ្មុំ និងបាភ្នំ។<br>២- ខេត្តលេខ១ មាន៦ គឺកំពង់ស្វាយ ពោធិ៍សាត់ កំពង់សៀម កំពត រំដួល និងសំរោងទង។<br>៣- ខេត្តលេខ២ មាន៧ គឺសៀមរាប ទ្រាំង បាទី ពារាំង ព្រៃវែង ស្រីសន្ធរ និងបារាយណ៍។<br>៤- ខេត្តលេខ៣ មាន១០ គឺបន្ទាយមាស ស្វាយទាប ភ្នំពេញ សិរីសោភ័ណ រលាប្អៀរ ជើងព្រៃ កណ្តាល ស្ទឹង កៀនស្វាយ ភ្នំស្រួច និងលើកដែក។<br>៥- ខេត្តលេខ៤ មាន១២ គឺគងពិសី ព្រៃកប្បាស រមាសហែក លង្វែក ស្ទោង ស៊ីធរកណ្តាល សន្ទុក មុខកំពូល ស្ទឹងត្រែង ល្វាឯម បរិបូណ៌ និងស្ទឹងត្រង់។<br>៦- ខេត្តលេខ៥ មាន១៣ គឺក្រចេះ កំពង់លែង កំពង់សោម ខ្សាច់កណ្តាល ពញាឮ ជីក្រែង អន្លង់រាជ ធ្លង ក្រគរ មូលប៉ាមោក ទន្លេរពៅ ម្លូព្រៃ និងកោះកុង។ |
| **១៣៥- សង្គ្រាមបារាំង-សៀម ឆ្នាំ១៨៩៣**<br>អ. Franco-Siamese War of 1893<br>បារ. Guerre franco-siamoise de 1893 | ការប្រយុទ្ធគ្នាដោយប្រើនាវារវាងទាហានជើងទឹកបារាំងនិងសៀមនៅប៉ាក់ណាម(Paknam) ជាមាត់ពាមនៃទន្លេមេណាម(ទន្លេចៅប្រាយ៉ា) ក្នុងរាត្រីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៨៩៣ ដែលនៅក្នុងនោះ នាវាបារាំងពីរគ្រឿង គឺអាំងកុងស្តង់និងកូម៉ែត(Inconstant et Comète) បានទម្លាយរបាំងនាវាសៀមនៅប៉ាក់ណាមនិងទន្លេមេណាម ហើយបន្តដំណើរទៅមុខទៅចតនៅមុខស្ថានទូតបារាំង នៅក្រុងបាងកក ក្នុងថ្ងៃបុណ្យជាតិបារាំង ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៨៩៣។<br>ជាផលវិបាកនៃសង្គ្រាមនេះ នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៨៩៣ បារាំងបានដាក់ឱសានវាទឱ្យសៀមដកថយពីត្រើយខាងកើតទន្លេមេគង្គពីទឹកដីចិនរហូតដល់ទឹកដីកម្ពុជាភាគខាងជើង(ខេត្តស្ទឹងត្រែង)និងបានទាមទារឱ្យសៀមសងការបង់ខាតដែលបង្កឡើងចំពោះរដ្ឋបារាំងជាទឹកប្រាក់២លានហ្វ្រង់។ នៅថ្ងៃនោះដែរ ព្រះរាជាកម្ពុជាបានដាក់សំណើជាលាយលក្ខណ៍អក្សរទៅរដ្ឋាភិបាលបារាំងដើម្បីទាមទារយកមកវិញនូវខេត្តសៀមរាបនិងបាត់ដំបងដែលសៀមបានកាន់កាប់ពីពេលមុន។ ជ័យជម្នះរបស់បារាំងនេះបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើសន្ធិសញ្ញាបារាំង-សៀមថ្ងៃទី៣ ខែតុលា ឆ្នាំ១៨៩៣ ដែលតម្រូវឱ្យសៀមប្រគល់«ខេត្តស្ទឹងត្រែង» មកឱ្យកម្ពុជាវិញ ដោយត្រូវដកថយពីត្រើយខាងកើតទន្លេមេគង្គនិងពីកោះទាំងឡាយនៃទន្លេនេះ។<br>បន្ទាប់ពីជ័យជម្នះរបស់បារាំងលើសៀម នៅប៉ាក់ណាម នៅថ្ងៃទី១៣ ខែ |

| | |
|---|---|
| | កក្កដា ឆ្នាំ១៨៩៣នោះ បារាំងបានកាន់កាប់«ចន្ទបុរី» រយៈពេល១១ឆ្នាំ (១៨៩៣-១៩០៤)។ ក្រុងចន្ទបុរី(Chanthaburi) ឬ ចន្ទប៊ុន(Chanta-boun) ជាកន្លែងសំចតនៃនាវាពាណិជ្ជកម្មសមុទ្រ នៅពាក់កណ្ដាលផ្លូវពីក្រុងព្រៃនគរទៅក្រុងបាងកកនិងស្ថិតនៅច្រកចូលព្រែកចន្ទបុរីចម្ងាយប្រហែល២៤គ.ម.ពីឆ្នេរសមុទ្រ។<br><br> |
| **១៣៦- ទីរេស៊ីដង់ក្រាតនិងកោះកុង**<br>អ. Residence of Krat and Koh Kong<br>បារ. Résidence de Krat et Koh Kong | ខេត្តខ្មែរចំនួនពីរគឺក្រាតនិងកោះកុង នៅជាប់ជាមួយគ្នាហៅថា «ទីរេស៊ីដង់ខេត្តក្រាតនិងកោះកុង»(Résidence de Krat et Koh kong) ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ចៅហ្វាយខេត្តបារាំងតែម្នាក់ក្នុងឆ្នាំ១៩០៤-១៩០៦។ នៅឆ្នាំ១៩០៤ បារាំងបានបោះបង់«ចន្ទបុរី»ដើម្បីកាន់កាប់«ក្រាត»(Krat) ឬ «ត្រាត»(Trat) ដែលស្ថិតនៅប្រហែល៦០គ.ម.ខាងត្បូងចន្ទបុរីជំនួសវិញ។<br>លោក ម៉ូរ៉ែល(Morel) ជារេស៊ីដង់ជាន់ខ្ពស់បារាំងនៅកម្ពុជា និងជាអ្នកតំណាងលោក បូ(Beau) ជាអគ្គទេសាភិបាលឥណ្ឌូចិន អមដំណើរដោយលោក ស៊ីម៉ុង(Simon) ជាចៅហ្វាយខេត្តបារាំងថ្មី និងព្រះអង្គម្ចាស់សុធារសជាតំណាងព្រះរាជាខ្មែរ បានធ្វើដំណើរទៅកាន់«ក្រាត» ដើម្បីចូលរួមក្នុង «ពិធីប្រគល់ទឹកដីក្រាតពីសៀមមកបារាំង»នៅឆ្នាំ១៩០៤។<br>(ប្រភព : *La France au Siam*, Le Petit Journal illustré du 26 Février 1905)<br><br><br>ខេត្តចន្ទបុរី និងក្រាត |

| | |
|---|---|
| | <br>ទីរេស៊ីដង់ខេត្តក្រាតនិងកោះកុង |
| **១៣៧- ការយោគយល់គ្នាដោយសុទ្ធចិត្ត បារាំង-អង់គ្លេស**<br>អ. Franco-British Entente cordiale<br>បារ. Entente cordiale franco-britannique | ការព្រមព្រៀងគ្នារវាងបារាំងនិងអង់គ្លេសដែលមានអត្ថិភាពពីឆ្នាំ១៩០៤ ដល់ឆ្នាំ១៩១៤ដើម្បីទុកកម្លាំងទៅទប់ទល់នឹងអាល្លឺម៉ង់ដែលបានពង្រីកកម្លាំងយោធាយ៉ាងសម្បើម នៅមុនសង្គ្រាមលោកលើកទី១។<br>ការប្រកួតប្រជែងគ្នារវាងមហាអំណាចអាណានិគមធំពីរ គឺអង់គ្លេស និង បារាំង នៅអាស៊ីអាគ្នេយ៍(ឆ្នាំ១៨៩៦-១៩០៤) បានផ្តល់ឱកាសឱ្យប្រទេសសៀមក្លាយជា«រដ្ឋទ្រនាប់»(Buffer State/État tampon)នៅចន្លោះមហាអំណាចអាណានិគមទាំងពីរនេះ។ ការដែលបារាំងរុញច្រានឱ្យសៀមដកថយពីប្រទេសកម្ពុជានិងឡាវនោះ នាំឱ្យមានការប្រឆាំងពីអង់គ្លេសដែលចង់ឱ្យសៀមនៅឯក-រាជ្យសម្រាប់ពាណិជ្ជកម្មនិងយុទ្ធសាស្ត្ររបស់ខ្លួន(អង់គ្លេស)។ ការប្រកួតប្រជែងនេះបានបញ្ចប់នៅឆ្នាំ១៩០៤ ដោយសារនយោបាយការបរទេសថ្មីរបស់បារាំង និងអង់គ្លេសដែលហៅថា «ការយោគយល់គ្នាជាមិត្តភាព»(Entente cordiale)។<br>«ការយោគយល់គ្នាដោយសុទ្ធចិត្ត»នេះ ផ្តើមចេញពីគំនិតរបស់លោក តេអូហ្វីល ដេលកាស្សេ (Théophile Delcassé) ជារដ្ឋមន្ត្រីការបរទេសបារាំងតាំងពីឆ្នាំ១៨៩៨ (ដូច្នេះហើយបានជាគេប្រើពាក្យបារាំងថា Entente cordialeនេះនិងមិនប្រើពាក្យអង់គ្លេសថា Cordial understanding ទេ)។<br>តាមការយោគយល់គ្នាជាមិត្តភាពនេះ បារាំងនិងអង់គ្លេសលែងប្រកួតប្រជែងគ្នាក្នុងបញ្ហាអាណានិគម ដើម្បីប្រមូលកម្លាំងទៅទប់ទល់នឹងអាល្លឺម៉ង់ដែលពង្រីកកម្លាំងយោធាយ៉ាងសម្បើមនៅមុនសង្គ្រាមលោកលើកទី១។<br>ដោយសារការយោគយល់គ្នានេះ បារាំងយកបានខេត្តសៀមរាប បាត់ដំបង និងសិរីសោភ័ណពីសៀមមកវិញ នៅឆ្នាំ១៩០៧ ដោយគ្មានការជំទាស់ពីអង់គ្លេស។ |

| | |
|---|---|
| | <br> |
| **១៣៨- ឃុំស្រែជិះ**<br>អ. Srè Chis Commune<br>បារ. Commune de Srè Chis | ឈ្មោះឃុំមួយនៅក្នុងស្រុកសំបូរ ( សម្បូណ៌ ) ខេត្តក្រចេះ បង្កើតឡើងដោយព្រះរាជប្រកាសចុះថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៣៦ ដែលនៅក្នុងឃុំនោះមានស្តូបអនុស្សាវរីយ៍ជ័យជម្នះរបស់កងយោធពលខេមរភូមិន្ទលើកងទ័ពវៀតមិញ នៅក្នុងខែកក្កដា ឆ្នាំ១៩៥៤ នៅពេលដែលសន្និសីទក្រុងហ្សឺណែវ ដើម្បីស្ថាបនាសន្តិភាពនៅឥណ្ឌូចិនឡើងវិញ កំពុងប្រព្រឹត្តទៅនៅប្រទេស ស្វ៊ីសពីថ្ងៃទី២៦ ខែមេសា ដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៥៤។<br>ចំពោះឈ្មោះឃុំនេះ នៅក្នុងឯកសារផ្លូវការផ្សេងៗទៀតមានការប្រើពាក្យ *ស្រែជិស ស្រែដ្ធិស* និង *ស្រែដ្ធេស ។*<br><br> |
| **១៣៩- ស្តូបអនុស្សាវរីយ៍ ជ័យជម្នះនៅស្រែជិះ**<br>អ. Victory Memorial at Srè Chih | ស្តូបដែលត្រូវបានកសាងឡើងនៅឆ្នាំ១៩៦២ នៅឃុំស្រែជិះ ស្រុកសំបូរ ( សម្បូណ៌ ) ខេត្តក្រចេះ ដើម្បីរំលឹកអនុស្សាវរីយ៍នៃជ័យជម្នះរបស់កងយោធពល-ខេមរភូមិន្ទលើកងទ័ពវៀតមិញ នៅក្នុងខែកក្កដា ឆ្នាំ១៩៥៤ នៅពេលដែលសន្និសីទក្រុងហ្សឺណែវដើម្បីស្ថាបនាសន្តិភាពនៅឥណ្ឌូចិនឡើងវិញកំពុងប្រព្រឹត្ត |

| | |
|---|---|
| បារ. Mémorial de la victoire à Srè Chih | ទៅនៅប្រទេសស្វីសពីថ្ងៃទី២៦មេសា ដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៥៤។<br>ប្រតិបត្តិការសឹកចុងក្រោយនៅឃុំស្រែជិះ ដែលបានជ័យជម្នះនោះបានប្រព្រឹត្តទៅនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៥៤ នៅក្រោមបញ្ជាការរបស់លោកវរសេនីយឯក សូ កាំខូយ(មេបញ្ជាការតំបន់យោធាខ្មែរប្រចាំខេត្តក្រចេះនិងស្ទឹងត្រែង) អមដោយលោកអនុសេនីយត្រី អ៊ុម សារុជ(មេបញ្ជាការកងអនុសេនាធំ) និងនាយទាហានបារាំងដែលបញ្ជាលើទាហានខ្មែរពីរកងអនុសេនាធំ (Compagnie)។ ស្តូបនេះស្ថិតនៅជិតព្រៃកគ្រៀង ដែលហូរកាត់ឃុំស្រែជិះ។ ក្រោយមក លោក សូ កាំខូយ ជា*ប្រធានាធិបតីស្តីទីនៃរបបសាធារណរដ្ឋខ្មែរ*នៅដើមខែមេសា ឆ្នាំ១៩៧៥។<br><br>ស្តូបអនុស្សាវរីយ៍ជ័យជម្នះនៅស្រែជិះ<br>(រូបថត ច័ន្ទវីរៈ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៧) |
| **១៤០- ការចូលទៅកាន់ឆ្លូងលើ**<br>អ. Penetration of the Upper Chhlong<br>បារ. Pénétration du Haut Chhlong | ដំណើរការពង្រីកការគ្រប់គ្រងរបស់បារាំងទៅកាន់ភូមិភាគឦសាននៃប្រទេសកម្ពុជាពីឆ្នាំ១៩២៥ដល់ឆ្នាំ១៩៣៥ តាមរយៈសកម្មភាពនានា ដូចជា ការធ្វើផ្លូវលំពីស្នួលចូលទៅតំបន់ឆ្លូងលើ(ខេត្តមណ្ឌលគិរីសព្វថ្ងៃ) ការធ្វើប្រតិបត្តិការយោធា ការបញ្ចុះបញ្ចូលអូសទាញទឹកចិត្ត និងការធ្វើខ្មែរនីយកម្មចំពោះប្រជាជននៅតំបន់នោះដែលមានជនជាតិព្នងជាពិសេស។<br>ព្រឹត្តិការណ៍សំខាន់ៗដែលពាក់ព័ន្ធមានដូចជា៖<br>- នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៣១ មន្ត្រីប្រតិភូបារាំងនៅស្នួល (Délégué de Snuol) ឈ្មោះហ្គាទីយ៍(Gatille) ដែលទទួលភារកិច្ចធ្វើផ្លូវចូលទៅកាន់ឆ្លូងលើ ត្រូវបានសម្លាប់ដោយជនជាតិព្នងនៅប៉ុស្តិ៍ហ្គាទីយ៍(Poste Gatille)។<br>- នៅឆ្នាំ១៩៣៣ នាង ស៊ូសាន កាប៉ឺឡេស(Suzanne Karpeles) ជាអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ និងព្រះភិក្ខុ ហួត តាត ជាសាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ បានទៅកាន់តំបន់ឆ្លូងលើនៅពេលដែលតំបន់នោះមិនទាន់មានសន្តិភាពទាំងស្រុងនៅឡើយ ដើម្បីរៀបចំកម្មវិធីបង្រៀនភាសាខ្មែរដល់ជនជាតិដើមភាគតិចនៅទីនោះ ដោយចាប់ផ្តើមពីប៉ុស្តិ៍ឡឺ រ៉ូលឡង់ (Poste Le Rolland)។ |

| | |
|---|---|
| | - នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៣៤ ព្រះសង្ឃ៨អង្គបាននិមន្តពីភ្នំពេញទៅកាន់ប៉ុស្តិ៍ឡឺ រ៉ុលឡង់ ដើម្បីរៀបចំសម្ពោធវត្តមួយនៅទីនោះនិងចាប់ផ្តើមបង្រៀនភាសាខ្មែរ។  ផែនទីផ្លូវទៅកាន់តំបន់ឆ្លូងលើ ឆ្នាំ១៩៣១-៣៥ |

## II.២- បច្ចេកសព្ទស្នើដោយគណៈកម្មការភូមិវិទ្យា

| | |
|---|---|
| **១- កសិបសុកម្ម**<br>អ. pastoral farming<br>បារ. agro-pastoral ( m. ) | ការដាំដុះនិងការចិញ្ចឹមសត្វជាហ្វូងនៅតាមវាលស្មៅធម្មជាតិតាមបែបកសិកម្មចិញ្ចឹមពោះ។ |
| **២- បសុកម្មគោចរ**<br>អ.nomadic herding<br>បារ.transhumance ( f. ) | ការចិញ្ចឹមហ្វូងសត្វតាមបែបសម័យដើមដោយមនុស្សចល័តទីកន្លែងរស់នៅដើម្បីនាំហ្វូងសត្វទៅរកវាលស្មៅឬកន្លែងដែលមានចំណីអាហារ។ ជាទូទៅ ការចិញ្ចឹមហ្វូងសត្វប្រភេទនេះមាននៅតំបន់ស្ងួតហែងឬស្ទើរហួតហែង( តំបន់វាលខ្សាច់ )។ |
| **៣- កសិកម្មព្រៃដុត**<br>អ. slash and burn agriculture<br>បារ. agriculture itinérante sur brûlis( m. )/ agriculture( f. ) par la hache et par le feu | ការដាំដុះរបស់សហគមន៍ជនជាតិដើមភាគតិចនៅតំបន់ព្រៃស្បាតដោយការកាប់ព្រៃហើយដុតនិងដាំដំណាំជាចម្ការវិលជុំ។<br>ឧ. ដំណាំព្រៃដុតរបស់ជនជាតិដើមភាគតិចនៅភូមិភាគឦសាននៅកម្ពុជា។ |
| **៤- កសិកម្មនឹងកន្លែង/ កសិកម្មនិសិន្ន**<br>អ. sedentary agriculture<br>បារ. agriculture sédentaire | ការដាំដុះដែលកសិករធ្វើនៅកន្លែងដដែលៗនិងជារៀងរាល់ឆ្នាំក្នុងភូមិសាស្ត្រណាមួយ។ |

| | |
|---|---|
| **៥- កសិកម្មគោចរ/ កសិកម្មចល័ត**<br>អ. nomadic farming<br>បារ. agriculture nomade | ការដាំដុះនិងការចិញ្ចឹមសត្វដោយការផ្លាស់ប្តូរទីកន្លែងទៅតាមលក្ខខណ្ឌភូមិសាស្ត្រ ( ទឹក ដី ស្មៅ រដូវ ...)។ |
| **៦- កសិឧស្សាហកម្ម**<br>អ. agro-industry<br>បារ. agro-industrie | សំណុំនៃសហគ្រាសឧស្សាហកម្មដែលផ្តល់នូវឧបករណ៍និងសម្ភារៈកសិកម្ម (ដី ថ្នាំពុលកសិកម្ម គ្រឿងចក្រ)និងសហគ្រាសឧស្សាហកម្មដែលកែច្នៃ វេចខ្ចប់ និងបង្កើតលក្ខខណ្ឌឱ្យកសិផល( ឧស្សាហកម្មកសិចំណីអាហារ )។ |
| **៧- បដិវត្តន៍កសិកម្ម**<br>អ. agricultural revolution<br>បារ. révolution agricole | ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សរបៀបដាំដុះនិងការចិញ្ចឹមសត្វដើម្បីបង្កើនស្បៀងឱ្យបានច្រើន ក្នុងគោលបំណងដោះស្រាយសេចក្តីត្រូវការរបស់ប្រជាជនដែលមានចំនួនច្រើនជាងមុន។ |
| **៨- បដិវត្តន៍បៃតង**<br>អ. green revolution<br>បារ. révolution verte /agriculture ( f. ) par la hache et par le feu | ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនូវបច្ចេកទេសដាំដុះ តាមរយៈអតិផលកម្មដូចជាការជ្រើសរើសពូជដំណាំ ការបង្កាត់ពូជ របៀបដាំ ជាតសាស្ត្រ ការប្រើជីនិងថ្នាំជាដើម ដើម្បីទទួលបានទិន្នផលខ្ពស់។ បដិវត្តន៍នេះបានចាប់ផ្តើមនៅប្រទេសម៉ិកស៊ិកនៅក្នុងទសវត្សរ៍ទី៥នៃសតវត្សរ៍ទី២០។ |
| **៩- ជីវភូមិវិទ្យា**<br>អ. biogeography<br>បារ. biogéographie ( f. ) | ការសិក្សាតាមបែបវិទ្យាសាស្ត្រអំពីរបាយភាវៈរស់( មនុស្ស សត្វ និងរុក្ខជាតិ ) និងស្ថានប្រព័ន្ធទៅតាមភូមិសាស្ត្រ និងបុព្វហេតុដែលនាំឱ្យមានរបាយខុសៗគ្នា។ |
| **១០- ពពួក**<br>អ. population<br>បារ. population | បណ្តុំសត្វឬរុក្ខជាតិច្រើនក្នុងប្រភេទតែមួយ ដែលរស់ឬដុះនៅជាមួយគ្នាក្នុងតំបន់ណាមួយ។ ឧទាហរណ៍ ពពួកផ្សោតទឹកសាបជាមច្ឆជាតិមួយប្រភេទដែលរស់នៅទន្លេមេគង្គកម្ពុជាផ្នែកខាងលើ។ |
| **១១- រុក្ខជាតិធម្មជាតិ**<br>អ. natural vegetation<br>បារ. vegetation naturelle | បណ្តុំរុក្ខជាតិដែលដុះលូតលាស់តាមធម្មតា ដោយពុំមានការបំផ្លិចបំផ្លាញ ឬការកែប្រែដោយមនុស្ស។ |
| **១២- ព្រៃ**<br>អ. forest<br>បារ. forêt ( f. ) | កន្លែងដែលមានរុក្ខជាតិតូចធំដុះចម្រុះគ្នា ព្រមទាំងបង្ហាញនូវសណ្ឋានរបស់វាផ្សេងពីមជ្ឈដ្ឋានជុំវិញ។ |
| **១៣- ព្រៃឈើ**<br>អ. wood forest<br>បារ. forêt des bois ( f. ) | កន្លែងដែលរុក្ខជាតិដុះតាមធម្មជាតិឬដោយការដាំដែលក្នុងនោះដើមឈើមានចំនួនច្រើនលើសលប់។ |

| | |
|---|---|
| **១៤- ព្រៃដុះឡើងវិញ**<br>អ. secondary forest<br>បារ. forêt secondaire | ព្រៃថ្មីដែលដុះ លូតលាស់ឡើង ក្រោយពីព្រៃដើមត្រូវបានកាប់ដោយមនុស្ស និង/ឬបំផ្លាញដោយភ្លើងឆេះ ...។ |
| **១៥- តៃហ្គា**<br>អ. taiga<br>បារ. taïga ( f. ) | តំបន់ដែលជាជីវមណ្ឌលនៅចន្លោះជីវមណ្ឌលទុនដ្រានិងស្តិប ដែលមានធ្លាក់ទឹកកកសំឡីនៅតំបន់អ៊ឺរ៉ាស៊ីនិងអាម៉េរិកខាងជើង ហើយមានដុះនូវប្រភេទព្រៃអម្បូរស្រល់ដែលមានសំណុំស្លឹករាងសាជីនិងមានពណ៌បៃតងគ្រប់រដូវ។ |
| **១៦- ព្រៃជ្រុះស្លឹក**<br>អ. deciduous forests<br>បា. forêt décidue | ប្រភេទព្រៃដែលជ្រុះស្លឹកតាមរដូវ ហើយដុះនៅតំបន់អាកាសធាតុត្រូពិកឬតំបន់អាកាសធាតុត្រជាក់បង្គួរ។ |
| **១៧- ព្រៃបៃតងជានិច្ច**<br>អ. evergreen forest<br>បារ. forêt à feuilles persistantes | ប្រភេទព្រៃដែលមានស្លឹកពណ៌បៃតងនៅគ្រប់រដូវ។ |
| **១៨- ព្រៃត្រូពិក**<br>អ. tropical forest<br>បារ. forêt tropicale | ប្រភេទព្រៃដែលសម្បូណ៌ដោយដើមឈើចម្រុះនិងមានស្លឹកពណ៌បៃតងនៅតំបន់ដែលមានសីតុណ្ហភាពខ្ពស់និងមានកម្ពស់ទឹកភ្លៀងប្រចាំឆ្នាំខ្ពស់ ពោលគឺនៅតំបន់ដែលមានអាកាសធាតុត្រូពិកនិងអេក្វាទ័រ។<br>ព្រៃត្រូពិកមានព្រៃស្តុក ព្រៃមូសុង ព្រៃកោងកាង ...។ |
| **១៩- ព្រៃស្តុក**<br>អ. dense forest<br>បារ. forêt dense | ប្រភេទព្រៃដែលមានរុក្ខជាតិទ្រុបទ្រុល ច្រើនជាន់ និងមានប្រភេទរុក្ខជាតិប្លែកៗគ្នា ដុះនៅតំបន់ត្រូពិកនិងតំបន់ផ្សេងទៀត។ |
| **២០- ព្រៃអេក្វាទ័រ**<br>អ. equatorial rainforest<br>បារ. forêt pluviale équatoriale ( f. ) | ប្រភេទព្រៃស្តុកដែលដុះនៅតំបន់ត្រូពិកនៃអាកាសធាតុអេក្វាទ័រ ដែលមានរុក្ខជាតិច្រើនថ្នាក់ដុះបន្តបន្ទាប់គ្នា ហើយអាចមានកម្ពស់រហូតដល់៦០ម៉ែត្រ។ |
| **២១- ព្រៃកោងកាង**<br>អ. mangrove swamp<br>បារ. mangrove/forêt de palétuviers ( f. ) | ប្រភេទព្រៃត្រូពិក ដុះនៅតំបន់ឆ្នេរសមុទ្រ(វាលភក់ ដីសណ្ត ខ្ពប ពាមខាងក្រោយផ្នូកខ្សាច់) ដែលមានរលកសមុទ្រខ្សោយ។ ព្រៃប្រភេទនេះដុះលូតលាស់ល្អ ជាពិសេស នៅតំបន់អាស៊ីខាងត្បូងនិងខាងកើត។ ព្រៃប្រភេទនេះមានដើមកោងកាងភាគច្រើនបំផុតនិងរុក្ខជាតិផ្សេងៗទៀតដុះលាយឡំ។ |
| **២២- ព្រៃមូសុង**<br>អ. monsoon forest<br>បារ. forêt de mousson | ប្រភេទព្រៃត្រូពិកនិងប្រភេទព្រៃជ្រុះស្លឹក ដុះនៅតំបន់អាកាសធាតុមូសុង (មានខ្យល់មូសុងវស្សានិងខ្យល់មូសុងប្រាំង)។ ព្រៃមូសុងដុះនៅតំបន់អាស៊ីអាគ្នេយ៍និងភាគឦសាននៃប្រទេសឥណ្ឌា។ |

| | |
|---|---|
| **២៣- ព្រៃមេឌីទែរ៉ាណេ**<br>អ. mediterranean forest/ chaparral<br>បារ. forêt méditerranéenne /chaparral | ប្រភេទព្រៃបៃតងជានិច្ច មានពពួកដើមសែន អូលីវ និងឈើផ្សេងៗទៀតនៃអម្បូរស្រល់ ដែលមានដុះនៅអាងមេឌីទែរ៉ាណេ(ទ្វីបអឺរ៉ុប) ភូមិភាគជ្រោយភាគខាងត្បូងនៃទ្វីបអាហ្វ្រិក និងភាគនិរតីនៃប្រទេសអូស្ត្រាលី។ |
| **២៤- ព្រៃម៉ាគី**<br>អ. maquis<br>បារ. maquis(m.) | ប្រភេទព្រៃឈើតូចៗស៊ុបទ្រុប កើតចេញពីព្រៃនៅអាងមេឌីទែរ៉ាណេដែលរេចរឹលដោយសារការកាប់ឆ្ការនិងភ្លើងឆេះ និងដុះនៅលើដីស៊ីលីស ដូចជា ព្រៃនៅភាគខាងត្បូងប្រទេសបារាំងជាដើម។ |
| **២៥- ព្រៃហ្គារីក**<br>អ. garrigue/garigue<br>បារ. garrigue/garigue (f.) | ប្រភេទព្រៃមិនសូវស៊ុបទ្រុបសម្បូរដោយគុម្ពោតរុក្ខជាតិបន្លានិងពពួកស្មៅដែលកើតចេញពីព្រៃនៅអាងមេឌីទែរ៉ាណេដែលរេចរឹលដោយសារការកាប់ឆ្ការនិងភ្លើងឆេះ និងដុះនៅលើដីថ្មកំបោរ។ |
| **២៦- ព្រៃស្ទាប់**<br>អ. thicket, bush<br>បារ. fourré (m.) | ប្រភេទព្រៃដុះញឹកប្រជៀតគ្នាស៊ុបទ្រុប សម្បូរដោយពពួកវល្លិ ស្បូវ គ្រែង និងដើមឈើតូចៗចម្រុះ ដុះក្រោមដើមឈើធំៗខ្លះ។ |
| **២៧- ព្រៃរបោះ**<br>អ.<br>បារ. forêt de clairière | ប្រភេទព្រៃដុះរង្វើលៗ ដាច់ៗពីគ្នា ឬដុះដោយដុំៗ ដែលជាព្រៃធម្មជាតិឬជាព្រៃដែលនៅសេសសល់ពីការកាប់ឆ្ការដើម្បីតាំងទីលំនៅនិងដាំដំណាំ។ |
| **២៨- គុម្ពោត**<br>អ. bush<br>បារ. buisson (m.) | ប្រភេទគុម្ពឈើតូចៗ កូនឫស្សីព្រៃ ព្រេច ទន្ទ្រានខេត្ត ដំបងយក្ស ស្បូវស្មៅ ... ដែលដុះផ្តុំគ្នាមួយដុំៗ។ |
| **២៩- ព្រៃជងស្ទឹង**<br>អ. gallery forest, riparian forest<br>បារ. forêt-galerie(f.) | ប្រភេទព្រៃដែលដុះតាមបណ្តោយផ្លូវទឹកដូចជា ទន្លេ ស្ទឹង ជាដើម។ |
| **៣០- ព្រៃគុម្ពោត**<br>អ. scrubland, shrubland<br>បារ. brousse (f.) | ប្រភេទព្រៃដែលមានដើមឈើរាយៗដុះលាយឡំនឹងគុម្ពោត នៅក្នុងតំបន់ត្រូពិក។ |
| **៣១- ព្រៃរនាម**<br>អ. easily-flooded forest<br>បារ.forêt inondable(f.) | ប្រភេទព្រៃដែលដុះក្នុងទំនាបបឹងឬកន្លែងដែលមានទឹកលិចតាមរដូវកាល។ ឧទាហរណ៍ ព្រៃដុះនៅតំបន់មាត់បឹងទន្លេសាបជាព្រៃរនាម។ |

| | |
|---|---|
| **៣២- វាលស្មៅ**<br>អ. savanna/ savana/ savannah<br>បារ. savane ( f. ) | ផ្នែកមួយនៃមណ្ឌលជីវៈដីគោក មានដុះពពួកស្មៅផ្សេងៗនៅតំបន់ក្តៅដែលមានរដូវប្រាំងវែង(ភាគកណ្តាលនៃទ្វីបអាហ្វ្រិកភាគខាងត្បូងនៃទ្វីបអាម៉េរិក)។<br>វាលស្មៅអាចមានដើមឈើច្រើនឬតិចដុះលាយឡំជាមួយពពួកស្មៅទៅតាមកម្ពស់ទឹកភ្លៀងដែលខុសៗគ្នាតាមតំបន់។ ពពួកស្មៅនៅវាលស្មៅលូតលាស់នៅរដូវភ្លៀងនិងក្រៀមស្វិតឬងាប់នៅរដូវប្រាំង។<br>ឧ. វាលស្មៅនៅទ្វីបអាហ្វ្រិកភាគកណ្តាល(ប្រទេសកេនយ៉ា)។ |
| **៣៣- វាលស្តិប**<br>អ.steppe<br>បារ.steppe ( f. ) | ផ្នែកមួយនៃមណ្ឌលជីវៈដីគោក មានដុះពពួកស្មៅទាបៗនិងអាចមានគុម្ពោតខ្លះៗ នៅតំបន់អាកាសធាតុត្រជាក់ខ្លាំងក្នុងសិសិររដូវនិងស្ងួតនៅវស្សានរដូវ ដូចជា នៅភាគកណ្តាលនៃទ្វីបអាស៊ី នៅតំបន់អាកាសធាតុក្បែរត្រូពិកនៃទ្វីបអាម៉េរិកខាងត្បូង(ប្រទេសអាហ្សង់ទីន) ជាដើម។ |
| **៣៤- ទុនដ្រា**<br>អ.tundra<br>បារ.toundra( f. ) | ផ្នែកមួយនៃមណ្ឌលជីវៈដីគោកនៅតំបន់ប៉ូលដែលមានសណ្ឋានដីមានលក្ខណៈជាភ្នំទាបៗ វាលទំនាប ហើយមានដុះចុល្លព្រឹក្សទាបៗ ស្លែ និងលីកែន។ |
| **៣៥- ភពផែនដី**<br>អ. Earth's planet<br>បារ. Planète térrestr ( f. ) | ភពដែលមានជីវិតរស់នៅនៃប្រព័ន្ធព្រះអាទិត្យជាភពទី៣ដែលមាននៅជិតព្រះអាទិត្យបន្ទាប់ពីភពពុធនិងភពសុក្រ។ ផែនដីជាភពគ្មានពន្លឺ គឺទទួលពន្លឺនិងកម្តៅពីព្រះអាទិត្យ។ ផែនដីជាម៉ាសរឹងមួយធំ មានរាងអេលីបសូអ៊ីត (សំប៉ែតបន្តិចត្រង់ប៉ូលទាំង២)។ ផែនដីមានផ្ទៃក្រឡា៥១០លានគីឡូម៉ែត្រការ៉េ មានកាំពីផ្ចិតទៅប៉ូល៦ ៣៥៧គីឡូម៉ែត្រនិងពីផ្ចិតទៅអេក្វាទ័រ ៦ ៣៧៨ គីឡូម៉ែត្រនិងខ្សែអេក្វាទ័រ ៤០ ០៧៧គីឡូម៉ែត្រ។ ផែនដីវិលជុំវិញខ្លួនឯង (រង្វិលខ្វាល់) ហើយវិលជុំវិញព្រះអាទិត្យ(រង្វិលជុំ)។ ភពផែនដីមានមណ្ឌលថ្ម មណ្ឌលទឹក មណ្ឌលអាកាស និងមណ្ឌលជីវៈ។ |
| **៣៦- សំបកផែនដី**<br>អ. Earth's crust/ The crust of the Earth<br>បារ. croûte terrestre/ écorce terrestre/ croûte de la Terre | ស្រទាប់ក្រៅបំផុតនៃផែនដីមានកម្រាស់ពី៥គីឡូម៉ែត្រទៅ១០០គីឡូម៉ែត្រ។ សំបកផែនដីចែកចេញជាពីរ គឺសំបកទ្វីបនិងសំបកក្រោមមហាសមុទ្រ ហើយដង់ស៊ីតេសំបកក្រោមមហាសមុទ្រធំជាងដង់ស៊ីតេសំបកទ្វីប។ |
| **៣៧- សំបកទ្វីប**<br>អ.continental crust<br>បារ. croûte continentale | ផ្នែកមួយនៃសំបកផែនដីដែលជាទ្វីប មានកម្រាស់ជាមធ្យម៣០គីឡូម៉ែត្រ សម្បូរដោយថ្មក្រានីត។ |
| **៣៨- សំបកក្រោមមហាសមុទ្រ**<br>អ. oceanic crust<br>បារ. croûte océanique | ផ្នែកមួយនៃសំបកផែនដីដែលនៅក្រោមមហាសមុទ្រ មានកម្រាស់ជាមធ្យម ៧គីឡូម៉ែត្រ សម្បូរដោយថ្មបាសាល់។ |

| | |
|---|---|
| **៣៩- ស្រទាប់ម៉ង់តូ**<br>អ. mantle<br>បារ. manteau (m.) | ស្រទាប់ថ្មដែលនៅចន្លោះសំបកផែនដីនិងស្នូលផែនដី មានកម្រាស់ពី៣៥គីឡូម៉ែត្រទៅ២ ៩០០គីឡូម៉ែត្រ។ |
| **៤០- មណ្ឌលថ្ម**<br>អ. lithosphere<br>បារ. lithosphère (m.) | មណ្ឌលរឹងដែលផ្សំឡើងដោយសំបកផែនដីនិងស្រទាប់ខាងលើបំផុតនៃម៉ង់តូ មានកម្រាស់ពី៧០គីឡូម៉ែត្រទៅ១៣០គីឡូម៉ែត្រ។ |
| **៤១- មណ្ឌលទឹក**<br>អ. hydrosphere<br>បារ. hydrosphère (f.) | មណ្ឌលដែលផ្សំឡើងដោយទឹកលើដី ទឹកក្នុងដី និងទឹកក្រោមដី ទាំងទម្រង់រាវ ទាំងទម្រង់រឹង។ |
| **៤២- មណ្ឌលអាកាស/ បរិយាកាស**<br>អ. atmosphere<br>បារ. atmosphère (f.) | មណ្ឌលដែលផ្សំឡើងដោយល្បាយឧស្ម័ន(អាសូត អុកស៊ីសែន ឧស្ម័នកម្រ) ចំហាយទឹក ពពក អាអេរ៉ូសូល ឧស្ម័នផ្ទះកញ្ចក់។ល។ ដែលគ្របដណ្ដប់ជុំវិញផែនដី។ |
| **៤៣- មណ្ឌលជីវៈ/ ជីវមណ្ឌល**<br>អ. biosphere<br>បារ. biosphère(f.) | មណ្ឌលដែលផ្សំឡើងដោយប្រព័ន្ធអេកូឡូស៊ីនានា និងសារពាង្គកាយរស់ទាំងអស់ដែលមាននៅលើឬក្នុងដី(ជីវមណ្ឌលដីគោក) ក្នុងទឹក និងនៅក្នុងបរិយាកាស រួមទាំងសារធាតុសរីរាង្គងាប់ដូចជា សំរាម កាកសំណល់បន្ទុះភ្នំភ្លើង សារធាតុសរីរាង្គក្នុងដី កម្ទេចកម្ទីក្នុងសមុទ្រ ជាដើម។ |
| **៤៤- ភូមិមាត្រវិទ្យា**<br>អ. geodesy<br>បារ. géodésie(f.) | វិទ្យាសាស្ត្រដែលសិក្សាពីការវាស់វែងរាងនិងវិមាត្រឬផ្នែកណាមួយនៃផែនដី រួមទាំងដង់ស៊ីតេ កំណោងផ្ទៃផែនដី។ល។ |
| **៤៥- អឌ្ឍគោល**<br>អ. hemisphere<br>បារ. hémisphère(m.) | ផ្នែកពាក់កណ្ដាលនៃផែនដីខណ្ឌចែកដោយខ្សែអេក្វាទ័រ។ ផែនដីត្រូវបានចែកជាអឌ្ឍគោលខាងជើងនិងអឌ្ឍគោលខាងត្បូង។ |
| **៤៦- ខ្សែអេក្វាទ័រ**<br>អ. equator<br>បារ. équateur (m.) | រង្វង់សន្មតដែលមានរយៈចម្ងាយស្មើគ្នាពីប៉ូលទាំងពីរ ហើយដែលចែកផែនដីជាអឌ្ឍគោលពីរស្មើគ្នា(អឌ្ឍគោលត្បូង អឌ្ឍគោលជើង)។ |
| **៤៧- ខ្សែស្រប**<br>អ. parallel<br>បារ. parallèle (m.) | រង្វង់សន្មតដែលស្របនឹងខ្សែអេក្វាទ័រ។ |
| **៤៨- រយៈទទឹង**<br>អ. latitude<br>បារ. latitude (f.) | រយៈចម្ងាយគិតជាដឺក្រេរវាងទីតាំងណាមួយលើផ្ទៃផែនដីនិងខ្សែអេក្វាទ័រ ហើយមានតម្លៃស្មើនឹងរង្វាស់នៃមុំផ្ចិតផែនដីដែលបង្កើតដោយបន្ទាត់ដែលកាត់តាមទីតាំងនោះភ្ជាប់ទៅនឹងផ្ចិតផែនដីនិងប្លង់អេក្វាទ័រ។ |

| | |
|---|---|
| **៤៩- ខ្សែបណ្ដោយ**<br>អ. meridian<br>បារ. méridien(m.) | កន្លះរង្វង់សន្មតនៃផែនដីដែលភ្ជាប់ប៉ូលទាំងពីរ។ |
| **៥០- ខ្សែបណ្ដោយគោល/ ខ្សែបណ្ដោយហ្គ្រីនវិច**<br>អ. prime meridian<br>បារ. méridien origine | ខ្សែបណ្ដោយដែលកាត់តាមមន្ទីរសង្កេតហ្គ្រីនវិច(Greenwich) នៃទីក្រុងឡុងដ៍ប្រទេសអង់គ្លេស ហើយត្រូវបានសន្មតជាខ្សែបណ្ដោយដែលមានរយៈបណ្ដោយ០°។ |
| **៥១- រយៈបណ្ដោយ**<br>អ. longitude<br>បារ. longitude(f.) | រយៈចម្ងាយគិតជាដឺក្រេរវាងទីតាំងណាមួយលើផ្ទៃផែនដីនិងខ្សែបណ្ដោយគោល ហើយមានតម្លៃស្មើនឹងរង្វាស់នៃមុំផ្ចិតផែនដីដែលបង្កើតដោយបន្ទាត់ដែលកាត់តាមទីតាំងនោះភ្ជាប់ទៅនឹងផ្ចិតផែនដីនិងប្លង់ខ្សែបណ្ដោយគោល។ |
| **៥២- ខ្សែត្រូពិក**<br>អ. tropic<br>បារ. tropique (m.) | ខ្សែស្របដែលមានរយៈទទឹង២៣°២៧' នៅសងខាងខ្សែអេក្វាទ័រ។ |
| **៥៣- សុលស្ទីស**<br>អ. solstice<br>បារ. solstice (m.) | ពេលវេលាដែលព្រះអាទិត្យស្ថិតនៅលើហ្សេនីតត្រង់ខ្សែត្រូពិកខាងជើង ដែលក្នុងពេលនោះ រស្មីព្រះអាទិត្យមានកម្រិតក្ដៅបំផុតនិងពេលថ្ងៃមានរយៈពេលវែងបំផុតនៅថ្ងៃទី២១ឬ២២ ខែមិថុនា ហៅថា សុលស្ទីសខែមិថុនា(នៅអឌ្ឍគោលខាងជើង) និងពេលវេលាដែលព្រះអាទិត្យស្ថិតនៅលើហ្សេនីតត្រង់ខ្សែត្រូពិកខាងត្បូង ដែលក្នុងពេលនោះ រស្មីព្រះអាទិត្យមានកម្រិតក្ដៅបំផុតនិងពេលថ្ងៃមានរយៈពេលវែងបំផុតនៅថ្ងៃទី២១ឬ២២ខែធ្នូ ហៅថា សុលស្ទីសខែធ្នូ(នៅអឌ្ឍគោលខាងត្បូង)។ |
| **៥៤- ហ្សេនីត**<br>អ. zenith<br>បារ. zenith (m.) | ចំណុចនៃស្វ៊ែមេឃដែលស្ថិតនៅលើបន្ទាត់ឈរចំពីលើក្បាលរបស់អ្នកសង្កេតឬចំពីលើទីតាំងណាមួយ។ |
| **៥៥- ស្វ៊ែមេឃ**<br>អ. celestial sphere<br>បារ. sphère céleste | ស្វ៊ែសន្មតនៅជុំវិញផែនដី មានផ្ចិតរួមជាមួយនឹងផ្ចិតផែនដី ដែលរួមមានព្រះអាទិត្យ ព្រះចន្ទ និងភពផ្សេងទៀត។ |
| **៥៦- ណាឌៀ**<br>អ. nadir<br>បារ. nadir (m.) | ចំណុចមួយនៃស្វ៊ែមេឃនៅលើបន្ទាត់ផ្ចិតឈរ ដែលឈមនឹងហ្សេនីត។ |
| **៥៧- អង់ទីប៉ូត**<br>អ. antipode<br>បារ. antipode (m.) | ទីកន្លែងមួយនៃផែនដី ដែលឈមនឹងទីន្លែងមួយទៀតតាមបន្ទាត់ផ្ចិត។ |

| | |
|---|---|
| **៥៨- រង្វង់ប៉ូល**<br>អ. polar circle<br>បារ. cercle polaire | រង្វង់ដែលស្របនឹងខ្សែអេក្វាទ័រ ហើយមានរយៈទទឹង៦៦°៣៣′ នៅសងខាងខ្សែអេក្វាទ័រ។ រង្វង់ប៉ូលខាងជើងហៅថា រង្វង់ប៉ូលអាកទិក ឯរង្វង់ប៉ូលខាងត្បូងហៅថា រង្វង់ប៉ូលអង់តាកទិក។ |
| **៥៩- ល្វែងម៉ោង**<br>អ. time zone<br>បារ. fuseau horaire | ចំណែកនៃផ្ទៃផែនដីនៅចន្លោះខ្សែបណ្ដោយពីរ ដែលគេកំណត់ម៉ោងដូចៗគ្នានៅគ្រប់ទីកន្លែង។ គេចែកផែនដីជា២៤ល្វែងម៉ោង។ |
| **៦០- ល្វែងម៉ោងគោល**<br>អ. prime time zone<br>បារ. fuseau horaire de base | ល្វែងម៉ោងដែលខ្សែបណ្ដោយគោលពុះចំពាក់កណ្ដាល។ |
| **៦១- ម៉ោងសកល**<br>អ. Greenwich Mean Time (GMT)/Universal Time(UT)<br>បារ. heure GMT/ temps universel(TU) | ម៉ោងដែលស្ថិតនៅក្នុងល្វែងម៉ោងគោល សម្រាប់ចាប់ផ្ដើមរាប់ម៉ោងនៅលើសកលលោក។ |
| **៦២- ម៉ោងផ្លូវការ**<br>អ. legal time<br>បារ. heure légale/ temps légal | ម៉ោងដែលត្រូវបានកំណត់ឱ្យប្រើនៅក្នុងប្រទេសមួយដោយធៀបនឹងម៉ោងសកល។ |
| **៦៣- ម៉ោងក្នុងស្រុក/ ម៉ោងតំបន់**<br>អ. local time<br>បារ. heure locale | ម៉ោងនៅកន្លែងផ្សេងៗនៃប្រទេសមួយក្រៅពីម៉ោងផ្លូវការនៃប្រទេសនោះ។ |
| **៦៤- រង្វិលខ្វាល់ផែនដី**<br>អ. Earth's rotation<br>បារ. rotation de la Terre | ចលនាផែនដីវិលជុំវិញអ័ក្សរបស់ខ្លួនពីលិចទៅកើត។ |
| **៦៥- រង្វិលជុំផែនដី**<br>អ. Earth's revolution<br>បារ. révolution de la Terre | ចលនាផែនដីវិលជុំវិញព្រះអាទិត្យតាមគន្លងជាអេលីប។ |
| **៦៦- អេលីប**<br>អ. ellipse<br>បារ. ellipse (f.) | ខ្សែកោងបិទដែលផលបូកចម្ងាយពីគ្រប់ចំណុចរបស់វាទៅនឹងកំណុំទាំងពីរជាចំនួនថេរ។ |
| **៦៧- ថ្ងៃតារាគតិ**<br>អ. sidereal day<br>បារ. jour sidéral | រយៈពេល២៣ម៉ោង ៥៦នាទី ៤,១វិនាទីនៃរង្វិលខ្វាល់ផែនដីដើម្បីបានមួយជុំខ្លួនឯងដោយផ្អែកលើការគណនាតាមតារាសាស្ត្រ។ |

| | |
|---|---|
| **៧៦- អង្គនភា**<br>អ. celestial bodies<br>បារ. corps célestes | អង្គទាំងឡាយដែលមាននៅក្នុងលំហអវកាស ដូចជាផ្កាយ ភព រូបធាតុអន្តរផ្កាយ(ឧស្ម័ននិងកម្ទេចផ្សេងៗ) កាំរស្មីអវកាស ជាដើម។ |
| **៧៧- ភព**<br>**អ.** planet<br>**បារ.** planète | តារា/អង្គនភាដែលគ្មានកាំរស្មី។ |
| **៧៨- អង្គមេឃ(អង្គនភា នៃប្រព័ន្ធព្រះអាទិត្យ)**<br>**អ.** celestial bodies of the solar system<br>**បារ.** corps célestes du système solaire | អង្គទាំងឡាយដែលនៅក្នុងមេឃ ដូចជាព្រះអាទិត្យ ភព រូបធាតុនានា (ឧស្ម័ននិងកម្ទេចផ្សេងៗ) កាំរស្មីអវកាស ជាដើម ដែលស្ថិតនៅក្នុងដែនលំហនៃប្រព័ន្ធព្រះអាទិត្យ។ |
| **៧៩- ភពល្អិត**<br>អ. minor planet<br>បារ. petite planète | ភពដែលមានអង្កត់ផ្ចិតមិនលើសពី១ ០០០ គីឡូម៉ែត្រ។<br>ភពសេរ៉េស(Cérès)ជាភពដែលធំជាងគេក្នុងចំណោមភពល្អិតៗ មានអង្កត់ផ្ចិតប្រហែល៩៤៥គីឡូម៉ែត្រ។ |
| **៨០- ភពផែនដី**<br>អ. Planet Earth<br>បារ. Planète Terre | ភពទី៣ដែលនៅជិតព្រះអាទិត្យបន្ទាប់ពីភពសុក្រនិងភពពុធ ដែលមានចម្ងាយប្រមាណពី១៤៧,១ទៅ១៥២,១លានគីឡូម៉ែត្រពីព្រះអាទិត្យ ទៅតាមការប្រែប្រួលនៃអិចសង់ទ្រីស៊ីតេរបស់អេលីប។<br>ភពផែនដីវិលជុំវិញខ្លួនឯង(រង្វិលខ្វាល់)និងវិលជុំវិញព្រះអាទិត្យ(រង្វិលជុំ) តាមគន្លងជាអេលីប។ ភពផែនដីមានរណបតែមួយគឺព្រះចន្ទ។ |
| **៨១- គន្លងផែនដី**<br>អ. earth´s orbit<br>បារ. orbite de la Terre | គន្លងដែលមានរាងជាអេលីបបង្កើតឡើងដោយរង្វិលជុំរបស់ផែនដី។ |
| **៨២- អិចសង់ទ្រីស៊ីតេ**<br>អ. eccentricity<br>បារ. excentricité (f.) | ផលធៀបរវាងចម្ងាយថេរពីផែនដីដែលស្ថិតនៅលើគន្លងរបស់ខ្លួនទៅនឹងចំណុចនឹងពីរនៃអ័ក្សធំ និងប្រវែងអ័ក្សធំនោះ។ |
| **៨៣- ភូបថ**<br>អ. ecliptic<br>បារ. écliptique | ប្លង់នៃគន្លងផែនដី។ ប្លង់នៃគន្លងផែនដីនិងប្លង់នៃអេក្វាទ័របង្កើតបានរង្វាស់មុំ ២៣°២៧´ដោយទម្រេតអ័ក្សប៉ូលនៃផែនដី។ |
| **៨៤- ផែនដី**<br>អ. the Earth<br>បារ. la Terre | អង្គមេឃមួយនៃប្រព័ន្ធព្រះអាទិត្យដែលមានជីវិតរស់នៅ។<br>ផែនដីគ្មានពន្លឺខ្លួនឯងទេ គឺទទួលពន្លឺពីព្រះអាទិត្យ។ វាជាម៉ាសមួយធំរឹង មានរាងអេលីបសូអ៊ីត(សំប៉ែតបន្តិចត្រង់ប៉ូលទាំង២) មានផ្ទៃក្រឡា៥១០លានគីឡូម៉ែត្រការ៉េ មានកាំពីផ្ចិតទៅប៉ូល៦ ៣៥៧គីឡូម៉ែត្រ និងពីផ្ចិតទៅអេក្វាទ័រ៦ ៣៧៨គីឡូម៉ែត្រ មានខ្សែអេក្វាទ័រ៤០ ០៧៧គីឡូម៉ែត្រ។ ផែនដីមានមណ្ឌលថ្ម មណ្ឌលទឹក មណ្ឌលអាកាស និងមណ្ឌលជីវៈ។ |

| | |
|---|---|
| **៨៥- សកល**<br>អ. universe<br>បារ. univers | សំណុំនៃអ្វីៗដែលមានអត្ថិភាពក្នុងកាលអាកាសដូចជា ភព ផ្កាយ ធូលី ជាដើម។ |
| **៨៦- ចក្រវាល**<br>អ. universe<br>បារ. Univers | សំណុំនៃអង្គនភានិងហ្គាឡាក់ស៊ីទាំងអស់ ដោយគិតទាំងលំហដែលវាស្ថិតនៅផង។ |
| **៨៧- ភូគោល**<br>អ. globe<br>បារ. globe terrestre | ស្វ៊ែដែលមានផែនទីពិភពលោកពាសភ្ជាប់ជាមួយ ហើយតំណាងឱ្យផែនដីទាំងមូល។ |
| **៨៨- នភគោល**<br>(នុប-ភៈ-គោល)<br>អ. celestial globe<br>បារ. globe celeste | ស្វ៊ែដែលមានផែនទីមេឃពាសភ្ជាប់ជាមួយ ហើយតំណាងឱ្យស្វ៊ែមេឃ។ |
| **៨៩- ចំណោលផែនទីសាស្ត្រ**<br>អ. map projection<br>បារ. projection cartographique | បច្ចេកទេសដែលអាចឱ្យតាងផ្ទៃផែនដីទាំងមូលឬដោយផ្នែកនៅលើផ្ទៃរាបនៃផែនទី។<br>ចំណោលផែនទីសាស្ត្រមានបីប្រភេទសំខាន់ៗ គឺចំណោលស៊ីឡាំង ចំណោលកោន និងចំណោលអាស៊ីមុត។ |
| **៩០- ហ្គាឡាក់ស៊ី**<br>អ. galaxy<br>បារ. galaxie | សំណុំដ៏ធំនៃផ្កាយនិងធាតុផ្សេងៗទៀត(ភព ឧស្ម័នអន្តរផ្កាយ ប្រហោងខ្មៅ ជាដើម) ហើយស្ថិតនៅក្នុងសំណុំជាមួយគ្នាបានដោយសារបាតុភូតនៃកម្លាំងទំនាញទៅវិញទៅមក។ |
| **៩១- ផ្លូវទ្បាក់តេ**<br>អ. Milky Way<br>បារ. Voie lactée | ហ្គាឡាក់ស៊ីដែលមានរាងជាគូទខ្យង ហើយមានប្រព័ន្ធព្រះអាទិត្យស្ថិតនៅក្នុងនោះ។ |
| **៩២- តារា**<br>អ. star<br>បារ. astre | អង្គនភាធម្មជាតិណាមួយនៅក្នុងលំហអវកាស(ភព ផ្កាយ រណបធម្មជាតិ ...)។ |
| **៩៣- ផ្កាយ**<br>អ. star<br>បារ. étoile | តារាដែលបញ្ចេញកាំរស្មីដោយខ្លួនឯង។ |
| **៩៤- តារាវិទ្យា**<br>អ. astronomy<br>បារ. astronomie | វិទ្យាសាស្ត្រសិក្សាអំពីទីតាំង ចលនា ទម្រង់ និងការវិវត្តនៃអង្គនភា។ |

| | |
|---|---|
| **៩៥- តារានិករ**<br>អ. constellation<br>បារ. constellation | ក្រុមផ្កាយនៅក្នុងស្វ៊ែមេឃ ដែលផ្តុំគ្នាបង្កើតបានទៅជារាងដូចជាវត្ថុឬសត្វអ្វីមួយ។<br>ឧ. ផ្កាយក្រពើ ផ្កាយយាមនង្គ័ល ផ្កាយកូនមាន់ ....។ |
| **៩៦- អាស៊ីមុត**<br>អ. azimuth<br>បារ. azimut | មុំនៅក្នុងប្លង់ដេកដែលផ្តុំឡើងដោយអង្កត់ភ្ជាប់ពីចំណុចសង្កេតទៅចំណោលផ្កាយណាមួយទៅលើជើងមេឃនិងបន្ទាត់ទិសខាងជើងភូមិសាស្ត្រ ដោយគិតតាមទ្រនិចនាឡិកា។ |
| **៩៧- ចំណោលកោន**<br>អ. conical projection<br>បារ. projection conique | ចំណោលផែនទីសាស្ត្រមួយប្រភេទដែលកើតឡើងដោយចំណោលចំណុចផ្សេងៗនៃផ្ទៃផែនដីទៅលើកោនដែលមានកំពូលនៅលើអ័ក្សផែនដី ហើយដែលដាក់ឱ្យប៉ះនឹងផ្នែកណាមួយនៃផ្ទៃផែនដី តាមវិធីធរណីមាត្រច្បាស់លាស់។ |
| **៩៨- ចំណោលអាស៊ីមុត**<br>អ. azimuthal projection<br>បារ. projection azimutale | ចំណោលផែនទីសាស្ត្រមួយប្រភេទដែលកើតឡើងដោយចំណោលចំណុចផ្សេងៗនៃផ្ទៃផែនដីទៅលើប្លង់ដែលដាក់ឱ្យប៉ះនឹងផ្នែកណាមួយនៃផ្ទៃផែនដីតាមវិធីធរណីមាត្រច្បាស់លាស់។ |
| **៩៩- ចំណោលស៊ីឡាំង**<br>អ. cylindrical projection<br>បារ. projection cylindrique | ចំណោលផែនទីសាស្ត្រមួយប្រភេទដែលកើតឡើងដោយចំណោលចំណុចផ្សេងៗនៃផ្ទៃផែនដីទៅលើស៊ីឡាំងដែលដាក់ឱ្យប៉ះនឹងខ្សែអេក្វាទ័រឬផ្នែកផ្សេងៗនៃផ្ទៃផែនដី តាមវិធីធរណីមាត្រច្បាស់លាស់។ |
| **១០០- មាត្រដ្ឋាន**<br>អ. scale<br>បារ. échelle | ខ្នាតដែលជាផលធៀបនៃប្រវែងតាងនៅលើផែនទីនិងប្រវែងពិតនៅលើផ្ទៃផែនដី។ |
| **១០១- សៀវភៅផែនទី**<br>អ. atlas<br>បារ. atlas | កម្រងផែនទីភូមិសាស្ត្រ។ |
| **១០២- លេខរយៈកម្ពស់**<br>អ. spot elevation/<br>spot height<br>បារ. cote d'altitude | លេខដាក់ក្បែរចំណុចណាមួយនៅលើផែនទីដើម្បីបញ្ជាក់ពីរយៈកម្ពស់ត្រង់ចំណុចនោះ។ |
| **១០៣- ខ្សែកម្ពស់**<br>អ. contour line<br>បារ. courbe de niveau | ខ្សែកោងបិទជិតនៅលើផែនទីភ្ជាប់ចំណុចទាំងអស់ដែលមានរយៈកម្ពស់ស្មើគ្នានៃសណ្ឋានដី។ |
| **១០៤- ចន្លោះកម្ពស់**<br>អ. contour interval<br>បារ. intervalle de contour | ចម្ងាយឈរស្មើៗគ្នាគិតពីខ្សែកម្ពស់មួយទៅខ្សែកម្ពស់មួយទៀត។ |

| | |
|---|---|
| **១០៥- រយៈកម្ពស់**<br>អ. altitude<br>បារ. altitude | ចម្ងាយឈរនៃទីតាំងណាមួយធៀបនឹងកម្រិតទឹកសមុទ្រ។ |
| **១០៦- ឆ្នូតកម្ពស់**<br>អ. hachure<br>បារ. hachure | គំនូសឆ្មារៗដែលគេគូសនៅលើផែនទីដើម្បីតាងចំណោតនៃសណ្ឋានដី។ គំនូសកម្ពស់ញឹកហើយខ្លី តាងចំណោតខ្លាំង គំនូសកម្ពស់ឃ្លាតៗគ្នាហើយវែង តាងជម្រាលដែលមិនចោតខ្លាំង។ |
| **១០៧- សញ្ញាសន្មត**<br>អ. conventional sign<br>បារ. signe conventionnel | សញ្ញាដែលដាក់នៅលើផែនទីដើម្បីតាងអ្វីៗនៅលើផ្ទៃដីឬនៅក្រោមដី ដូចជា ភ្នំ បឹង ផ្លូវដែក ទីប្រជុំជនជាដើម។<br>សញ្ញាសន្មតទាំងអស់នៅលើផែនទីមួយ ហៅថាកំណត់ពន្យល់។ |
| **១០៨- កូអរដោណេ ភូមិសាស្ត្រ**<br>**អ.** geographic coordinates<br>បារ. coordonnées géographiques | ប្រព័ន្ធទិន្នន័យ(រយៈទទឹង រយៈបណ្ដោយ រយៈកម្ពស់)ឱ្យដឹងទីតាំងមួយលើផែនដី។ |
| **១០៩- សណ្ឋានដី**<br>អ. relief<br>បារ. relief | ទម្រង់ផ្សេងៗគ្នាខាងផ្នែកលក្ខណៈរូប( ខ្ពស់ ទាប ...)នៃផ្ទៃផែនដី។ |
| **១១០- ផែនទីឋានលេខា**<br>អ. topographic map<br>បារ. carte topographique | ផែនទីមាត្រដ្ឋានធំ(មាត្រដ្ឋានដែលមានភាគបែងតូចជាងឬស្មើ១០០ ០០០) ដែលគេគូរដើម្បីបង្ហាញឱ្យច្បាស់នូវអ្វីៗដែលមាននៅលើផ្នែកណាមួយនៃផ្ទៃដី ដូចជា ភ្នំ ផ្លូវទឹក ទីប្រជុំជនជាដើម។ |
| **១១១- ឋានលេខាសាស្ត្រ**<br>អ. topography<br>បារ. topographie | បច្ចេកទេសប្រើសម្រាប់តាងលើប្លង់នូវទម្រង់ផ្សេងៗគ្នានៅលើផ្ទៃដី ដូចជា ភ្នំ ទំនាប និងអ្វីៗផ្សេងទៀតដែលកើតឡើងដោយធម្មជាតិឬសិប្បនិម្មិត។ |
| **១១២- ខ្យល់មូសុង**<br>**អ.** monsoon<br>**បារ.** mousson | ខ្យល់រដូវនៅតំបន់រយៈទទឹងត្រូពិក មានរបបទៀងទាត់ហើយបក់ពីសមុទ្រមកទ្វីបនៅរដូវវស្សាដោយនាំមកជាមួយនូវទឹកភ្លៀង និងបក់ពីទ្វីបទៅសមុទ្រនៅរដូវប្រាំងដោយនាំមកនូវខ្យល់ស្ងួតហើយត្រជាក់។<br>ខ្យល់មូសុងមាននៅទ្វីបអាស៊ី( ខាងត្បូងនិងខាងកើត ) អូស្ត្រាលីភាគខាង ជើង ទ្វីបអាហ្វ្រិក( ខាងកើតនិងខាងលិច ) ទ្វីបអាម៉េរិក( តំបន់អាម៉ាសូន ) ជាដើម។ |
| **១១៣- រដូវ**<br>អ. season<br>បារ. saison | រយៈពេលនៃឆ្នាំកំណត់ដោយលក្ខខណ្ឌអាកាសធាតុសំខាន់ៗ( សីតុណ្ហភាព សុរិយការ កំណកអាកាស ) ដែលមានសភាពស្ទើរតែថេរ។ |

| | |
|---|---|
| **១១៤- រដូវប្រាំង**<br>អ. dry season<br>បារ. saison sèche | រដូវមួយក្នុងចំណោមរដូវទាំងពីរនៃតំបន់អាកាសធាតុត្រូពិកដែលមានកំណកអាកាសតិចនិងសីតុណ្ហភាពខ្ពស់ ហើយតំបន់ណាដែលស្ថិតនៅកាន់តែឆ្ងាយពីអេក្វាទ័រ ចិរវេលារបស់រដូវនេះកាន់តែវែង។ |
| **១១៥- រដូវវស្សា**<br>អ. rainy season/ wet season<br>បារ. saison des pluies/ saison humide | រដូវមួយក្នុងចំណោមរដូវទាំងពីរនៃតំបន់អាកាសធាតុត្រូពិកដែលមានកំណកអាកាសច្រើននិងសីតុណ្ហភាពទាប ហើយតំបន់ណាដែលស្ថិតនៅកាន់តែឆ្ងាយពីអេក្វាទ័រ ចិរវេលារបស់រដូវនេះកាន់តែខ្លី។ |
| **១១៦- និទាឃរដូវ**<br>អ. spring<br>បារ. printemps | រដូវមួយក្នុងចំណោមរដូវទាំងបួននៃតំបន់អាកាសធាតុត្រជាក់បង្គួរដែលបន្តពីសិសិររដូវនិងបញ្ចប់នៅពេលចាប់ផ្តើមវស្សានរដូវ សីតុណ្ហភាពមធ្យមប្រមាណ ១០°C ហើយផ្កាឈើចាប់ផ្តើមរីក។<br>នៅអឌ្ឍគោលខាងជើង និទាឃរដូវចាប់ពីថ្ងៃទី២០ឬ២១ ខែមីនារហូតដល់ថ្ងៃទី២១ឬ២២ ខែមិថុនា។ ចំណែកឯនៅអឌ្ឍគោលខាងត្បូងវិញ និទាឃរដូវចាប់ពីថ្ងៃទី២២ឬ២៣ ខែកញ្ញាដល់ថ្ងៃទី២២ឬ២៣ ខែធ្នូ។ |
| **១១៧- វស្សានរដូវ**<br>អ. summer<br>បារ. été | រដូវមួយក្នុងចំណោមរដូវទាំងបួននៃតំបន់អាកាសធាតុត្រជាក់បង្គួរ ដែលបន្តពីនិទាឃរដូវនិងបញ្ចប់នៅពេលចាប់ផ្តើមសរទរដូវ និងមានសីតុណ្ហភាពខ្ពស់ជាងរដូវផ្សេងទៀត។<br>នៅអឌ្ឍគោលខាងជើង វស្សានរដូវចាប់ពីថ្ងៃទី២១ឬ២២ ខែមិថុនាដល់ថ្ងៃទី២២ឬ២៣ ខែកញ្ញា។ ចំណែកឯនៅអឌ្ឍគោលខាងត្បូងវិញ វស្សានរដូវចាប់ពីថ្ងៃទី២២ឬ២៣ ខែធ្នូដល់ថ្ងៃទី២០ឬ២១ ខែមីនា។ |
| **១១៨- សរទរដូវ**<br>អ. autumn/fall<br>បារ. automne | រដូវមួយក្នុងចំណោមរដូវទាំងបួននៃតំបន់អាកាសធាតុត្រជាក់បង្គួរ ដែលបន្តពីវស្សានរដូវនិងបញ្ចប់នៅពេលចាប់ផ្តើមសិសិររដូវ សីតុណ្ហភាពមធ្យមទាបជាងនិទាឃរដូវ និងមានស្លឹកឈើជ្រុះ។<br>នៅអឌ្ឍគោលខាងជើង សរទរដូវចាប់ពីថ្ងៃទី២២ឬ២៣ ខែកញ្ញាដល់ថ្ងៃទី២១ឬ២២ ខែធ្នូ។ ចំណែកឯនៅអឌ្ឍគោលខាងត្បូងវិញ សរទរដូវចាប់ពីថ្ងៃទី២០ឬ២១ ខែមីនាដល់ថ្ងៃទី២១ឬ២២ ខែមិថុនា។ |
| **១១៩- សិសិររដូវ**<br>អ. winter<br>បារ. hiver | រដូវមួយក្នុងចំណោមរដូវទាំងបួននៃតំបន់អាកាសធាតុត្រជាក់បង្គួរ ដែលបន្តពីសរទរដូវនិងបញ្ចប់នៅពេលចាប់ផ្តើមនិទាឃរដូវ មានសីតុណ្ហភាពត្រជាក់ជាងរដូវផ្សេងទៀត និងមានធ្លាក់ទឹកកកសំឡី។<br>នៅអឌ្ឍគោលខាងជើង សិសិររដូវចាប់ពីថ្ងៃទី២១ឬ២២ ខែធ្នូដល់ថ្ងៃទី២០ឬ២១ ខែមីនា។ ចំណែកឯនៅអឌ្ឍគោលខាងត្បូងវិញ សិសិររដូវចាប់ពីថ្ងៃទី២១ឬ២២ ខែមិថុនាដល់ថ្ងៃទី២២ឬ២៣ ខែកញ្ញា។ |

| | |
|---|---|
| **១២០- ពពក**<br>អ. cloud<br>បារ. nuage(m.) | ទម្រង់ដើមនៃកំណកអាកាស អណ្តែតក្នុងបរិយាកាស មានពណ៌សឬប្រផេះ ដែលផ្គុំឡើងដោយគ្រាប់ទឹកល្អិតៗដែលមានអង្កត់ផ្ចិតពី៥ទៅដល់៥០មីក្រុង ឬដោយក្រាមទឹកកកតូចៗ ឬដោយគ្រាប់ទឹកល្អិតៗនិងក្រាមទឹកកកតូចៗ។ |
| **១២១- ពពកអន្លាយ**<br>អ. stratus<br>បារ. stratus | ប្រភេទពពកដែលស្ថិតនៅរយៈកម្ពស់ទាប ប្រមាណពី៦០០ទៅ២ ១០០ម. មានរាងអន្លាយ ពណ៌ប្រផេះ ស្ថិតនៅក្រោមបំផុតបើធៀបទៅនឹងពពកដទៃទៀត និងបង្កឱ្យមានភ្លៀងរលឹមរពេយស្បៃ។ |
| **១២២- ពពកស្បៃ**<br>អ. cirrus<br>បារ. cirrus (m.) | ប្រភេទពពកដែលស្ថិតនៅរយៈកម្ពស់ខ្ពស់ជាងគេបើធៀបនឹងពពកដទៃទៀត ប្រមាណពី៥ ០០០ទៅ១៤ ០០០ម. ផ្សំឡើងដោយគ្រាប់ទឹកកក មានសណ្ឋានដូចជាស្បៃពណ៌ស មិនបណ្តាលឱ្យមានកំណកអាកាសទេ។ |
| **១២៣- ពពកផ្កាស្ពៃ**<br>អ. cumulus<br>បារ. cumulus | ប្រភេទពពកដែលមានសណ្ឋានដូចផ្កាស្ពៃពណ៌ស/ខាត់ណាពណ៌ស បាតរបស់វាស្ថិតនៅរយៈកម្ពស់ប្រមាណជា២ ០០០ម. មានកម្រាស់ច្រើនគីឡូម៉ែត្រ មិនបណ្តាលឱ្យមានកំណកអាកាសទេ។ |

## II.៣- បច្ចេកសព្ទស្នើដោយគណៈកម្មការសុខាភិបាល

| | |
|---|---|
| **១- ដំណើរមានរដូវ**<br>អ. menstruation<br>បារ.menstruation(f) | ដំណើរហូរឈាមពីស្បូនរបស់ស្ត្រី មានរយៈពេលធម្មតាពី៣ទៅ៧ថ្ងៃ តាមវដ្តរដូវ(cycle menstruel)។ |
| **២- ការមានរដូវ**<br>អ. menorrhea<br>បារ. ménorrhée (f.) | ការហូរឈាមនិងសារធាតុផ្សេងៗពីក្នុងស្បូនរបស់ស្ត្រីនៅពេលមានរដូវ។ |
| **៣- រំហូរពីស្បូន**<br>អ. metrorrhea<br>បារ. métrorrhée (f.) | ការហូរសារធាតុរាវដែលអាចជាទឹករំអិល(mucus/glaire) ទឹកភ្លោះ(liquide amniotique) ឬកម្ទេចកម្ទីផ្សេងៗពីក្នុងស្បូន។ |
| **៤- អង់ដូមេទ្រីយ៉ូស**<br>អ. endometriosis<br>បារ. endométriose (f.) | វត្តមានជាលិកាភ្នាសក្នុងស្បូន(endomètre)នៅទីតាំងខុសប្រក្រតី ដូចជានៅក្នុងដៃស្បូន(trompe de Fallope) សាច់ដុំស្បូន(myomètre) ឬនៅក្រៅស្បូនជាដើម។ |
| **៥- អង់ដូមេទ្រីយ៉ូម**<br>អ. endometrioma<br>បារ. endométriome (m.) | ដុំពកស្លូត(tumeur bénigne)នៃភ្នាសក្នុងស្បូន(endomètre) ដែលមានរាងមូលៗមានស្រោមដូចណ្ឌូល(nodule)។ |
| **៦- អមូត្រ**<br>អ. anuria<br>បារ. anurie (f.) | អាការៈគ្មានទឹកនោមក្នុងប្លោកនោម។ |

| | |
|---|---|
| **៧- ជំងឺសាច់ដុំ**<br>អ. myopathy/myopathia<br>បារ. myopathie ( f. ) | ជំងឺគ្រប់ប្រភេទនៃប្រព័ន្ធសាច់ដុំ។ |
| **៨- ពកសាច់ដុំ**<br>អ. myoma<br>បារ. myome ( m. ) | ដុំពកស្លូត( tumeur bénigne )កើតឡើងពីជាលិកាសាច់ដុំមិនប្រក្រតី។ |
| **៩- ដុំពកភ្នាស**<br>អ. epithelioma<br>បារ. épithéliome/<br>épithélioma ( m. ) | ដុំពកកាច( tumeur maligne )កើតឡើងពីជាលិកាភ្នាស( tissu d'épithélium ) មិនប្រក្រតីរបស់សរីរាង្គដែលជាមហារីក។ |
| **១០- ក្រិនសាច់ដុំ**<br>អ. myosclerosis<br>បារ. myosclérose ( f. ) | អាការៈក្រិន ស្វិត និងរួញតូចខុសប្រក្រតីនៃសាច់ដុំ។ |
| **១១- ជំងឺផ្សិត/មីកូស**<br>អ. mycosis<br>បារ. mycose ( f ) | ជំងឺដែលបង្កឡើងដោយមេរោគជាពពួកផ្សិត( champignon )។ |
| **១២- មីកូវិទ្យា**<br>អ. mycology<br>បារ. mycologie ( f. ) | វិទ្យាសាស្ត្រសិក្សាពីជំងឺដែលបង្កដោយមេរោគជាពពួកផ្សិត( champignon )។ |
| **១៣- បរាសិតវិទ្យា**<br>អ. parasitology<br>បារ. parasitologie ( f. ) | វិទ្យាសាស្ត្រសិក្សាពីពពួកបរាសិត( parasite )។ |
| **១៤- កោសិកាវិទ្យា**<br>អ. cytology<br>បារ. cytologie ( f. ) | វិទ្យាសាស្ត្រសិក្សាពីកោសិកា( cellules )គ្រប់ប្រភេទ។ |
| **១៥- ជាលិកាវិទ្យា**<br>អ. histology<br>បារ. histologie ( f. ) | វិទ្យាសាស្ត្រសិក្សាពីជាលិកា( tissus )គ្រប់ប្រភេទ។ |
| **១៦- ដុំពកវិទ្យា/អុងកូវិទ្យា**<br>អ. oncology<br>បារ. oncologie ( f. ) | វិទ្យាសាស្ត្រសិក្សាពីដុំពក( tumeurs )នៃជាលិកា( tissus )ផ្សេងៗរបស់សរីរាង្គ។ |
| **១៧- មហារីកវិទ្យា**<br>អ. cancerology<br>បារ. cancérologie ( f. ) | វិទ្យាសាស្ត្រសិក្សាពីជំងឺមហារីក វិធីសាស្ត្រការពារនិងព្យាបាល។ |

| | |
|---|---|
| **១៨- មូត្រព្យាបាល**<br>អ. urotherapy<br>បារ. urothérapie ( f. ) | វិធីវេជ្ជសាស្ត្រវិភាគនិងព្យាបាលជំងឺប្រព័ន្ធទឹកនោម។ |
| **១៩- ពេទ្យព្យាបាល**<br>អ. therapist<br>បារ. thérapeute ( m. ) | អ្នកវេជ្ជសាស្ត្រដែលមានចំណេះជំនាញក្នុងការព្យាបាលជំងឺ។ |
| **២០- អាក្រូប៉ាតូវិទ្យា**<br>អ. acropathology<br>បារ. acropathologie ( f. ) | វិទ្យាសាស្ត្រសិក្សាពីជំងឺនៅផ្នែកចុងនៃសពាង្គកាយ ( extrémité de l'organisme ) ។ |
| **២១- វិរូបភាព**<br>អ. malformation<br>បារ. malformation ( f. ) | លក្ខណៈខុសប្រក្រតីពីកំណើតនៃសរីរាង្គណាមួយរបស់សពាង្គកាយ។ |
| **២២- ស្រួចស្រាល់**<br>អ. acute<br>បារ. aigu,-uë ( adj. ) | ដែលមានអាការៈឈឺទាន់ហន់ហើយធ្ងន់ធ្ងរផ្ទុយនឹងអាការៈរ៉ាំរ៉ៃ ( chronique ) ។ |
| **២៣- ការកន្ទេក/អាប់ដុកម្ម**<br>អ. abduction<br>បារ. abduction ( f. ) | ចលនាសរីរាង្គដែលទាញចេញទៅខាងក្រៅខុសពីទម្រង់ដើម។ |
| **២៤- ការរួបចូល/អាត់ដុកម្ម**<br>អ. adduction<br>បារ. adduction ( f. ) | ចលនាសរីរាង្គដែលទាញពីក្រៅចូលក្នុងខុសពីទម្រង់ដើម។ |
| **២៥- ឈឺ**<br>អ. ache<br>បារ. mal ( m. ) | អាការៈមិនស្រួលនៃសរីរាង្គណាមួយ។ |
| **២៦- ភាពជូរ/អាស៊ីដភាព**<br>អ. acidity<br>បារ. acidité ( f. ) | កម្រិតជាតិអាស៊ីដឬជាតិជូរនៅក្នុងល្បាយមួយដែលមានpHក្រោម៧។ |
| **២៧- អាគូស្ទិក**<br>អ. acoustic<br>បារ. acoustique ( adj. ) | ដែលជាប្រព័ន្ធសរសៃប្រសាទដែលទាក់ទងគ្នារវាងត្រចៀកនិងខួរក្បាល។ |
| **២៨- ចូល**<br>អ. afferent<br>បារ. afférent ( adj. ) | ដែលនាំសារធាតុអ្វីមួយចូលទៅក្នុងសរីរាង្គ។ |

| | |
|---|---|
| **២៩- ចេញ**<br>អ. efferent<br>បារ. efférent ( adj. ) | ដែលនាំសារធាតុអ្វីមួយចេញពីសរីរាង្គទៅក្រៅ។ |
| **៣០- អាយុ**<br>អ. age<br>បារ. âge ( m. ) | រយៈពេលនៃជីវិតរស់នៅរបស់បុគ្គលណាមួយចាប់ពីថ្ងៃកើតដល់ពេលណាមួយឬដល់ថ្ងៃស្លាប់។ |
| **៣១- សម្អិតខះ**<br>អ. agglutination<br>បារ. agglutination ( f. ) | ការស្អិតខះជាប់គ្នារបស់កោសិកាឬមីក្រូសព៌ាង្គកាយដោយសារអន្តរកម្ម រវាងអង់ទីហ្សែននិងអង់ទីករនៅពេលជួបគ្នា។ |
| **៣២- មរណាសន្នកាល/ អាហ្គោនី**<br>អ. agony<br>បារ. agonie ( f. ) | ដំណាក់កាលស្លឈាមមុនស្លាប់របស់អ្នកជំងឺដោយសារកង្វះអុកស៊ីហ្សែនទៅចិញ្ចឹមខួរក្បាល។ |
| **៣៣- ផឿក**<br>អ. albinism<br>បារ. albinisme ( m. )/ albinie ( f. ) | អាការៈគ្មានជាតិពណ៌ម៉េឡានីន ( pigment de la mélanine ) នៃស្បែក (ភ្នែក សក់ រោម ... ) ពីកំណើត ពេញទាំងខ្លួនឬផ្នែកណាមួយនៃសព៌ាង្គកាយ។ |
| **៣៤- មនុស្សផឿក**<br>អ. albino<br>បារ. albinos ( m. ) | មនុស្សដែលគ្មានជាតិពណ៌ម៉េឡានីន ( pigment de la mélanine ) នៅស្បែក ( ភ្នែក សក់ រោម ... ) ពីកំណើត។ |
| **៣៥- ជំណើរជ្រុះរោម/ អាឡូប៉េស៊ី**<br>អ. alopecia<br>បារ. alopécie ( f. ) | អាការៈជ្រុះរោម សក់ ខ្លះៗឬអស់រលីងនៅផ្នែកណាមួយនៃសព៌ាង្គកាយ។ |
| **៣៦- កង្វាក់/អាម៉ូរ៉ូស**<br>អ. amaurosis<br>បារ. amaurose ( f. ) | អាការៈងងឹតមើលមិនឃើញរបស់ភ្នែក តែរចនាសម្ព័ន្ធគ្រាប់ភ្នែកនៅធម្មតា។ |
| **៣៧- អាមីប**<br>អ. amoeba<br>បារ. amibe ( f. ) | បរាសិតឯកកោសិកាមានក្បាល ដងខ្លួន និងកន្ទុយ អាចធ្វើចលនាបានយ៉ាងរហ័ស ដែលជាភ្នាក់ងារបង្កជំងឺមួលឈាម ( dysentérie amibienne )។ |
| **៣៨- យានសង្គ្រោះ**<br>អ. ambulance<br>បារ. ambulance ( f. ) | មធ្យោបាយដឹកជញ្ជូនដែលមានបំពាក់ឧបករណ៍វេជ្ជសាស្ត្រ ដើម្បីជួយសង្គ្រោះបន្ទាន់ដល់អ្នកជំងឺ អ្នករបួស ជនរងគ្រោះផ្សេងៗ ឬដឹកសាកសព។ |

| | |
|---|---|
| **៣៩- អំពូតាស្យុង**<br>អ. amputation<br>បារ. amputation (f.) | ការកាត់ចោលតាមវិធីវេជ្ជសាស្ត្រនូវផ្នែកណាមួយនៃអវយវៈឬសរីរាង្គខាងក្រៅ។ |
| **៤០- រេសិចស្យុង**<br>អ. resection<br>បារ. résection (f.) | ការកាត់ឬច្រឹបតាមវិធីវេជ្ជសាស្ត្រនូវផ្នែកសរីរាង្គខាងក្នុងណាមួយឬសរីរាង្គទាំងមូលបន្ទាប់មកត្រូវដេរភ្ជិតឬដេរតភ្ជាប់ឱ្យមានដំណើរការឡើងវិញ។ |
| **៤១- ព័ត៌មានជំងឺ**<br>អ. anamnesis<br>បារ. anamnèse (f.) | ដំណឹងស្តីពីស្ថានភាពជំងឺដែលអ្នកជំងឺឬសមាជិកគ្រួសាររៀបរាប់ភ្លាមៗប្រាប់គ្រូពេទ្យ។ |
| **៤២- ជំនួយកម្លាំង/ អាណាឡឹបស៊ី**<br>អ. analepsia/analepsis<br>បារ. analepsie (f.) | វិធីធ្វើឱ្យអ្នកជំងឺមានកម្លាំងពលំឡើងវិញក្រោយពេលជាសះស្បើយ។ |
| **៤៣- ឱសថជំនួយកម្លាំង/ អាណាឡឹបទិក**<br>អ. analeptic<br>បារ. analeptique (m) | សារជាតុឱសថឬចំណីអាហារពិសេសដែលធ្វើឱ្យមានកម្លាំងឡើងវិញ និងធ្វើឱ្យមានរំញោចប្រព័ន្ធប្រសាទកណ្តាលឬសរីរាង្គដទៃទៀតរបស់សពាង្គកាយ។ |
| **៤៤- អាណាហ្វីឡាស៊ី**<br>អ. anaphylaxis<br>បារ. anaphylaxie (f.) | ប្រតិកម្មនៃសរីរាង្គទៅនឹងសារជាតុពីក្រៅតាមការលេប ការចាក់ ការហិត ឬការប៉ះពាល់ ដែលបង្កជារោគសញ្ញាផ្សេងៗដូចជា ឡើងកន្ទួលរមាស់លើ ស្បែកកណ្តាស់ ឬអាចបណ្តាលឱ្យស្តុក(choc) និង/ឬរហូតដល់ស្លាប់ក៏មាន។ |
| **៤៥- កាយវិភាគវិទ្យា/ អាណាតូមី**<br>អ. anatomy<br>បារ. anatomie (f.) | វិទ្យាសាស្ត្រសិក្សាអំពីរចនាសម្ព័ន្ធនៃសរីរាង្គមនុស្សនិងសត្វ។ |
| **៤៦- អាណេវ្រីស**<br>អ. aneurysm<br>បារ. anévrisme/ anévrysme (m) | អាការៈរីកប៉ោងភ្នាសសរសៃឈាមដែលបង្កឱ្យកើតមានជាអាតេរ៉ូម។ |
| **៤៧- អង់ហ្ស៊ីន**<br>អ. angina<br>បារ. angine (f.) | អាការៈឈឺចាប់ខ្លាំងភ្លាបណ្តាលមកពីការកន្ត្រាក់សាច់ដុំ(spasme)នៅត្រង់ចំណុចណាមួយនៃសរីរាង្គ។ |

| | |
|---|---|
| **៤៨- គំនាំងសន្លាក់/ អង់គីឡូស**<br>អ. ankylosis/(joint) stiffness<br>បារ. ankylose (f.) | អាការៈគាំងសន្លាក់ពុំអាចធ្វើចលនាសកម្មឬអកម្មបានបង្កដោយសាច់ដុំ ឬពួរសាច់ដុំនៃសន្លាក់នោះក្រិនរឹង ឬដោយមូលហេតុលោករលួយសន្លាក់។ |
| **៤៩- ភាពមិនប្រក្រតី/ អណូម៉ាលី**<br>អ. anomaly<br>បារ. anomalie (f.) | លក្ខណៈខុសប្លែកពីធម្មតានៃសរីរាង្គណាមួយរបស់សព៌ាង្គកាយ។ |
| **៥០- បារម្ភ**<br>អ. worry<br>បារ. inquiétude (f.) | អាការៈខ្វល់ខ្វាយក្នុងចិត្តអំពីហេតុការណ៍ដែលអាចឬមិនអាចកើតមានឡើង។ |
| **៥១- ថប់អារម្មណ៍**<br>អ. anxiety<br>បារ. anxiété (f.) | អាការៈតប់ប្រមល់ផ្លូវចិត្តរហូតដល់បេះដូងដើរញាប់និងបែកញើស។ |
| **៥២- តំណឹងចិត្ត/អង់ហ្គ័ស**<br>អ. anguish<br>បារ. angoisse (f.) | អាការៈទង្គឹះចិត្ត តានតឹងនិងថប់អារម្មណ៍ធ្ងន់ធ្ងរ ដែលប៉ះពាល់រហូតដល់ប្រព័ន្ធឈាមរត់ ប្រព័ន្ធផ្លូវដង្ហើម ...។ |
| **៥៣- អាកត្រូស**<br>អ. arthrosis<br>បារ. arthrose (f.) | អាការៈខូចសន្លាក់រ៉ាំរ៉ៃដោយគ្មានរោគសញ្ញារលាកដែលបង្កឱ្យសន្លាក់នោះចុះខ្សោយឬគាំង។ ជាទូទៅ អាការៈនេះច្រើនកើតនៅសន្លាក់ជង្គង់ឬសន្លាក់ត្រគាកចំពោះមនុស្សមានវ័យលើសពី៥០ឆ្នាំឡើងទៅ។ |
| **៥៤- ជំងឺធូលីសួត/ ផ្នឺម៉ូកូនីញ៉ូស**<br>អ. pneumoconiosis<br>បារ. pneumoconiose (f.) | ជំងឺសួតរ៉ាំរ៉ៃម៉្យាងដែលបង្កដោយកំណកធូលី(ផង់ សារធាតុរ៉ែឬសារធាតុគីមី ...)នៅក្នុងសួត តាមការដកដង្ហើមស្រូបចូលក្នុងរយៈពេលយូរ។ |
| **៥៥- អាស្បេស្តូស**<br>អ. asbestosis<br>បារ. asbestose (f.) | ជំងឺធូលីសួតម៉្យាងបង្កឡើងដោយការដកដង្ហើមស្រូបចូល ផង់អាម៉្យង់(amiante) ផង់ម៉ាញេស្យូមស៊ីលីកាត(silicate de magnésium) ផង់ដែកអុកស៊ីដ(oxyde de fer) ... ដែលប្រើក្នុងឧស្សាហកម្ម។ |
| **៥៦- អាតេរ៉ូម**<br>អ. atheroma<br>បារ. athérome (m.) | ១- គីស្ត(kyste)កើតឡើងដោយសារកំណកខ្ទុះនៃមុន(acné)។<br>២- កំណកសារធាតុខ្លាញ់នៅភ្នាសក្នុងនៃអាកទែដែលបង្កឱ្យឡើងសម្ពាធឈាម។ |
| **៥៧- កម្រិនអាកទែ/ អាកទែរីយ៉ូសក្លេរ៉ូស** | ១- អាការៈក្រាស់រឹងនិងបាត់ភាពយឺត(élasticité) នៃអាកទែ ដែលបង្កឡើងដោយអត្រាកាល់ស្យូមឡើងខ្ពស់ក្នុងចរន្តឈាម ដែលភាគច្រើនកើតឡើង |

| | |
|---|---|
| អ. arteriosclerosis<br>បារ. artériosclérose (f.) | ចំពោះមនុស្សវ័យចំណាស់។<br>២- អាការៈក្រាស់រឹងនៃផ្នែកណាមួយឬច្រើននៃអាកទែ ដែលបង្កឡើងដោយកំណកសារធាតុខ្លាញ់អាតេរ៉ូមស្ថិតនៅក្នុងអាកទែរយៈពេលយូរ ដែលបង្កឱ្យទៅជាអាតេរ៉ូស្កេរ៉ូស(athérosclérose)។ |
| **៥៨- របួមតូច/អត្រេស៊ី**<br>អ. atresia<br>បារ. atrésie (f.) | អាការៈរួមតូចនៃបំពង់ឬរន្ធរបស់សរីរាង្គ ដែលមានលក្ខណៈជាវិរូបភាពពីកំណើតឬក្រោយកំណើត ហើយដែលធ្វើឱ្យមុខងារសរីរាង្គនោះថយចុះឬបាត់បង់។ |
| **៥៩- ល្បឺ**<br>អ. audition<br>បារ. audition (f.) | ការស្ដាប់ឮនៃសោតវិញ្ញាណ។ |
| **៦០- សំដាប់ស្ទង់**<br>អ. auscultation<br>បារ. auscultation (f.) | ការស្ដាប់សំឡេងសរីរាង្គក្នុងសព៌ាង្គកាយ ដូចជា សួត បេះ ដូង ពោះវៀន ជាដើម ដើម្បីធ្វើរោគវិនិច្ឆ័យដោយប្រើត្រចៀកផ្ទាល់ឬដោយប្រើឧបករណ៍វេជ្ជសាស្ត្រ។ |
| **៦១- អូតូក្លាវ**<br>អ. autoclave<br>បារ. autoclave (m.) | ទូឬឆ្នាំងពិសេសសម្រាប់ធ្វើស្ទេរីលកម្មសម្ភារៈវេជ្ជសាស្ត្រឬសម្ភារៈផ្សេងៗ ដោយប្រើចំហាយទឹកដែលមានកម្ដៅនិងសម្ពាធខ្ពស់។ |
| **៦២- សល្យកម្មសព/ អូតុបស៊ី**<br>អ. autopsy<br>បារ. autopsie (m.) | វិធីវះកាត់សាកសពដោយអ្នកជំនាញវេជ្ជសាស្ត្រធ្វើកោសល្យវិច័យដើម្បីរកមូលហេតុនៃមរណភាពឬដើម្បីស្រាវជ្រាវវិទ្យាសាស្ត្រវេជ្ជសាស្ត្រ។ |
| **៦៣- បាស៊ីុយ៍/បាស៊ី**<br>អ. bacillus<br>បារ. bacille (m.) | ពពួកបាក់តេរីឯកកោសិកាមានរាងដូចកូនដំបង ដែលអាចរស់នៅក្នុងដី ទឹក ខ្យល់ សព៌ាង្គកាយ ...។ |
| **៦៤- បាស៊ីយ៍/បាស៊ីរបេង បាស៊ីយ៍/បាស៊ីកុក**<br>អ. tuberculosis bacillus<br>បារ. Bacille de la tuberculose/ Bacille de Koch (m.) | បាក់តេរីម្យ៉ាងដែលបង្ករោគរបេងចំពោះមនុស្សនិងសត្វ។ បាក់តេរីនេះរកឃើញនៅគ.ស.១៨៨២ ដោយជនជាតិអាល្លឺម៉ង់ឈ្មោះ រ៉ូបែរកុក(Robert Koch)។ |
| **៦៥- បាស៊ីយ៍/បាស៊ីឃ្លង់ បាស៊ីយ៍/បាស៊ីហាង់សិន**<br>អ. Hansen's bacillus<br>បារ. bacille de Hansen (m.) | បាក់តេរីម្យ៉ាងដែលបង្ករោគឃ្លង់។ បាក់តេរីនេះរកឃើញនៅគ.ស.១៨៧៣ ដោយជនជាតិន័រវែសឈ្មោះ ហង់សិន(Gerhard Armauer Hansen)។ |

| | |
|---|---|
| ៦៦- បេសេហ្ស(វ៉ាក់សាំង)<br>អ. bacillus Calmette-Guérin(vaccine)<br>បារ. BCG(vaccin)/ bacille bilié Calmette-Guérin (vaccin)(m.) | វ៉ាក់សាំងការពាររោគរបេងដែលរកឃើញនៅចន្លោះគ.ស.១៩០៤-១៩២៨ ដោយជនជាតិបារាំងឈ្មោះលោក អាល់ប៊ែរកាល់ម៉ែត(Albert Calmette) និង លោក កាមី(យ៍)ហ្គេរ៉ាំង(Camille Guérin)។ |
| ៦៧- ការស្ងាប<br>អ. yawning<br>បា. bâillement (m.) | ការហាមាត់ដោយអចេតនាដកដង្ហើមចូលយ៉ាងខ្លាំងនិងបញ្ចេញខ្យល់បន្តិចម្តងៗមកវិញ។ សកម្មភាពនេះកើតមាននៅពេលអស់កម្លាំង ងងុយដេក ឬធុញថប់។ |
| ៦៨- ថង់<br>អ. sac/bag<br>បារ. sac (m.) | បរិក្ខារវេជ្ជសាស្ត្រជាស្បោងម្យ៉ាងសម្រាប់ត្រងលំហូរសារធាតុរាវ ខ្ទុះ ឬឈាមកដែលហូរចេញពីសរីរាង្គកាយ។ |
| ៦៩- កន្ថោរពេទ្យ/ បាសាំងពេទ្យ<br>អ. bedpan<br>បារ. bassin de lit (m.) | បរិក្ខារវេជ្ជសាស្ត្រជាកន្ថោរមានទ្រង់ទ្រាយសំប៉ែតសម្រាប់ឱ្យអ្នកជំងឺបន្ទោបង់នៅលើគ្រែ។ |
| ៧០- មាត់ឆែប/ឆែបមាត់<br>អ. cleft lip/cleft palate<br>បារ. bec-de-lièvre (m.) | វិរូបភាពពីកំណើតដែលបបូរមាត់និង/ឬក្រអូមមាត់ខាងលើ មានសណ្ឋានជាវង្វេះប្រហ។ |
| ៧១- បង់រុំ<br>អ. band<br>បារ. bande (f.) | បន្ទះស្បៃ លោហធាតុ ឬ ប្លាស្ទិកទន់ប្រើក្នុងវេជ្ជសាស្ត្រ សម្រាប់រុំព័ទ្ធសរីរាង្គណាមួយ។ |
| ៧២- ការរុំបង់<br>អ. bandage<br>បារ. bandage (m.) | វិធីរុំរបួសឬដំបៅដោយប្រើបង់រុំដើម្បីទប់ឱ្យនឹងឬទប់លំហូរឈាម។ |
| ៧៣- ការត្រាំ<br>អ. balneation<br>បារ. balnéation (f.) | វិធីពន្លិចសរីរាង្គកាយមួយផ្នែកឬទាំងមូលក្នុងទឹកឬក្នុងសូលុយស្យុងផ្សេងៗក្នុងគោលបំណងព្យាបាល។ |
| ៧៤- ការត្រាំព្យាបាល<br>អ. balneotherapy<br>បារ. balnéothérapie (f.) | វិធីព្យាបាលជំងឺដោយការត្រាំ។ |
| ៧៥- តុល្យភាព<br>អ. balance<br>បារ. balance(f.) | ស្ថានភាពលំនឹងរវាងធាតុនានានៅក្នុងភាវៈរស់ ដូចជាលំនឹងអត្រាអេឡិចត្រូលីត(électrolyte) អាស៊ីដ-បាស(acide-base)។ |

## II.៤- បច្ចេកសព្ទស្នើដោយគណៈកម្មការទស្សនវិជ្ជា

| | |
|---|---|
| **១- អសុទ្ធចិត្ត**<br>អ. bad faith<br>បារ. mauvaise foi | លក្ខខណ្ឌមួយដែលមនុស្សម្នាក់បង្វែរការយល់ឃើញរបស់នរណាម្នាក់ទៀតចេញពីការណ៍ពិត ឬអំណាចជ្រើសរើសនិងជម្រើសនានាក្នុងកម្រិតណាមួយដែលគេដឹងថាវាមាន។ លក្ខខណ្ឌនេះកត់សម្គាល់ដោយ **ហ្សង់ ប៉ូល សាត្រ** (Jean-Paul Sartre)។ |
| **២- ការបាត់ស្មារតីគ្រប់គ្រង**<br>អ. ecstasy<br>បារ. extase | សភាពមួយដែលការទទួលដឹងដោយញាណធម្មតាឈប់ដំណើរការមួយរយៈ ហើយប្រធានបែរជាដឹងពីភាពអស្ចារ្យជាងមុនប្រកបដោយភាពសប្បាយរីករាយ ប៉ុន្តែបន្ទាប់មកអ្វីដែលប្រធានដឹងនោះ មិនអាចទទួលដឹងបានជាធម្មតានោះទេ។ ម្យ៉ាងទៀត ការបាត់ស្មារតីគ្រប់គ្រងជាសភាពខាងខួរក្បាល ជាធម្មតាបង្កដោយការឆ្លងកាត់បទពិសោធន៍គម្ពីរនិយមជ្រុលខាងសាសនា ការត្រេកត្រអាលផ្លូវភេទ ឬការញៀនគ្រឿងញៀន ... ក្នុងនោះ ពេលខ្លះ បុគ្គលបានបាត់ស្មារតីគ្រប់គ្រងនិងសម្បជញ្ញៈ ដោយសារតែការគ្របដណ្ដប់ពីវេទនារម្មណ៍យ៉ាងខ្លាំង។ |
| **៣- សត្យានុមតិភាព/<br>វត្ថុវិស័យភាព**<br>អ. objectivity<br>បារ. objectivité | អត្ថិភាពពិតនៃអ្វីមួយដែលមិនផ្អែកលើចំណាប់អារម្មណ៍ឬគំនិតរបស់មនុស្ស។<br>ឧទាហរណ៍ទី១ រសជាតិជូរនៃផ្លែអំពិលគឺជាសត្យានុម័តិភាព។<br>ឧទាហរណ៍២ សច្ចភាពនៅក្នុងហេតុការណ៍មួយគឺជាសត្យានុម័តិភាព។ |
| **៤- អត្តនោមតិភាព/<br>ប្រធានវិស័យភាព**<br>អ. subjectivity<br>បារ. subjectivité | អត្ថិភាពនៃអ្វីមួយដោយផ្អែកលើទស្សនៈឬអារម្មណ៍របស់បុគ្គលជាជាងផ្អែកលើហេតុការណ៍ខាងក្រៅឬកស្តុតាង។<br>ឧទាហរណ៍ ការយល់ថាព្រះអាទិត្យរះនៅទិសខាងកើតនិងលិចនៅទិសខាងលិច គឺជាអត្តនោមតិភាពរបស់មនុស្ស។ |
| **៥- អដ្ឋង្គិកមគ្គ**<br>អ. eightfold path<br>បារ. octuple sentier | ផ្លូវដែលប្រកបដោយអង្គប្រាំបីដែលជាមជ្ឈិមាបដិបទា(ផ្លូវកណ្ដាល)បានដល់ សីល សមាធិ បញ្ញា ជាផ្លូវប្រតិបត្តិដើម្បីរំដោះខ្លួនឱ្យចេញផុតពីសេចក្ដីទុក្ខ។ អង្គរបស់អដ្ឋង្គិកមគ្គទាំង៨មាន៖<br>១- សម្មាទិដ្ឋិ គំនិតយល់ឃើញត្រូវ គឺគំនិតយល់ឃើញថា ធ្វើបុណ្យបានបុណ្យ ធ្វើបាបបានបាបជាដើម។ សមាទិដ្ឋិនេះទៀតសោត គឺសំដៅយកបញ្ញាយល់ឃើញប្រពៃ គឺឃើញនូវអរិយសច្ចទាំងបួន មានទុក្ខសច្ច សមុទយសច្ច និរោធសច្ច និងមគ្គសច្ច។<br>២- សម្មាសង្កប្បោ ត្រិះរិះត្រូវ គឺត្រិះរិះចេញចាកកាម ត្រិះរិះដល់ការមិនព្យាបាទ ហៅថាអព្យាបាទ និងការត្រិះរិះមិនជាហេតុបៀតបៀនអ្នកដទៃ (អវិហិង្សា)។<br>៣- សម្មាវាចា សម្ដីនិយាយត្រូវ បានដល់វាចាវៀរចាកវចីទុច្ចរិត៤។<br>៤- សម្មាកម្មន្តោ ការងារត្រូវ បានដល់ការងារដែលវៀរចាកនូវទុច្ចរិតទាំង៣ |

| | |
|---|---|
| | ឬការងារទាំងទាំងឡាយណា ដែលមិនមានទោស ហើយផ្តល់ប្រយោជន៍ដល់ខ្លួននិងសង្គម។<br>៥- សម្មាអាជីវោ ការចិញ្ចឹមជីវិតត្រូវ បើគ្រហស្ថបានដល់ការលះបង់នូវជំនួញខុសទាំង៥(មិច្ឆាជីវ) បើបព្វជិតបានដល់ការលះបង់នូវបាបធម៌៥ និងអនេសនៈ២១ ជាដើម។<br>៦- សម្មាវាយាមោ ការព្យាយាមត្រូវ បានដល់ការព្យាយាមក្នុងស្ថានទាំង៤ មានកម្ចាត់បង់នូវអំពើអាក្រក់ និងព្យាយាមធ្វើអំពើល្អ។<br>៧- សម្មាសតិ រឭកប្រពៃ គឺរឭកក្នុងសតិប្បដ្ឋាន៤។<br>៨- សម្មាសមាធិ តាំងចិត្តខ្ជាប់ប្រពៃ គឺចម្រើនក្នុងឈាន៤។<br>អដ្ឋង្គិកមគ្គមិនមែនជាការអភិវឌ្ឍត្រង់ភ្លឹងដូចបន្ទាត់នោះទេ ប៉ុន្តែជាការបំបែកធាតុខុសៗគ្នាដែលគេត្រូវការដើម្បីឱ្យជីវិតស៊ីរូបផុតពីសេចក្តីទុក្ខបាន។<br>អដ្ឋង្គិកមគ្គឬហៅម្យ៉ាងទៀតថា មជ្ឈិមប្បដិបទា(ផ្លូវកណ្តាល)ក៏បាន។ ឧទាហរណ៍ ព្រះសង្ឃទូន្មានឱ្យពុទ្ធបរិស័ទយកអដ្ឋង្គិកមគ្គ ធ្វើជាមាគ៌ាជីវិត។ |
| **៦- សុឃាត**<br>អ. euthanasia<br>បារ. euthanasie | ការប្រតិបត្តិនូវការបញ្ចប់ជីវិតអ្នកជំងឺដោយចេតនា ដើម្បីបំបាត់ការឈឺចាប់ខាងផ្លូវកាយនិងផ្លូវចិត្ត។ |
| **៧- ទស្សនវិជ្ជាបស្ចិមប្រទេស**<br>អ. western philosophy<br>បារ. philosophie occidentale | ស្នាដៃនិងគំនិតនៃពួកបស្ចិមប្រទេស(បណ្តាប្រទេសអឺរ៉ុបនិងអាម៉េរិក)ត្រូវបានគេបង្កើតឡើងដោយកការគិតបែបទស្សនវិជ្ជាស្តីពីអរិយធម៌បស្ចិមប្រទេស ជាពិសេស អរិយធម៌ដែលចាប់ផ្តើមដោយទស្សនវិជ្ជាក្រិកបុរាណ។<br>ទស្សនវិជ្ជាបស្ចិមប្រទេសខុសគ្នាពីទស្សនវិជ្ជាបូព៌ាប្រទេសនិងទស្សនវិជ្ជាអន្តោគ្រាម។ |
| **៨- សីលវិជ្ជាអស្តិរូប**<br>អ. metaethics<br>បារ. méta-éthique | សីលវិជ្ជាមួយប្រភេទដែលសិក្សាអំពីប្រភពនិងអត្ថន័យនៃបញ្ញត្តិទស្សនវិជ្ជាសីលធម៌។ |
| **៩- សីលវិជ្ជានិយាម**<br>អ. normative ethics<br>បារ. ethique normative | សីលវិជ្ជាមួយប្រភេទដែលទាក់ទងនឹងការសម្រេចអំពីស្តង់ដាឬខ្នាតគំរូសីលធម៌ ដែលកំណត់ថា ឥរិយាបថណាមួយត្រឹមត្រូវគួរនឹងធ្វើតាមនិងឥរិយាបថខុសឆ្គងដែលគួរជៀសវាង។ |
| **១០- សីលវិជ្ជាអនុវត្តន៍**<br>អ. applied ethics<br>បារ. ethique appliquée | សីលវិជ្ជាមួយប្រភេទដែលទាក់ទងនឹងការវិភាគជាក់លាក់អំពីបញ្ហាវិវាទប្បដិវាទ(បញ្ហាចម្រូងចម្រាស)ខាងសីលធម៌ ដូចជា ការរំលូតកូន ការសម្លាប់ទារក សិទ្ធិសត្វ កង្វល់ខាងបរិស្ថាន ការសម្លាប់មនុស្សដែលមានជំងឺធ្ងន់មើលមិនជា សីលធម៌សុខាភិបាល សីលធម៌ជំនួញ ការស្រឡាញ់ភេទដូចគ្នា សីលធម៌រួមភេទ ការកាត់ទោសប្រហារជីវិត និងសង្គ្រាមបរមាណូ ជាដើម។ |

| | |
|---|---|
| **១១- កាតាឡិបស៊ីស**<br>អ. katalepsis<br>បារ. katalepsis | តាមទស្សនវិទូអត់ធ្មត់និយម មានន័យថា មូលបដិញ្ញាចម្បងបែបមនោគមវិជ្ជា ដោយចាត់ទុកថាសភាពចិត្តរបស់អ្នកណាម្នាក់ជាប់ពាក់ព័ន្ធទៅនឹងការយល់ដឹង និងការទទួលយកបញ្ញត្តិទស្សនវិជ្ជាមូលដ្ឋាននានា។<br>តាមភាសាក្រិក ពាក្យ **កាតាឡិបស៊ីស** មានន័យថា ការចាប់យក។ |
| **១២- វប្បធម៌ស្ថាប័ន**<br>អ. organizational culture<br>បារ. oulture organisationnelle | ឥរិយាបថរួមរបស់មន្ត្រីនិងបុគ្គលិក ដែលជាផ្នែកមួយរបស់ស្ថាប័ននិងជាតម្លៃដែលមនុស្សចងភ្ជាប់ទៅនឹងការងារឬអំពើរបស់ពួកគេ។ វប្បធម៌នេះ រួមមាន តម្លៃ ទស្សនវិស័យ និយាម ភាសា ការងារ ប្រព័ន្ធសញ្ញា ជំនឿ និងទម្លាប់របស់ស្ថាប័ន។ វប្បធម៌ស្ថាប័នជះឥទ្ធិពលលើរបៀបដែលមនុស្សនិងក្រុមនីមួយៗធ្វើអន្តរកម្មជាមួយគ្នា លើអតិថិជននិងលើអ្នកពាក់ព័ន្ធផ្សេងទៀត។<br>ឧទាហរណ៍ សមាជិកថ្មីនៃស្ថាប័ននីមួយៗ តែងតែត្រូវបានគេបង្រៀនអំពីវប្បធម៌ស្ថាប័ន ជាពិសេស បង្រៀនអំពីគំរូនៃឥរិយាបថនិងការកំណត់រួម ដែលទាក់ទងទៅនឹងវិធីនៃការយល់ឃើញ ការគិតនិងការមានអារម្មណ៍អំពីការងារ។ |
| **១៣- ឥរិយាបថស្ថាប័ន**<br>អ. organizational behavior<br>បារ. comportement organisationnel | វិស័យមួយនៃការសិក្សាដោយអង្កេតលើផលប៉ះពាល់ដែលកើតចេញពីឥរិយាបថរបស់បុគ្គលម្នាក់ៗ ក្រុមនីមួយៗ និងរចនាសម្ព័ន្ធនានានៅក្នុងស្ថាប័នមួយ។<br>វិស័យនៃការសិក្សានេះជាប់ពាក់ព័ន្ធជាមួយមុខវិជ្ជាជាច្រើនរួមមាន សង្គមវិទ្យា ចិត្តវិទ្យា ទំនាក់ទំនង ការគ្រប់គ្រង ទ្រឹស្តីស្ថាប័ន និងធនធានមនុស្សវិទ្យា។ លើសពីនេះទៀត វាក៏អាចសំដៅទៅរកស្ថាប័នវិទ្យាឬវិទ្យាសាស្ត្រស្ថាប័នទៀតផង។<br>ឥរិយាបថស្ថាប័នមានឫសគល់នៅក្នុងចិត្តវិទ្យាឧស្សាហកម្មនិងចិត្តវិទ្យាស្ថាប័ន។ |
| **១៤- សន្និដ្ឋភាព**<br>អ. acquaintance<br>បារ. connaissance | វិធីដែលប្រធានយល់ដឹងពីកម្មវត្ថុតាមរយៈបទពិសោធន៍ផ្ទាល់និងភ្លាមៗ។<br>សន្និដ្ឋភាពមានលក្ខណៈផ្ទុយពីការពិពណ៌នា ដែលក្នុងនោះកម្មវត្ថុនៃការពិពណ៌នាត្រូវបានគេស្គាល់តាមរយៈអន្តរការណ៍នៃការសន្និដ្ឋាន។<br>កម្មវត្ថុសន្និដ្ឋភាពកើតឡើងតាមរយៈទិន្នន័យខាងវិញ្ញាណ ការចងចាំ និងបញ្ញត្តិទូទៅ ដូចជា ភាពក្រហម ភាពមូល ជាដើម។<br>សញ្ញាណនៃសន្និដ្ឋភាពត្រូវបានគេប្រើដើម្បីកំណត់ព្រំដែនអ្វីដែលយើងអាចដឹងតាមរយៈការសង្កេតឃើញភ្លាមៗ។<br>(ពាក្យនេះគេប្រើក្នុងពុទ្ធិវិទ្យា) |
| **១៥- ភ្នាក់ងារ**<br>អ. agent<br>បារ. agent | មនុស្សដែលប្រកបដោយវិចារណញ្ញាណនិងជាប្រធាននៃអំពើ ដែលអាចសម្រេចចិត្តធ្វើឬមិនធ្វើអំពើណាមួយ ហើយអាចពិចារណារកវិធីនិងអនុវត្តវិធីនោះ ដើម្បីជំរុញឱ្យមានការផ្លាស់ប្តូរ។<br>(ពាក្យនេះប្រើក្នុងទស្សនវិជ្ជាស្តីពីអំពើនិងសីលវិជ្ជា)។ |

| | |
|---|---|
| **១៦- ទំនោរ**<br>អ. tendency<br>បារ. tendance | ទិដ្ឋភាពនៃការប្រព្រឹត្តរបស់មនុស្សម្នាក់ៗ ដែលបង្ហាញតាមវិធីជាក់លាក់ណាមួយ ហើយជាកម្លាំងចលករខាងផ្លូវចិត្តច្បាស់លាស់តម្រង់ទៅរកគោលបំណងជាក់លាក់ណាមួយ។<br>តាមធម្មជាតិរបស់មនុស្ស ទំនោរសុទ្ធតែជាកម្លាំងពិតប្រាកដ ហើយសុទ្ធតែមានគោលបំណងជាក់លាក់។ តាមវិទ្យាសាស្ត្រ គោលបំណងទាំងឡាយពុំមែនកើតឡើងដោយឯកឯងនោះទេ ផ្ទុយទៅវិញ វាសុទ្ធតែមានប្រភពរបស់វា។ |
| **១៧- ឆន្ទៈ**<br>អ. will<br>បារ. volonté | អំណាចនៃចិត្តក្នុងការជ្រើសរើសចំណង់ខ្លាំងបំផុតក្នុងចំណោមចំណង់ជាច្រើនដែលមានក្នុងខណៈពេលមួយនៃការសម្រេចចិត្ត ដែលស្តែងឡើងតាមរយៈសកម្មភាពជាក់លាក់ណាមួយ។<br>ឆន្ទៈមិនសំដៅលើចំណង់ជាក់លាក់ណាមួយទេ ប៉ុន្តែសំដៅលើសមត្ថភាពក្នុងការប្រព្រឹត្តប្រកបដោយការសម្រេចចិត្តចំពោះចំណង់របស់បុគ្គលណាម្នាក់។<br>នៅក្នុងទស្សនវិជ្ជា ឆន្ទៈសំខាន់ណាស់ក្នុងនាមជាផ្នែកច្បាស់លាស់មួយនៃចិត្តរួមជាមួយនឹងវិចារណញ្ញាណនិងការយល់ដឹង។ ឆន្ទៈត្រូវបានចាត់ទុកថាសំខាន់នៅក្នុងសីលវិជ្ជា ដោយសារតែតួនាទីស្នូលនៅក្នុងការជួយមនុស្សម្នាក់ឱ្យប្រព្រឹត្តប្រកបដោយបំណង។ |
| **១៨- និមិត្តសត្វ**<br>អ. animal symbolicum<br>បារ. animaux symbolicum | តាមទស្សនៈរបស់លោក កាស៊ីរឺ(Ernst Cassirer) និមិត្តសត្វ សំដៅទៅលើមនុស្សដែលមានលក្ខណៈពិសេសរបស់ខ្លួនអាស្រ័យទៅលើសមិទ្ធផលដោយមិនអាស្រ័យលើរូបកាយនិងស្មារតីនោះទេ។ |
| **១៩- នរក**<br>អ. hell<br>បារ. enfer | តាមលទ្ធិគ្រិស្តសាសនា នរកជាលោកឬសភាវៈសម្រាប់អ្នកសាងបាបដែលមិនភ្ញាក់រឭក ក្រោយពេលពួកគេស្លាប់ទៅ ហើយអ្នកសាងបាបទាំងនោះត្រូវកាត់ផ្តាច់ពីអាទិទេព និងទទួលរងទណ្ឌកម្មផ្សេងៗផងដែរ។<br>តាមទស្សនៈពុទ្ធសាសនា នរកជាទីអបាយភូមិឬអធោលោកដែលមានរណ្តៅជាលំនៅនៃសត្វមានបាបនៅរងទុក្ខតាមកម្លាំងកម្មដែលខ្លួនធ្វើ។ |
| **២០- ទឡ្ហីករណ៍បុព្វហេតុទីមួយ**<br>អ. first cause argument<br>បារ. argument de la cause première | ទឡ្ហីករណ៍មួយនៃទឡ្ហីករណ៍បុរាណស្តីអំពីអត្ថិភាពរបស់អាទិទេព។<br>ហេតុការណ៍នីមួយៗនៅក្នុងពិភពធម្មជាតិ មានបុព្វហេតុរបស់វា។ ទោះ បីជាយ៉ាងណាក៏ដោយ គេមិនអាចរកឃើញបុព្វហេតុដំបូងបំផុតដែរ គឺគេគ្រាន់តែអាចត្រឡប់ទៅរកបុព្វហេតុនានា ដោយពន្លាតថយក្រោយបន្តបន្ទាប់ប៉ុណ្ណោះ។ ដើម្បីបញ្ឈប់ការត្រឡប់ពន្លាតថយក្រោយនេះ យើងត្រូវតែសន្មតថា អ្វីជាបុព្វហេតុទីមួយ។ បុព្វហេតុទីមួយនេះត្រូវបានគេសន្មតថាជាសកម្មភាពនៃការបង្កើតរបស់អាទិទេព។ |

| | |
|---|---|
| **២១- សួគ៌**<br>អ. heaven<br>បារ. ciel | លោកឬភពនៃសន្តិនិងសុភមង្គលដ៏ឧត្តមដែលគេជឿថា បុគ្គលល្អនឹងបានទៅកើតនៅក្រោយពេលគេស្លាប់ទៅ។<br>អារីស្តូតឱ្យនិយមន័យពាក្យ «សួគ៌» បីយ៉ាងផ្សេងៗគ្នា៖<br>១- មណ្ឌលដែលស្ថិតនៅចុងបំផុតនៃចក្រវាល។<br>២- មេឃឬសួគ៌តាមន័យទូទៅ។<br>៣- ចក្រវាលទាំងមូលដែលជាសទិសន័យនឹងលោកធាតុ។<br>នៅក្នុងប្រពៃណីគ្រិស្តសាសនា សួគ៌គឺជាកន្លែងបម្រុងទុកសម្រាប់មនុស្សបាបដែលព្រះបានសង្គ្រោះក្រោយពេលស្លាប់។ តាមន័យនេះ សួគ៌ជាភពដែលអាទិទេពនិងអស់ទេវតាស្ថិតនៅ។ |
| **២២- អនន្តភាព**<br>អ. eternity<br>បារ. éternité | លក្ខណៈមួយក្នុងចំណោមលក្ខណៈផ្សេងៗរបស់អាទិទេព ដែលត្រូវបានគេបកស្រាយបានតាមរបៀបពីរយ៉ាងខុសគ្នា។<br>របៀបទី១ អាទិទេពគឺជាអនន្ត ដោយសារតែអាទិទេពមិនចងដោយពេលវេលា។ អត្ថិភាពរបស់អាទិទេពនៅក្រៅពេលវេលាឬមិនចំណុះពេលវេលា, អាទិទេពគ្មានពេលកំណត់ ប៉ុន្តែអាទិទេពជាអ្នកបង្កើតពេល។ ដោយសារតែអាទិទេពមិននៅក្នុងពេលវេលា រាល់ព្រឹត្តិការណ៍ដែលកើតឡើងក្នុងពេល ចំពោះទ្រង់ គឺកើតឡើងដំណាលគ្នា។ ខណៈ «ឥឡូវ» របស់យើងសម្គាល់ពេលវេលានិងវត្តអត្ថិភាពក្នុងពេលប្រែប្រួល រីឯ «ឥឡូវ» របស់អាទិទេព ឋិតថេរ មិនប្រែប្រួលនិងមិនអាចធ្វើឱ្យប្រែប្រួល។<br>របៀបទី២ អាទិទេពមានលោកិយភាព ពោលគឺមានអតីតកាល បច្ចុប្បន្នកាលនិងអនាគតកាល ប៉ុន្តែព្រះអង្គជាអនន្តភាព ពីព្រោះអាទិទេពតែងតែមានអត្ថិភាពនៅក្នុងអតីតកាល មានអត្ថិភាពនៅក្នុងបច្ចុប្បន្នកាល និងនឹងតែងតែមានអត្ថិភាពនៅក្នុងអនាគតកាល។ អនន្តភាពស្មើនឹងចំនួនសរុបនៃកាលទាំងបី(អតីតកាល បច្ចុប្បន្នកាល និងអនាគតកាល)។<br>(ពាក្យនេះ គេប្រើក្នុងអស្តិរូបវិជ្ជានិងទស្សនវិជ្ជាអំពីសាសនា)។ |
| **២៣- ហឋយោគ**<br>អ. hatha-yoga<br>បារ. hatha-yoga | ផ្នែកមួយនៃប្រព័ន្ធទស្សនវិជ្ជាយោគៈដែលជាការហ្វឹកហាត់និងលត់ដំរាងកាយនិងចិត្តឱ្យមានតុល្យភាព ដោយប្រើវិធីផ្សេងៗដូចជា កាធ្វើសមាធិ ការហាត់ប្រាណ ជាដើម ហើយដែលមានកម្រិតស្រាលជាងប្រព័ន្ធវិធីយោគៈផ្សេងៗទៀត។ |
| **២២- តម្លៃសោភ័ណ**<br>អ. aesthetic value<br>បារ. valeur esthétique | លក្ខណៈនានាដែលធ្វើឱ្យស្នាដៃសិល្បៈមួយល្អ ឬជោគជ័យ ដូចជា តុល្យភាព ភាពទាក់ទាញ ប្រណីតភាព ភាពរស់រវើក ភាពស៊ីចង្វាក់ ភាពពេញលេញ ឬឯកភាព ពោលគឺជាអ្វីដែលជួយឱ្យស្នាដៃសិល្បៈមួយមាន «សោភណភាព» ហើយដែលខុសពីអ្វីដែលផ្តល់ប្រយោជន៍ សច្ចភាព និងសីលកុសលរបស់ស្នាដៃនោះ។ (បញ្ញត្តិនេះ គេប្រើនៅក្នុងសោភណវិជ្ជា)។ |

| | |
|---|---|
| **២៥- សព្ទវិវាទ**<br>អ. logomachy<br>បារ. logomachie | ការខ្វែងគំនិតគ្នាអំពីការប្រើប្រាស់ពាក្យ។ |
| **២៦- វិភាគ**<br>អ. analysis<br>បារ. analyse | ដំណើរនៃការគិតដោយបំបែកបញ្ហាទាំងមូលទៅជាសមាសភាគរបស់វា និងទំនាក់ទំនងរវាងសមាសភាគទាំងនោះ។ |
| **២៧- អាតូមនិយម**<br>អ. atomism<br>បារ. atomisme | ១- ទ្រឹស្តីបុរាណរបស់ដេម៉ូគ្រីត ( Democrite/Democritus ) អេពីគួ ( Epicure/ Epicurus ) និងលុយក្រែស ( Lucrèce/Lucretius ) ដែលថាចុណ្ណភាគសុទ្ធល្អិតបំផុត មិនអាចបំបែកតទៅទៀតបាននិងមិនអាចបំផ្លាញបាន គឺជាសមាស-ភាពមូលដ្ឋាននៃចក្រវាលទាំងមូល។<br>២- ទ្រឹស្តីដែលថា ស្ថាប័ន តម្លៃ និងលំនាំសង្គម កើតឡើងពីអំពើនិងប្រយោជន៍របស់បុគ្គលម្នាក់ៗ។ |
| **២៨- រូបតំណាង**<br>អ realistic statue<br>បារ. statue réaliste | រូបភាពដែលប្រត្យក្សារម្មណ៍ផ្តល់ឱ្យអង្គចងចាំ ( លំនឹក ) នៅពេលដែលមនុស្សបានជួបប្រាស្រ័យផ្ទាល់ជាមួយអង្គវត្ថុជាច្រើនលើក ហើយបានផ្តិតស្លាកស្នាមរបស់វាចូលទៅក្នុងខួរក្បាលមនុស្ស ក្រោយមកអង្គចងចាំបង្ហាញឡើងវិញនូវលក្ខណៈពិសេសមួយចំនួន ពេលដែលមនុស្សមិននៅផ្ទាល់ជាមួយអង្គវត្ថុ។ |
| **២៩- ការបង្កើតថ្មី**<br>អ. creativity<br>បារ. créativité | ជាទូទៅ ការបង្កើតថ្មីសំដៅយកការបង្កើតអ្វីមួយដែលថ្មី ដែលរួមទាំងវត្ថុរូបី និងគំនិត។ ការបង្កើតថ្មីត្រូវបានគេប្រើយ៉ាងទូលំទូលាយនៅក្នុងសកម្មភាពរបស់មនុស្ស ប៉ុន្តែ វាមានសារៈសំខាន់ដោយឡែកនៅក្នុងការបង្កើតសិល្បៈ។ ការបង្កើតថ្មីបង្ហាញនូវភាពថ្មី និងពាក់ព័ន្ធជាមួយការបង្កើតអ្វីមួយដែលខុសពីអ្វីដែលបានបង្កើតពីមុន ប៉ុន្តែ វាក៏ពង្រីកទៅហួសពីអ្វីដែលគ្រាន់តែជាភាពថ្មី។<br>( ពាក្យនេះគេប្រើនៅក្នុងសោភណវិជ្ជា )។ |
| **៣០- គតិបណ្ឌិតប្រតិបត្តិ**<br>អ. practical Wisdom<br>បារ. sagesse pratique ( f. ) | បច្ចេកសព្ទរបស់អារីស្តូត ( Aristote/Aristotle ) សម្រាប់ការពិចារណាដែលនាំទៅដល់សកម្មភាពប្រតិបត្តិ ពោលគឺសំដៅទៅដល់គុណធម៌ដែលកើតចេញពីការពិចារណាអំពីការអនុវត្តត្រឹមត្រូវនូវការយល់ដឹងទូទៅ និងការយល់ដឹងខាងទ្រឹស្តីសីលធម៌ចំពោះករណីជាក់ស្តែងដោយឡែកៗ។<br>អារីស្តូត និយាយថា គតិបណ្ឌិតប្រតិបត្តិ គឺជាសភាពពិតនិងសមហេតុផលនៃសមត្ថភាពក្នុងការធ្វើអំពើណាមួយ ដោយគិតដល់ផលល្អនិងអាក្រក់ចំពោះមនុស្ស។<br>( បញ្ញត្តិនេះគេប្រើនៅក្នុងទស្សនវិជ្ជាក្រិកបុរាណ សីលវិជ្ជា និងទស្សនវិជ្ជាស្តីអំពីអំពើ [គតិបណ្ឌិតប្រតិបត្តិ=ការពិចារណា=ការយល់ដឹង=បញ្ញា=ហេតុផលប្រតិបត្តិ=ការប្រុងប្រយ័ត្ន] )។ |

| | |
|---|---|
| **៣១- ការយល់សប្តិ /សុបិន**<br>អ. dream<br>បារ. rêve (m.) | សេរី(ដំណើរបន្តគ្នា)នៃរូបភាព គំនិត វេទនារម្មណ៍ និងឥន្ទ្រិយារម្មណ៍ដែលជាធម្មតាកើតឡើងដោយអចេតនានៅក្នុងចិត្តក្នុងរយៈពេលនៃដំណាក់កាលណាមួយនៃដំណេក។<br>ថ្វីបើខ្លឹមសារនិងគោលបំណងនៃការយល់សប្តិមិនត្រូវបានគេយល់ដឹងពេញលេញក៏ដោយ ក៏ការយល់សប្តិបានក្លាយទៅជាប្រធានបទនៃការសន្មតបែបវិទ្យាសាស្ត្រ ហើយវាក៏ជាប្រធានបទនៃចំណាប់អារម្មណ៍ខាងទស្សនវិជ្ជានិងសាសនាតាំងពីមានការកត់ត្រានៅក្នុងប្រវត្តិសាស្ត្រ។<br>ការសិក្សាបែបវិទ្យាសាស្ត្រអំពីការយល់សប្តិត្រូវបានគេហៅថា សុបិនវិទ្យា (oneirology)។ |
| **៣២- រាជានិយម**<br>អ. royalism<br>បារ. royalisme (m.) | ទស្សនៈដែលគាំទ្រគោលការណ៍ដឹកនាំដោយក្សត្រឬសន្តតិវង្សណាមួយនិងជំនឿចំពោះអំណាចធម្មានុរូបរបស់រដ្ឋបាលរាជាធិបតេយ្យឬក្សត្រ។ |
| **៣៣- វិជ្ជមាននិយម**<br>អ. positivism<br>បារ. positivisme (m.) | ប្រព័ន្ធគំនិតទស្សនវិជ្ជាដែលបង្កើតឡើងដោយទស្សនវិទូបារាំងឈ្មោះ អូហ្គូកុង (Auguste Comte) ប៉ុន្តែ ឫសគល់របស់វាចេញមកពីហ្វ្រង់ស៊ីសបេខឹន (Francis Bacon)។ ស្មារតីរួមរបស់វិជ្ជមាននិយមគឺថា ទស្សនវិជ្ជាគួរតែផ្តោតការយកចិត្តទុកដាក់តែទៅលើអ្វីដែលបទពិសោធផ្តល់ឱ្យជាក់ស្តែង និងគួរតែចៀសវាងពីការគិតបែបសន្មតដែលទៅហួសពីបទពិសោធ។ ដូច្នេះ វិជ្ជមាននិយមចាត់ទុកការសិក្សាអំពីវិធីវិទ្យាសាស្ត្រថាជាកិច្ចការចម្បងរបស់ខ្លួន និងបង្ហាញខ្លួនឯងថាជាប្រភេទនៃទស្សនវិជ្ជាអំពីវិទ្យាសាស្ត្រ។<br>(ពាក្យនេះគេប្រើនៅក្នុងទស្សនវិជ្ជាអំពីវិទ្យាសាស្ត្រ ពុទ្ធិវិទ្យា ទស្សនវិជ្ជាអំពីវិទ្យាសាស្ត្រសង្គម និងទស្សនវិជ្ជាអំពីសាសនា)។ |
| **៣៤- បិតាធិបតេយ្យ**<br>អ. paternalism<br>បារ. paternalisme (m.) | របៀបនៃការគ្រប់គ្រងនិងការដឹកនាំរដ្ឋដែលមានលក្ខណៈស្រដៀងនឹងការគ្រប់គ្រងរបស់ឪពុកទៅលើកូនឬការគ្រប់គ្រងដែលមានលក្ខណៈរួមផ្សំរវាងការប្រើអំណាចជាមួយនឹងការទទួលខុសត្រូវក្នុងការមើលថែសមាជិកដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។<br>នៅក្នុងសីលវិជ្ជា ពាក្យនេះមានន័យថា ជាការជ្រៀតជ្រែកចូលទៅក្នុងសេរីភាពរបស់អ្នកណាម្នាក់ដោយជឿថា ការជ្រៀតជ្រែកនោះ គឺដើម្បីលើកកម្ពស់កុសលរបស់អ្នកនោះឬការពារអ្នកនោះពីគ្រោះថ្នាក់ដែលកើតឡើង ទោះបីការជ្រៀតជ្រែកនោះបង្កឱ្យមានការជំទាស់ឬការតវ៉ាពីបុគ្គលដែលត្រូវបានគេជ្រៀតជ្រែកសេរីភាពនោះក៏ដោយ។<br>បច្ចុប្បន្ន បិតាធិបតេយ្យត្រូវបានជំទាស់ដោយទស្សនៈសេរីនិយម ដោយគេយល់ថា ជាការធ្វើឱ្យបាត់បង់សេរីភាព ស្វ័យភាព និងសិទ្ធិបុគ្គល។<br>(ពាក្យនេះគេប្រើនៅក្នុងសីលវិជ្ជានិងទស្សនវិជ្ជានយោបាយ)។ |

| | |
|---|---|
| **៣៥- ការសម្រុះសម្រួល**<br>អ. compromise<br>បារ. compromis (m.) | ការព្រមព្រៀងមួយដែលសម្រេចឡើងដោយភាគីពាក់ព័ន្ធតាមរយៈការចរចារួមគ្នា បន្ទាប់ពីភាគីនីមួយៗបានធ្វើសម្បទានមួយចំនួនចេញពីការទាមទារដំបូងៗរបស់ខ្លួន ដើម្បីអាចទទួលយកបានទាំងអស់គ្នា។<br>ការសម្រុះសម្រួលផ្អែកលើមូលដ្ឋាន ដែលភាគីនីមួយៗធ្វើសហប្រតិបត្តិការក្នុងការដោះស្រាយបញ្ហាជាជាងការធ្វើឱ្យខូចទំនាក់ទំនង។<br>(ពាក្យនេះគេប្រើនៅក្នុងសីលវិជ្ជានិងទស្សនវិជ្ជានយោបាយ)។ |
| **៣៦- សេរីនិយមក្លាស៊ិក/ សេរីនិយមបែបបុរាណ**<br>អ. classic liberalism<br>បារ. libéralisme classique | មនោគមវិជ្ជានយោបាយម្យ៉ាងនិងជាមែកជាងមួយនៃសេរីនិយមដែលគាំទ្រសេរីភាពពលរដ្ឋនៅក្រោមនីតិរដ្ឋនិងផ្តោតលើសេរីភាពខាងសេដ្ឋកិច្ច។<br>សេរីនិយមក្លាស៊ិកទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងសេរីនិយមនិងសេរីនិយមខាងសេដ្ឋកិច្ច។<br>នៅដើមសតវត្សរ៍ទី១៩សេរីនិយមក្លាស៊ិកត្រូវបានអភិវឌ្ឍដោយឈរលើគំនិតរបស់ទស្សនវិទូនៃសតវត្សរ៍មុនៗជាការឆ្លើយតបទៅនឹងនគរូបនីយកម្មនិងបដិវត្តន៍ឧស្សាហកម្មនៅអឺរ៉ុបនិងសហរដ្ឋអាម៉េរិក។<br>បុគ្គលល្បីល្បាញដែលគំនិតរបស់ពួកគាត់បានរួមចំណែកនៅក្នុងសេរីនិយមក្លាស៊ិក រួមមាន ចន ឡុក(John Locke), តូម៉ាស ជេហ្វ័រសាន់ (Thomas Jefferson), ហ្សង់ បាបទីស្តសាយ(Jean-Baptiste Say), តូម៉ាស ម៉ាល់ធឹស (Thomas Malthus) និងដេវីដ រីកាដូ (David Ricardo)។<br>សេរីនិយមក្លាស៊ិកត្រូវបានដកស្រង់ចេញពីទ្រឹស្តីសេដ្ឋកិច្ច (Economics) របស់អាដាម ស្មីត(Adam Smith) ជំនឿលើច្បាប់ធម្មជាតិ (Natural law) ទ្រឹស្តីផលប្រយោជន៍និយម(Utilitarianism) និងភាពរីកចម្រើន (Progress)។ |
| **៣៧- គោលជំហរ**<br>អ. attitude (position)<br>បារ. l'attitude (position) | សភាពនៃការយល់ព្រមឬការមិនយល់ព្រមខាងគំនិត ការពេញចិត្តឬការមិនពេញចិត្ត ដែលទាក់ទងនឹងវេទនារម្មណ៍និងអារម្មណ៍ ហើយដែលផ្ទុយទៅនឹងជំនឿ។<br>ជំនឿទាក់ទងនឹងហេតុការណ៍និងការគិត ចំណែកឯគោលជំហរវិញទាក់ទងនឹងការវាយតម្លៃនិងការឆ្លើយតបខាងវេទនារម្មណ៍។<br>មនុស្សដែលមានជំនឿដូចគ្នា អាចមានគោលជំហរខុសគ្នា ឬក៏មនុស្សដែលមានគោលជំហរដូចគ្នាអាចមានជំនឿខុសគ្នាចំពោះកម្មវត្ថុតែមួយ។ ដូច្នេះ ការខុសគ្នារវាងគោលជំហរនិងជំនឿ ដូចគ្នាទៅនឹងការខុសគ្នារវាងតម្លៃនិងហេតុការណ៍។ សីលវិជ្ជាអត្តនោម័តិអះអាងថា គោលជំហរទាក់ទងដោយផ្ទាល់នឹងហេតុផលជំរុញនិងឥរិយាបថ និងអះអាងថា ការវិនិច្ឆ័យខាងសីលវិជ្ជានិងខាងតម្លៃគឺជាបញ្ហានៃគោលជំហរជាជាងបញ្ហានៃការគិត។<br>(ពាក្យនេះប្រើនៅក្នុងសីលវិជ្ជានិងទស្សនវិជ្ជាស្តីពីអំពើ)។ |

| | |
|---|---|
| **៣៨- អាជ្ញា**<br>អ. authority<br>បារ. autorité | សិទ្ធិអំណាចដែលកាន់កាប់ដោយមនុស្សម្នាក់ ស្ថាប័នមួយ ឬរដ្ឋមួយដើម្បីចេញបញ្ជាឱ្យគោរព។ សិទ្ធិនេះបញ្ជាក់ពីកាតព្វកិច្ចមួយដែលអ្នកនៅក្រោមបង្គាប់នៃអាជ្ញានេះត្រូវតែគោរពនិងអនុវត្តតាម។<br>អាជ្ញាគឺជាប្រភេទមួយនៃអំណាច ប៉ុន្តែអំណាចទាំងអស់មិនមែនសុទ្ធតែជាអាជ្ញាទេ។ ប្រភេទអំណាចមួយចំនួនគ្រាន់តែជាកម្លាំងបង្ខិតបង្ខំ ហើយវាមិនមានធម្មានុរូបភាពទេ។ អាជ្ញាអាចគ្រប់គ្រងតែតំបន់និងមនុស្សមួយចំនួនដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ប៉ុន្តែមិនមែនគ្រប់គ្រងតំបន់និងមនុស្សផ្សេងទៀតដែលស្ថិតនៅក្រៅដែនសមត្ថកិច្ចរបស់ខ្លួនទេ។<br>វិសាលភាពនិងព្រំដែននៃអាជ្ញារបស់រដ្ឋទាមទារឱ្យមានការពន្យល់។<br>(ពាក្យនេះគេប្រើក្នុងបរិបទទស្សនវិជ្ជានយោបាយនិងទស្សនវិជ្ជាអំពីច្បាប់)។ |
| **៣៩- អាជ្ញានិយម**<br>អ. authoritarianism<br>បារ. l'autoritarisme (m.) | ទស្សនៈនយោបាយមួយដែលយល់ថា ប្រជាពលរដ្ឋត្រូវតែគោរពអាជ្ញាធរជាដាច់ខាត ដោយមិនអនុញ្ញាតឱ្យសួរដេញដោលឡើយ។<br>ក្នុងការប្រតិបត្តិ នៅក្នុងប្រព័ន្ធនយោបាយផ្តាច់ការមួយ រដ្ឋាភិបាលមានអំណាចឥតព្រំដែននិងខ្វះការបង្គាប់បញ្ជាត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ។ អាជ្ញាធរអាចសម្រេចចិត្តដោយមិនចាំបាច់ពិគ្រោះយោបល់ឬចរចាជាមួយអ្នកដែលទទួលផលប៉ះពាល់ពីការអនុវត្តសេចក្តីសម្រេចចិត្តនោះឡើយ។ សង្គមបែបនេះត្រូវបានគ្រប់គ្រងដោយមនុស្សម្នាក់ឬមនុស្សមួយក្រុមជាជាងដោយច្បាប់។<br>(ពាក្យនេះគេប្រើក្នុងបរិបទទស្សនវិជ្ជានយោបាយ) |
| **៤០- អសារនិយម**<br>អ. nihilism<br>បារ. nihilisme (m.) | ១- ទស្សនៈដែលយល់ថា ជំនឿនិងតម្លៃជាប្រពៃណីគ្មានហេតុផលនិងថា អត្ថិភាពគ្មានន័យនិងគ្មានប្រយោជន៍ ។<br>២- ទស្សនៈដែលបដិសេធនូវមូលដ្ឋានសត្យានុម័តិនានានៃសច្ចភាព ជាពិសេសសច្ចភាពខាងសីលធម៌។<br>៣- ទស្សនៈដែលជឿថា គ្រប់អង្គការសាសនានិងនយោបាយអាក្រក់ណាស់ ឬជាប្រព័ន្ធគំនិតមួយដែលថាគ្មានគោលការណ៍ឬជំនឿណាដែលមានន័យ ឬអាចជាការណ៍ពិតបានទេ។<br>ឧទាហរណ៍ ពួកអសារនិយមខាងសីលធម៌យល់ថា សីលធម៌គ្មានអត្ថិភាពពីធម្មជាតិទេ។ |
| **៤១- អន្តរកម្មនិយម**<br>អ. interactionism<br>បារ. interactionnisme (m.) | ទស្សនៈរបស់ពួកទ្វិកនិយមដែលអះអាងថា ថ្វីបើចិត្តនិងកាយជាសារធាតុពីរដាច់ដោយឡែកពីគ្នាក៏ដោយ ក៏វាជះឥទ្ធិពលលើគ្នាទៅវិញទៅមកតាមទំនាក់ទំនងហេតុផល។ ចិត្តនិងកាយជាធាតុពីរឯករាជ្យពីគ្នា ប៉ុន្តែនៅក្នុងជីវិតទាំងមូល កាយនិងចិត្តមានអន្តរកម្មជាមួយគ្នា។<br>(ពាក្យនេះគេប្រើក្នុងបរិបទអស្តិរូបវិជ្ជានិងទស្សនវិជ្ជាអំពីចិត្ត) |

| | |
|---|---|
| **៤២- ព្រលឹង**<br>អ. soul<br>បារ. âme | ផ្នែកអរូបធាតុដែលគេសន្មតថាមានវត្តមានតែនៅក្នុងភាវៈរស់ប៉ុណ្ណោះ។<br>ដោយសារតែហាក់ដូចជាគ្មានភាពខុសគ្នាខាងរូបធាតុរវាងភាវៈរស់នៅក្នុងខណៈនៃជីវិតដែលហៀបនឹងស្លាប់និងរាងកាយដែលទើបនឹងស្លាប់ថ្មីៗ ទើបទស្សនវិទូជាច្រើនតាំងពីសម័យប្លាតុង(Plato)បានអះអាងថា ព្រលឹងគឺជាសមាសភាគអរូបធាតុរបស់ភាវៈរស់។ ដោយហេតុថាមានតែវត្ថុរូបធាតុប៉ុណ្ណោះដែលមានទីបញ្ចប់ ទើបប្លាតុងចាត់ទុកថា ភាពអរូបធាតុរបស់ព្រលឹងជាមូលដ្ឋាននៃអមតភាពរបស់ព្រលឹង។ ទាំងប្លាតុង ទាំងអារីស្តូត មិនបានគិតថា មានតែមនុស្សទេដែលមានព្រលឹង៖ អារីស្តូត អះអាងថា ព្រលឹងក៏មានចំពោះសត្វនិងរុក្ខជាតិដែរ ពីព្រោះសត្វនិងរុក្ខជាតិសុទ្ធតែបង្ហាញមុខងារខ្លះជាភាវៈមានជីវិត។ ខុសពីប្លាតុង អារីស្តូតបដិសេធការចាកចេញនៃព្រលឹងពីអម្បូរមួយទៅអម្បូរមួយទៀតឬពីរាងកាយមួយទៅរាងកាយមួយទៀត បន្ទាប់ពីការស្លាប់។ គាត់សង្ស័យចំពោះសមត្ថភាពចាកចេញពីរាងកាយរបស់ព្រលឹងថា តើព្រលឹងអាចចាកចេញដោយលូននៅមានជីវិតនិងបំពេញមុខងារដោយគ្មានរាងកាយបានដែរឬទេ។<br>រ៉ឺណេ ដេកាត (René Déscartes) អះអាងថា មានតែមនុស្សទេដែលមានព្រលឹង និងអះអាងថាធម្មជាតិអរូបធាតុរបស់ព្រលឹងអាចបង្កើតសេរីភាពបាន ទោះបីជារាងកាយរបស់មនុស្សស្ថិតនៅ ឬមិនស្ថិតនៅក្រោមការកំណត់របស់ច្បាប់រូបធាតុក៏ដោយ។ |
| **៤៣- ភាវៈមនុស្ស**<br>អ. human being<br>បារ. être humain | ចំពោះអារីស្តូត(Aristotle) «ភាវៈមនុស្ស» គឺជាសត្វប្រកបដោយវិចារណញ្ញាណ។ ចំពោះរ៉ឺណេដេកាត(René Déscartes) «ភាវៈមនុស្ស» មិនមែនជាសរីរាង្គតែមួយទេប៉ុន្តែវាជាបន្សំនៃធាតុខុសគ្នាពីរគឺចិត្តនិងកាយ។ ទោះបីជាមានភាពខុសគ្នាក្នុងការកំណត់បញ្ញត្តិភាវមនុស្សរវាងអារីស្តូតនិងរ៉ឺណេដេកាតក៏ដោយក៏អ្នកទាំងពីរបានចាត់ទុកថា វិចារណញ្ញាណ គឺជាលក្ខណៈសំខាន់នៃភាវមនុស្ស។<br>ភាវមនុស្សត្រូវបានគេប្រើជាសទិសន័យជាមួយពាក្យ «មនុស្ស» ដែលគេយល់ថា ជាភាវៈមួយដែលមានសិទ្ធិមិនអាចដកហូតបាន ពោលគឺសិទ្ធិរស់រានមានជីវិត និងសិទ្ធិមានសេរីភាព ព្រមទាំងជាភាវៈមួយខ្ពស់ជាងសត្វផ្សេងៗដែលមិនមែនជាមនុស្ស។<br>ទស្សនវិជ្ជាសីលធម៌សហសម័យមានទំនោរចង់ផ្តាច់ «មនុស្ស» ចេញពី «ភាវៈមនុស្ស» ដោយជឿថា «មនុស្ស» គឺជាភាវៈដែលមានស្វ័យញាណ ចំណែកឯ «ភាវៈមនុស្ស» គ្រាន់តែជាសមាជិកនៃពូជដើមរបស់មនុស្ស គឺអូម៉ូសាព្យាង (Homosapiens) ប៉ុណ្ណោះ។<br>(ពាក្យនេះគេប្រើនៅក្នុងអស្តិរូបវិជ្ជា សីលវិជ្ជា និងទស្សនវិជ្ជាអំពីចិត្ត)។ |